# ព្រះគម្ពីរ
# សម្ពន្ធមេត្រីថ្មី
# ដំណឹងល្អរៀបរៀងដោយលោកម៉ាថាយ

## ពាក្យលំនាំ

លោកម៉ាថាយជាអ្នកទារពន្ធជាតិយូដាម្នាក់ដែលពីដើមមានឈ្មោះថាលេវី។ ព្រះយេស៊ូបានត្រាស់ហៅលោកមកធ្វើជាសាវ័ក ព្រមទាំងបានតែងតាំងលោកជាគ្រីស្តទូតផង។

## គោលបំណងរបស់លោកម៉ាថាយ

លោកបានតែងកណ្ឌគម្ពីរដំណឹងល្អនេះក្រោមការបំភ្លឺរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីណែនាំជនជាតិយូដាឲ្យជឿថាព្រះយេស៊ូពិតជាព្រះគ្រីស្តដែលបានយាងមកតាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។ លោកចង់បង្ហាញថា ព្រះយេស៊ូយាងមកក្នុងលោកនេះដើម្បីបំពេញកិច្ចការទាំងអស់ស្របតាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់កាលពីដើម និងស្របតាមពាក្យដែលពួកព្យាការីថ្លែងទុកមកផងដែរ។

លោកម៉ាថាយចង់ពន្យល់ទៀតថា ព្រះយេស៊ូក៏ដូចជាលោកម៉ូសេដែរ ព្រះអង្គយាងមកប្រទានវិន័យតែវិន័យថ្មីនេះធ្វើឲ្យវិន័យពីដើមមានអត្ថន័យនិងមានតម្លៃពេញលក្ខណៈថែមទៀត។ ហេតុនេះហើយបានជាលោកចូលចិត្តដកស្រង់ឃ្លាជាច្រើនពីព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ដែលជនជាតិយូដាចាំច្បាស់មកចំលងដាក់ក្នុងគម្ពីររបស់លោក ដើម្បីធ្វើជាភស្តុតាងបញ្ជាក់ថាព្រះយេស៊ូពិតជាយាងមកផ្តល់អត្ថន័យឲ្យព្រះគម្ពីរសម្ពន្ធមេត្រីចាស់បានពេញលេញ។

លោកម៉ាថាយក៏ចង់ពន្យល់ជនជាតិយូដាថា ក្រុមគ្រីស្តបរិស័ទគ្រប់ជាតិគ្រប់សាសន៍ពិតជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ រីឯជនជាតិអ៊ីស្រាអែលដែលមិនព្រមជឿព្រះយេស៊ូ លែងមានសិទ្ធិជាប្រជារាស្ត្ររបស់ព្រះអង្គទៀតហើយ។

លោកម៉ាថាយយកចិត្តទុកដាក់ដាស់តឿនក្រុមគ្រីស្តបរិស័ទដែលហៅថា "ព្រះសហគមន៍" ដ្បិតព្រះសហគមន៍នេះហើយដែលបានទទួលអំណាចពីព្រះគ្រីស្តនិងបន្តបេសកកម្មរបស់ព្រះអង្គក្នុងពិភពលោកសព្វថ្ងៃ។

លោកម៉ាថាយសរសេរកណ្ឌគម្ពីរដំណឹងល្អនេះតាមគំនិតរបស់ជនជាតិយូដា គឺលោកមិនហ៊ានសរសេរព្រះនាមព្រះជាម្ចាស់ទេតែលោកប្រើពាក្យ«ស្ថានបរមសុខ»ជំនួសវិញឧទាហរណ៍លោកប្រើពាក្យ«ព្រះរាជ្យនៃស្ថានបរមសុខ»ជំនួសពាក្យ «ព្រះរាជ្យរបស់ព្រះជាម្ចាស់»។

អ្នកអានមុខជាឃើញក្នុងកណ្ឌគម្ពីរដំណឹងល្អម៉ាថាយថាព្រះយេស៊ូយាងមកផែនដីនេះ ដើម្បីកសាង

ពិភពលោកមួយថ្មីគឺ «ព្រះរាជ្យរបស់ព្រះជាម្ចាស់» ហើយព្រះអង្គប្រៀនប្រដៅអស់អ្នកដែលមកតាមព្រះអង្គ អំពីរបៀបរស់នៅសមស្របនឹងព្រះរាជ្យនេះ ដើម្បីឲ្យគេអាចធ្វើជាបន្ទាល់នាំដំណឹងល្អអំពីព្រះរាជ្យទៅប្រកាសប្រាប់មនុស្សទាំងអស់នៅសព្វទីកន្លែង រហូតដល់អវសានកាលនៃពិភពលោក។

# ដំណឹងល្អរៀបរៀងដោយលោកម៉ាថាយ

## បញ្ជីរាយនាមព្រះអយ្យកោរបស់ព្រះយេស៊ូ

(លូកា ៣.២៣-៣៨)

១ [១]នេះជាបញ្ជីរាយនាមព្រះអយ្យកោ របស់ព្រះយេស៊ូគ្រីស្ដ* ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ ដែលត្រូវជាពូជពង្សរបស់លោកអប្រាហាំ*។

[២]លោកអប្រាហាំបង្កើតលោកអ៊ីសាក លោកអ៊ីសាកបង្កើតលោកយ៉ាកុប លោកយ៉ាកុបបង្កើតលោកយូដា និងបងប្អូនរបស់គាត់ [៣]លោកយូដានិងនាងថាម៉ារបង្កើតលោកផារេស និងលោកសេរ៉ាលោកផារេសបង្កើតលោកហេតស្រូម លោកហេតស្រូមបង្កើតលោកអរ៉ាម [៤]លោកអរ៉ាមបង្កើតលោកអមីណាដាប់ លោកអមីណាដាប់បង្កើតលោកណាសូន លោកណាសូនបង្កើតលោកសាលម៉ូន [៥]លោកសាលម៉ូន និងនាងរ៉ាហាបបង្កើតលោកបូអាសលោកបូអាស និងនាងរូថបង្កើតលោកអូបេដលោកអូបេដបង្កើតលោកយេសាយ [៦]លោកយេសាយបង្កើតស្ដេចដាវីឌ។

ស្ដេចដាវីឌ និងភរិយារបស់អ៊ូរីបង្កើតស្ដេចសាឡូម៉ូន [៧]ស្ដេចសាឡូម៉ូនបង្កើតស្ដេចរ៉ូបោមស្ដេចរ៉ូបោមបង្កើតស្ដេចអប៊ីយ៉ា ស្ដេចអប៊ីយ៉ាបង្កើតស្ដេចអសាភ [៨]ស្ដេចអសាភបង្កើតស្ដេចយ៉ូសាផាតស្ដេច យ៉ូសាផាតបង្កើតស្ដេចយ៉ូរ៉ាម ស្ដេចយ៉ូរ៉ាមបង្កើតស្ដេចអូស្សាស [៩]ស្ដេចអូស្សាសបង្កើតស្ដេចយ៉ូថាម ស្ដេចយ៉ូថាមបង្កើតស្ដេចអខាស ស្ដេចអខាសបង្កើតស្ដេចអេសេខ្យាស [១០]ស្ដេចអេសេខ្យាសបង្កើតស្ដេចម៉ាណាសេ ស្ដេចម៉ាណាសេបង្កើតស្ដេចអម៉ូន ស្ដេចអម៉ូនបង្កើតស្ដេចយ៉ូស្យាស [១១]ស្ដេចយ៉ូស្យាសបង្កើតស្ដេចយេកូញ៉ាស និងអនុជរបស់ព្រះអង្គក្នុងគ្រាដែលគេកៀរជនជាតិអ៊ីស្រាអែល យកទៅធ្វើជាឈ្លើយនៅស្រុកបាប៊ីឡូន។

[១២]ក្រោយគ្រា ដែលគេកៀរជនជាតិអ៊ីស្រាអែលយកទៅធ្វើជាឈ្លើយនៅស្រុកបាប៊ីឡូន ស្ដេចយេកូញ៉ាសបង្កើតលោកសាឡាធាល លោកសាឡាធាលបង្កើតលោកសូរ៉ូបាបិល [១៣]លោកសូរ៉ូបាបិលបង្កើតលោកអប៊ីយូដ លោកអប៊ីយូដបង្កើតលោកអេលីយ៉ាគីម លោកអេលីយ៉ាគីមបង្កើតលោកអស៊ើរ [១៤]លោកអស៊ើរបង្កើតលោកសាដុក លោកសាដុកបង្កើតលោកអគីម លោកអគីមបង្កើតលោកអេលីយូដ [១៥]លោកអេលីយូដបង្កើតលោកអេលាសារ លោកអេលាសារបង្កើតលោកម៉ាថាន លោកម៉ាថានបង្កើតលោកយ៉ាកុប [១៦]លោកយ៉ាកុបបង្កើតលោកយ៉ូសែបជាស្វាមីរបស់នាងម៉ារី ដែលបង្កើតព្រះយេស៊ូហៅថាព្រះគ្រីស្ដ*។

១៧ដូច្នេះ ចាប់ពីលោកអប្រាហាំមកទល់ស្ដេច
ដាវីឌមានដប់បួនតំណ ចាប់ពីស្ដេចដាវីឌមកទល់នឹង
គ្រាដែលគេកៀរជនជាតិអ៊ីស្រាអែល យកទៅធ្វើជា
ឈ្លើយ នៅស្រុកបាប៊ីឡូនមានដប់បួនតំណហើយ
ចាប់ព គ្រាដែលគេកៀរជនជាតិអ៊ីស្រាអែលយកទៅ
ធ្វើជាឈ្លើយនៅស្រុកបាប៊ីឡូន មកទល់ព្រះគ្រីស្ដក៏
មានដប់បួនតំណដែរ។

## កំណើតព្រះយេស៊ូគ្រីស្ដ

(លូកា ២.១-៧)

១៨នេះជាដំណើររឿង អំពីកំណើតរបស់ព្រះ
យេស៊ូគ្រីស្ដ។ នាងម៉ារីមាតារបស់ព្រះអង្គត្រូវជាគូ
ដណ្ដឹងរបស់លោកយ៉ូសែប។ មុនពេលអ្នកទាំងពីររួម
រស់ជាមួយគ្នា នាងម៉ារីមានផ្ទៃពោះដោយសារព្រះ
វិញ្ញាណដ៏វិសុទ្ធរួចទៅហើយ។ ១៩លោកយ៉ូសែប
ស្វាមីរបស់នាងជាមនុស្សសុចរិត លោកមិនចង់
បំបាក់មុខនាងឡើយ គឺលោកសម្រេចចិត្តថានឹងផ្ដាច់
ពាក្យដោយស្ងាត់ៗវិញ។ ២០ពេលលោកកំពុងគិត
ដូច្នេះ ស្រាប់តែមានទេវទូត*របស់ព្រះអម្ចាស់មក
ប្រាប់លោកក្នុងសុបិននិមិត្តថា៖ «លោកយ៉ូសែបជា
ព្រះរាជវង្សរបស់ព្រះបាទដាវីឌ*អើយសូមកុំខ្លាចនឹង
ទទួលនាងម៉ារី មកធ្វើជាភរិយាឡើយ! បុត្រដែលនៅ
ក្នុងផ្ទៃនាង កើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធ*។ ២១នាង
នឹងសម្រាលបានបុត្រមួយ ហើយលោកត្រូវថ្វាយព្រះ
នាមថា"យេស៊ូ" ដ្បិតបុត្រនោះនឹងសង្គ្រោះប្រជារា
ស្ត្រព្រះអង្គឲ្យរួចពីបាបរបស់គេ»។
២២ហេតុការណ៍នេះកើតឡើង ស្របនឹងសេចក្ដី
ដែលព្រះអម្ចាស់មានព្រះបន្ទូល តាមរយៈព្យាការី*ថា
៖

២៣*«មើល!ស្ដ្រីព្រហ្មចារីនឹងមានផ្ទៃពោះ*
*នាងនឹងសម្រាលបានបុត្រមួយ*
*ដែលគេនឹងថ្វាយ*
*ព្រះនាមថា "អេម៉ានូអែល"»*[ក]

ប្រែថា «ព្រះជាម្ចាស់គង់ជាមួយយើង»។
២៤លុះលោកយ៉ូសែបភ្ញាក់ឡើងលោកក៏ធ្វើ
តាមបង្គាប់ទេវទូត*របស់ព្រះអម្ចាស់ គឺលោកទទួល
នាងម៉ារីមកធ្វើជាភរិយា ២៥ប៉ុន្តែលោកពុំបានរួម
បវេណីជាមួយនាង រហូតដល់នាងសម្រាលបានបុត្រ
ដែលលោកថ្វាយព្រះនាមថា "យេស៊ូ"។

## ពួកហោរាចារ្យមក ថ្វាយបង្គំព្រះឱរសយេស៊ូ

២ ១ព្រះយេស៊ូប្រសូត នៅភូមិបេថ្លេហិមក្នុងស្រុកយូ
ដា នារជ្ជកាលព្រះបាទហេរ៉ូដ។ មានពួកហោរាចារ្យ
នាំគ្នាធ្វើដំណើរ ពីទិសខាងកើតមកដល់ក្រុងយេរូសា
ឡឹម ២សួរថា៖ «ព្រះមហាក្សត្ររបស់ជនជាតិយូដា
ដែលទើបនឹងប្រសូតគង់នៅឯណា? យើងខ្ញុំបាន
ឃើញផ្កាយរបស់ព្រះអង្គរះនៅទិសខាងកើត ហើយ
យើងខ្ញុំមកថ្វាយបង្គំព្រះអង្គ»។ ៣ កាលព្រះបាទហេរ៉ូ
ដឮដំណឹងនេះទ្រង់រន្ធត់ព្រះហឫទ័យយ៉ាងខ្លាំង
ហើយអ្នកក្រុងយេរូសាឡឹមទាំងអស់ក៏រន្ធត់ចិត្ត
ជាមួយព្រះអង្គដែរ។ ៤ព្រះរាជាត្រាស់ហៅពួកនាយក
បូជាចារ្យ* និងពួកធម្មាចារ្យ*ទាំងប៉ុន្មានរបស់ប្រជា
ជនមក ដើម្បីសួរគេពីទីកន្លែងដែលព្រះគ្រីស្ដ* ត្រូវប្រ
សូត។ ៥ គេទូលស្ដេចថា ព្រះគ្រីស្ដត្រូវប្រសូតនៅភូមិ
បេថ្លេហិម ក្នុងស្រុកយូដាដ្បិតមានសេចក្ដីចែងទុក
មកតាមរយៈព្យាការី*ថា៖

៦ *«ភូមិបេថ្លេហិមជាដែនដីយូដាអើយ!*
*ក្នុងបណ្ដាក្រុងសំខាន់ៗនៃស្រុកយូដា*
*អ្នកមិនមែនតូចជាងគេទេ*
*ដ្បិតនឹងមានមេដឹកនាំមួយរូបកើតចេញពីអ្នក*
*លោកនឹងថែរក្សាជនជាតិអ៊ីស្រាអែល*
*ជាប្រជារាស្ត្ររបស់យើង»*[ខ] ។

៧ពេលនោះ ព្រះបាទហេរ៉ូដហៅពួកហោរាចារ្យ

មកជាសម្ងាត់ សួរបញ្ជាក់អំពីពេលដែលផ្កាយរះឡើ
ង។ ៩បន្ទាប់មក ទ្រង់ចាត់ហោរាចារ្យទាំងនោះឲ្យទៅ
ភូមិបេថ្លេហិម ដោយមានរាជឱង្ការថា៖ «សុំអស់
លោកនាំគ្នាទៅចុះ ហើយស៊ើបសួរដំណឹងអំពីព្រះ
ឱរសនោះឲ្យបានច្បាស់លាស់។ កាលបើបានឃើញ
ហើយ ចូរមកប្រាប់យើងវិញផង ដើម្បីឲ្យយើងបាន
ទៅថ្វាយបង្គំព្រះអង្គដែរ»។ ៩ក្រោយពីបានទទួល
រាជឱង្ការហើយ គេក៏នាំគ្នាចេញទៅ។ ពេលនោះ
ផ្កាយដែលគេបានឃើញនៅទិសខាងកើតនាំមុខគេ
រហូតដល់កន្លែងដែលព្រះឱរសគង់ទើបឈប់។ ១០
កាលហោរាចារ្យទាំងនោះឃើញផ្កាយ គេសប្បាយ
ចិត្តពន់ប្រមាណ ១១គេចូលទៅក្នុងផ្ទះ ឃើញព្រះ
ឱរសគង់នៅជាមួយនាងម៉ារីជាមាតា គេក៏នាំគ្នាក្រាប
ថ្វាយបង្គំព្រះអង្គ រួចបើកហិបយកទ្រព្យរបស់ខ្លួន គឺ
មាសគ្រឿងក្រអូបនិងជ័រល្វីងទេស មកថ្វាយព្រះអ
ង្គ។ ១២បន្ទាប់មកគេវិលត្រឡប់ទៅស្រុករបស់ខ្លួនវិញ
តាមផ្លូវមួយផ្សេងទៀត ដ្បិតព្រះជាម្ចាស់មានព្រះ
បន្ទូលប្រាប់គេក្នុងសុបិននិមិត្ត មិនឲ្យវិលទៅគាល់
ព្រះបាទហេរ៉ូដវិញឡើយ។

## ព្រះយេស៊ូភៀសខ្លួនទៅនៅស្រុកអេស៊ីប

១៣កាលពួកហោរាចារ្យចាកចេញផុតទៅ ទេវ
ទូត*របស់ព្រះអម្ចាស់ មកប្រាប់លោកយ៉ូសែបក្នុង
សុបិននិមិត្តថា៖ «ចូរក្រោកឡើងនាំព្រះឱរសនិង
មាតារបស់ព្រះអង្គរត់ទៅស្រុកអេស៊ីបទៅ។ ចូរស្នាក់
នៅស្រុកនោះ រហូតដល់យើងប្រាប់ឲ្យវិលត្រឡប់មក
វិញសឹមមក ដ្បិតស្ដេចហេរ៉ូដរកធ្វើគុតព្រះឱរស»។
១៤លោកយ៉ូសែបក្រោកឡើងនាំព្រះឱរសនិងមាតា
របស់ព្រះអង្គ រត់ភៀសខ្លួនទៅស្រុកអេស៊ីបទាំងយ
ប់។ ១៥គាត់ស្នាក់នៅទីនោះរហូតដល់ព្រះបាទហេរ៉ូដ
សោយទិវង្គត ដើម្បីឲ្យបានស្របនឹងសេចក្ដីដែលព្រះ
អម្ចាស់មានព្រះបន្ទូល តាមរយៈព្យាការីថា៖ *«យើង
បានហៅបុត្រយើងចេញពីស្រុកអេស៊ីបមក»*។

## ស្ដេចហេរ៉ូដចេញបញ្ជាឲ្យគេសម្លាប់ក្មេងៗ

១៦ព្រះបាទហេរ៉ូដយល់ថា ពួកហោរាចារ្យបាន
បំបាក់មុខព្រះអង្គ ស្ដេចទ្រង់ព្រះពិរោធក្រៃលែង
ហើយចេញបញ្ជា ឲ្យគេសម្លាប់ក្មេងប្រុសៗទាំងអស់
ដែលមានអាយុពីពីរខួបចុះមក នៅភូមិបេថ្លេហិម និង
ភូមិជិតខាង គឺគិតចាប់តាំងពីពេលកំណត់ដែលផ្កាយ
ត្រូវរះ ដូចទ្រង់បានសួរបញ្ជាក់ពួកហោរាចារ្យ។
១៧ ហេតុការណ៍នេះកើតឡើងស្របនឹងសេចក្ដី ដែល
មានចែងទុក តាមរយៈព្យាការី*យេរេមីថា៖

១៨ *«មានសំឡេងមួយលាន់ឮពីភូមិរ៉ាម៉ាមក*
*ជាទំនួញសោកសៅ*
*គឺនាងរ៉ាខែលយំសោកអាណិតកូន*
*នាងមិនព្រមឲ្យនរណាសម្រាលទុក្ខឡើយ*
*ព្រោះកូននាងបាត់បង់ជីវិត*
*អស់ទៅហើយ»*[យ]។

## ព្រះយេស៊ូត្រឡប់មកពីស្រុកអេស៊ីបវិញ

១៩កាល ព្រះបាទ ហេរ៉ូដ សោយទិវង្គតផុតទៅ
ទេវទូត*របស់ព្រះអម្ចាស់ មកប្រាប់លោកយ៉ូសែបនៅ
ស្រុកអេស៊ីបក្នុងសុបិននិមិត្តថា៖ ២០«ចូរក្រោកឡើង
នាំព្រះកុមារនិងមាតារបស់ព្រះអង្គវិលត្រឡប់ទៅ
ស្រុកអ៊ីស្រាអែលវិញទៅ ដ្បិតពួកអ្នកដែលប៉ុនប៉ងធ្វើ
គុតព្រះកុមារស្លាប់បាត់អស់ទៅហើយ»។

២១ លោកយ៉ូសែបក្រោកឡើងនាំព្រះកុមារ និង
មាតារបស់ព្រះអង្គ វិលត្រឡប់មកស្រុកអ៊ីស្រាអែលវិ
ញ។ ២២ប៉ុន្តែកាលលោកដឹងថា ព្រះបាទអកេឡោស
ឡើងគ្រងរាជ្យនៅស្រុកយូដា ស្នងព្រះបាទហេរ៉ូដជា
ព្រះបិតាលោក ខ្លាចមិនហ៊ានទៅស្រុកនោះទេ លោក
ភៀសខ្លួនទៅស្រុកកាលីឡេដោយព្រះជាម្ចាស់មាន
ព្រះបន្ទូលឲ្យដឹង ក្នុងសុបិននិមិត្ត។ ២៣លោកតាំងទី
លំនៅក្នុងភូមិមួយឈ្មោះណាសារ៉ែត ដើម្បីឲ្យស្រប
តាមសេចក្ដីដែលពួកព្យាការី*បានថ្លែងទុកថា៖ «គេ

នឹងហៅព្រះអង្គថា ជាអ្នកភូមិណាសារ៉ែត»។

## លោកយ៉ូហានបាទីស្ដប្រៀនប្រដៅបណ្ដាជន

(ម៉ាកុស ១.១-៨ លូកា ៣.១-១៨ យ៉ូហាន ១.១៩-២៨)

៣[១]នៅគ្រានោះ លោកយ៉ូហានបាទីស្ដ*មកដល់ លោកប្រកាស នៅវាលរហោស្ថាន*ស្រុកយូដាថា៖ [២]«ចូរប្រែចិត្តគំនិតឡើង ដ្បិតព្រះរាជ្យ*នៃស្ថានបរមសុខ* មកជិតបង្កើយហើយ!»។ [៣]ព្យាការី*អេសាយបានថ្លែងទុក អំពីលោកយ៉ូហាននេះថា៖

*«មានសំឡេងបុរសម្នាក់ស្រែកឡើង*
*នៅវាលរហោស្ថានថា៖*
*"ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់*
*ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ!"»*[ង]។

[៤]លោកយ៉ូហានមានសម្លៀកបំពាក់ ធ្វើអំពីរោមអូដ្ឋ ហើយពាក់ខ្សែក្រវាត់ធ្វើអំពីស្បែក។ លោកបរិភោគកណ្ដូបនិងទឹកឃ្មុំ។ [៥]អ្នកក្រុងយេរូសាឡឹម អ្នកស្រុកយូដា និងអ្នកស្រុកនៅតំបន់ទន្លេយ័រដាន់ទាំងមូលនាំគ្នាចេញទៅរកលោក។ [៦]គេទទួលសារភាពអំពើបាបរបស់ខ្លួន ហើយលោកក៏ធ្វើពិធីជ្រមុជទឹក*ឲ្យគេក្នុងទន្លេយ័រដាន់។

[៧]កាលលោកឃើញពួកខាងគណៈផារីស៊ី* និងពួកខាងគណៈសាឌូស៊ី*ជាច្រើន មកទទួលពិធីជ្រមុជទឹកពីលោក លោកមានប្រសាសន៍ទៅគេថា៖ «នែ៎ពូជពស់វែកអើយ! តើនរណាប្រាប់អ្នករាល់គ្នាឲ្យរត់គេចពីព្រះពិរោធ*របស់ព្រះជាម្ចាស់ដែលជិតមកដល់ដូច្នេះ?។ [៨]ចូរប្រព្រឹត្តអំពើល្អដើម្បីបញ្ជាក់ថាអ្នករាល់គ្នាបានប្រែចិត្តគំនិតមែន។ [៩]កុំនឹកស្មានថា ខ្លួនមានលោកអប្រាហាំជាបុព្វបុរសនោះឡើយ ដ្បិតខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់ក៏អាចធ្វើឲ្យថ្មទាំងនេះ ទៅជាកូនចៅលោកអប្រាហាំបានដែរ។ [១០]ពូថៅនៅជិតគល់ឈើជាស្រេច ដើមណាមិនផ្ដល់ផ្លែល្អទេ នឹងត្រូវកាប់រំលំហើយបោះទៅក្នុងភ្លើង។ [១១]ខ្ញុំធ្វើពិធីជ្រមុជ*អ្នករាល់គ្នាក្នុងទឹក ដើម្បីឲ្យអ្នករាល់គ្នាបានប្រែចិត្តគំនិត ប៉ុន្តែលោកដែលមកក្រោយខ្ញុំលោកមានកម្លាំងខ្លាំងជាងខ្ញុំ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែដោះស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង។ លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ*និងដោយភ្លើងវិញ។ [១២]លោកកាន់ចង្អេរលោកសម្អាតលានបោកស្រូវ អុំស្រូវយកគ្រាប់ល្អរបស់លោកប្រមូលដាក់ជង្រុក រីឯសំដី[ច]វិញ លោកនឹងដុតក្នុងភ្លើងដែលឆេះពុំចេះរលត់ឡើយ»។

## ព្រះយេស៊ូទទួលពិធីជ្រមុជទឹក

(ម៉ាកុស ១.៩-១១ លូកា ៣.២១-២២ យ៉ូហាន ១.៣២-៣៤)

[១៣]ពេលនោះ ព្រះយេស៊ូយាងពីស្រុកកាលីឡេ មករកលោកយ៉ូហាននៅត្រង់ទន្លេយ័រដាន់ ដើម្បីឲ្យលោកធ្វើពិធីជ្រមុជទឹក* ថ្វាយព្រះអង្គ។ [១៤]ប៉ុន្តែលោកយ៉ូហានប្រកែកថា៖ «ខ្ញុំទេតើ ដែលត្រូវទទួលពិធីជ្រមុជទឹកពីលោក ម្ដេចក៏លោកមករកខ្ញុំវិញ!»។ [១៥]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ឥឡូវនេះសុំធ្វើសិនចុះ ធ្វើដូច្នេះទើបស្របតាមគ្រប់សេចក្ដីដែលព្រះជាម្ចាស់បានបង្គាប់ទុកមក»។ លោកយ៉ូហានក៏យល់ព្រម។ [១៦]ពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹករួចហើយ ទ្រង់យាងឡើងពីទឹកស្រាប់តែផ្ទៃមេឃបើកចំហ ព្រះអង្គទតឃើញព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងចុះ ដូចសត្វព្រាបមកសណ្ឋិតលើព្រះអង្គ។ [១៧] ពេលនោះមានព្រះសូរសៀងពីលើមេឃមកថា៖ «នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់!»។

## ព្រះយេស៊ូឈ្នះការល្បួង

(ម៉ាកុស ១.១២-១៣ លូកា ៤.១-១៣)

៤[១]ពេលនោះ ព្រះវិញ្ញាណនាំព្រះយេស៊ូទៅវាល

របហោស្ថាន ឲ្យមារ*សាតាំងល្បួង ២ បន្ទាប់ពីបានតម
អាហារអស់រយៈពេលសែសិបថ្ងៃ សែសិបយប់មក
ព្រះអង្គក៏ឃ្លាន។
៣មេល្បួងចូលមកជិតព្រះអង្គ ពោលថា៖ «
ប្រសិនបើលោកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់
មែន សូមធ្វើឲ្យដុំថ្មទាំងនេះទៅជានំបុ័ងមើល៍!»។
៤ ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលតបទៅវិញថា៖ «ក្នុង
គម្ពីរមានចែងថា "មនុស្សមិនមែនរស់ដោយសារតែ
អាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូល
ដែលចេញ មកពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ"[ឈ]»
។ ៥ពេលនោះ មារនាំព្រះអង្គទៅក្រុងយេរូសាឡឹមជា
ក្រុងដ៏វិសុទ្ធ* ដាក់ព្រះអង្គលើកំពូលព្រះវិហារ* ៦
ហើយពោលថា៖ «ប្រសិនបើលោកពិតជាព្រះបុត្រា
របស់ព្រះជាម្ចាស់មែន សូមលោតទម្លាក់ខ្លួនចុះទៅ
ក្រោមមើល៍ ដ្បិតក្នុងគម្ពីរមានចែងថា "ព្រះជាម្ចាស់
នឹងបញ្ជាឲ្យទេវទូត*ចាំទ្រលោក មិនឲ្យជើងលោកប៉ះ
ទង្គិចនឹងថ្មឡើយ" [ញ]»។ ៧ព្រះយេស៊ូមានព្រះបន្ទូល
ទៅមារថា៖ «ក្នុងគម្ពីរមានចែងទៀតថា "កុំល្បងល
ព្រះជាម្ចាស់ជាព្រះរបស់អ្នកឡើយ"[ដ]»។ ៨មារក៏នាំ
ព្រះអង្គទៅលើកំពូលភ្នំមួយយ៉ាងខ្ពស់ ហើយចង្អុល
បង្ហាញនគរទាំងប៉ុន្មាន ក្នុងពិភពលោក ព្រមទាំងឲ្យ
ព្រះអង្គឃើញភោគទ្រព្យរបស់នគរទាំងនោះផង។ ៩
មារទូលព្រះអង្គថា៖ «ប្រសិនបើលោកក្រាបថ្វាយ
បង្គំខ្ញុំ ខ្ញុំនឹងប្រគល់សម្បត្តិនេះឲ្យ!»។ ១០ព្រះយេស៊ូ
មានព្រះបន្ទូលទៅមារថា៖ «សាតាំងអើយ!ចូរថយ
ចេញទៅ ដ្បិតក្នុងគម្ពីរមានចែងថា "អ្នកត្រូវថ្វាយបង្គំ
ព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះ
អង្គប៉ុណ្ណោះ"[ឋ]»។ ១១ពេលនោះ មារក៏ចាកចេញពី
ព្រះអង្គទៅ ហើយមានពួកទេវទូត*នាំគ្នាចូលមក
គាល់ និងបម្រើព្រះអង្គ។

## ព្រះយេស៊ូចាប់ផ្ដើមផ្សាយដំណឹងល្អនៅស្រុកកាលីឡេ

(ម៉ាកុស ១.១៤-១៥ លូកា ៤.១៤-១៥)

១២កាលព្រះយេស៊ូជ្រាបដំណឹងថា គេបានចាប់
លោកយ៉ូហានយកទៅឃុំឃាំង ហើយព្រះអង្គក៏
យៀសចេញទៅស្រុកកាលីឡេ។ ១៣ព្រះអង្គចាកចេញ
ពីភូមិណាសារ៉ែត ទៅស្នាក់នៅក្រុងកាផានុមជិតមាត់
សមុទ្រ ក្នុងតំបន់សាប៊ូឡូននិងតំបន់ណែបថាលី
១៤ ដើម្បីឲ្យបានស្របនឹងសេចក្ដីដែលមានចែងទុក
តាមរយៈព្យាការីអេសាយថា៖

១៥ *«ដែនដីសាប៊ូឡូន និង ដែនដីណែបថាលី*
*ដែលស្ថិតនៅតាមផ្លូវទៅកាន់សមុទ្រអើយ!*
*ស្រុកខាងនាយទន្លេយ័រដាន់*
*ស្រុកកាលីឡេដែលសាសន៍ដទៃរស់នៅអើយ!*
១៦ *ប្រជាជនដែលអង្គុយនៅក្នុងទីងងឹត*
*បានឃើញពន្លឺមួយដ៏ភ្លឺខ្លាំង ហើយមានពន្លឺមួយ*
*លេចឡើង បំភ្លឺពួកអ្នករស់ក្នុងស្រុកដែល*
*ស្ថិតនៅក្រោមអំណាចនៃសេចក្ដីស្លាប់»*[ឌ] ។

១៧តាំងពីគ្រានោះមក ព្រះយេស៊ូចាប់ផ្ដើម
ប្រកាសថា៖ «ចូរប្រែចិត្តគំនិតដ្បិតព្រះរាជ្យ*នៃស្ថាន
បរមសុខនៅជិតបង្កើយហើយ!»។

## ព្រះយេស៊ូត្រាស់ហៅសាវ័កបួនរូប

(ម៉ាកុស ១.១៦-២០ លូកា ៥.១-១១)

១៨កាលព្រះអង្គយាង តាមឆ្នេរសមុទ្រ កាលីឡេ
ទ្រង់ទតឃើញបងប្អូនពីរនាក់ ជាអ្នកនេសាទកំពុងតែ
បង់សំណាញ់ គឺលោកស៊ីម៉ូនហៅសិលា និងលោក
អន់ដ្រេជាប្អូនរបស់គាត់។ ១៩ព្រះអង្គមានព្រះបន្ទូល
ទៅគេថា៖ «សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នក
ឲ្យនេសាទមនុស្សវិញ»។ ២០អ្នកទាំងពីរក៏ទុក
សំណាញ់នៅទីនោះភ្លាម រួចដើរតាមព្រះអង្គទៅ។
២១ព្រះយេស៊ូយាងទៅមុខ ឆ្ងាយបន្តិចព្រះអង្គ

ទតឃើញបងប្អូនពីរនាក់ទៀត គឺលោកយ៉ាកុបនិង
លោកយ៉ូហានជាកូនរបស់លោកសេបេដេកំពុងតែ
រៀបចំអួននៅក្នុងទូក ជាមួយលោកសេបេដេ ជាឪពុ
ក។ ព្រះអង្គក៏ត្រាស់ហៅអ្នកទាំងពីរ។ ២២អ្នកទាំងពីរ
ចាកចោលទូកចាកចោលឪពុកភ្លាម រួចដើរតាមព្រះ
យេស៊ូទៅ។

២៣ព្រះយេស៊ូយាងកាត់ ស្រុកកាលីឡេទាំង
មូលព្រះអង្គបង្រៀនអ្នកស្រុក នៅក្នុងសាលាប្រជុំ*
របស់ពួកគេ ព្រះអង្គប្រកាសដំណឹងល្អអំពីព្រះរាជ្យ*
ហើយប្រោសអ្នកជំងឺគ្រប់យ៉ាង និងមនុស្សពិការគ្រប់
ប្រភេទក្នុងចំណោមប្រជាជនឲ្យបានជាផង។ ២៤ព្រះ
កិត្តិនាមរបស់ព្រះអង្គ ក៏ល្បីឮខ្ចរខ្ចាយពាសពេញ
ស្រុកស៊ីរីទាំងមូល។ គេបាននាំអស់អ្នកជំងឺគ្រប់យ៉ាង
និងអ្នកកើតទុក្ខក្រំគ្រាមនុស្សខ្មោចចូលមនុស្សឆ្កួត
ជ្រូក និងមនុស្សស្លាប់ដៃស្លាប់ជើង មករកព្រះអង្គ
ព្រះអង្គក៏ប្រោសគេឲ្យបានជាទាំងអស់គ្នា។ ២៥មាន
មហាជនជាច្រើនពីស្រុកកាលីឡេស្រុកដេកាប៉ូល
ក្រុងយេរូសាឡឹមស្រុកយូដា និងពីតំបន់ខាងនាយ
ទន្លេយ័រដាន់ នាំគ្នាដើរតាមព្រះយេស៊ូ។

## សុភមង្គលដ៏ពិតប្រាកដ

(លូកា ៦.២០-២៦)

៥ ១ព្រះយេស៊ូទតឃើញមហាជនទាំងនេះ ព្រះអង្គ
យាងឡើងទៅលើភ្នំ រួចព្រះអង្គគង់នៅទីនោះ។សាវ័
ក*នាំគ្នាចូលមកគាល់ព្រះអង្គ ២ព្រះអង្គក៏មានព្រះ
បន្ទូលបង្រៀនគេថា៖

៣ «អ្នកណាដាក់ចិត្តជាអ្នកក្រ *ខ្សត់*[ឈ]
អ្នកនោះមានសុភមង្គល*ហើយ
ដ្បិតពួកគេបានទទួលព្រះរាជ្យ
នៃស្ថានបរមសុខ!

៤ អ្នកណាសោកសៅ
អ្នកនោះមានសុភមង្គលហើយ
ដ្បិតព្រះជាម្ចាស់នឹងសម្រាលទុក្ខពួកគេ!

៥ អ្នកណាមានចិត្តស្លូតបូត
អ្នកនោះមានសុភមង្គលហើយ
ដ្បិតពួកគេនឹងទទួលផែនដីទុកជាមត៌ក!

៦ អ្នកណាស្រេកឃ្លានសេចក្ដី *សុចរិត**[ណ]
អ្នកនោះមានសុភមង្គលហើយ
ដ្បិតព្រះជាម្ចាស់នឹងប្រទានឲ្យ
ពួកគេបានឆ្អែត!

៧ អ្នកណាមានចិត្តមេត្តាករុណា
អ្នកនោះមានសុភមង្គលហើយ
ដ្បិតព្រះជាម្ចាស់នឹងសម្តែងព្រះហឫទ័យ
មេត្តាករុណាដល់ពួកគេវិញ!

៨ អ្នកណាមានចិត្តបរិសុទ្ធ*
អ្នកនោះមានសុភមង្គលហើយ
ដ្បិតពួកគេនឹងឃើញព្រះជាម្ចាស់!

៩ អ្នកណាកសាងសន្តិភាព
អ្នកនោះមានសុភមង្គលហើយ
ដ្បិតពួកគេនឹងមានឈ្មោះជាបុត្រ
របស់ព្រះជាម្ចាស់!

១០ អ្នកណាត្រូវគេបៀតបៀន
ព្រោះតែបានធ្វើតាមសេចក្ដីសុចរិត*
អ្នកនោះមានសុភមង្គលហើយ
ដ្បិតគេបានទទួលក្នុងព្រះរាជ្យ
នៃស្ថានបរមសុខ!

១១ ប្រសិនបើមានគេត្មះតិះដៀលបៀតបៀន
និងមានគេនិយាយអាក្រក់គ្រប់យ៉ាង បង្ខូចឈ្មោះអ្នក
រាល់គ្នា ព្រោះតែខ្ញុំនោះអ្នករាល់គ្នាមានសុភមង្គល
ហើយ! ១២ចូរអរសប្បាយរីករាយឡើងព្រោះអ្នករាល់
គ្នានឹងទទួលរង្វាន់យ៉ាងធំ នៅស្ថានបរមសុខដ្បិតពួក
ព្យាការី* ដែលរស់នៅមុនអ្នករាល់គ្នាក៏ត្រូវគេបៀត
បៀនដូច្នោះដែរ»។

## អំបិល និង ពន្លឺ

(ម៉ាកុស ៩.៥០-៥១ លូកា ១៤.៣៤-៣៥)

១៣«អ្នករាល់គ្នាជាអំបិល សម្រាប់មនុស្សលោក
ប៉ុន្តែ បើអំបិលបាត់ជាតិប្រៃហើយ តើគេនឹងយកអ្វី
មកធ្វើឲ្យប្រៃឡើងវិញបាន?។ អំបិលនោះគ្មាន
ប្រយោជន៍អ្វីទៀតទេ គឺមានតែបោះចោលទៅខាង
ក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ។ ១៤អ្នករាល់គ្នាជា
ពន្លឺ សម្រាប់បំភ្លឺមនុស្សលោក។គេមិនអាចលាក់
បំបាំងក្រុងណា ដែលសង់នៅលើភ្នំ បានឡើយ។
១៥ គេមិនដែលអុជចង្កៀង ហើយយកធុងគ្របពីលើ
នោះទេ គឺគេតែងយកចង្កៀងទៅដាក់លើជើងចង្កៀង
វិញ ហើយចង្កៀងនោះបំភ្លឺអស់អ្នកដែលនៅក្នុងផ្ទះ។
១៦ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបំភ្លឺមនុស្សទាំងឡាយ
ដូច្នោះដែរ គេនឹងឃើញអំពើល្អដែលអ្នករាល់គ្នាប្រ
ព្រឹត្ត ហើយលើកតម្កើងសិរីរុងរឿងព្រះបិតារបស់អ្នក
រាល់គ្នា ដែលគង់នៅស្ថានបរមសុខ*»។

## ព្រះបន្ទូលអំពីវិន័យ

១៧«សុំកុំនឹកស្មានថា ខ្ញុំមកលុបបំបាត់ធម្មវិ
ន័យឬគម្ពីរព្យាការី*ចោលឡើយ។ ខ្ញុំមិនមែនមកលុប
បំបាត់ទេ គឺខ្ញុំមកធ្វើឲ្យគម្ពីរមានអត្ថន័យពេញលក្ខ
ណៈទៅវិញ[៣]។ ១៨ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាបានដឹង
ច្បាស់ថា ដរាបណាផ្ទៃមេឃនិងផែនដីនៅស្ថិតស្ថេរ
ដរាបនោះគ្មានក្បៀស ឬបន្តក់ណាមួយក្នុងធម្មវិន័យ
*ត្រូវលុបបាត់ឡើយ គឺគម្ពីរទាំងមូលនឹងនៅស្ថិត
ស្ថេរ រហូតដល់ទីបំផុត។ ១៩អ្នកណាល្មើសបញ្ញត្តិតូច
មួយនេះ ហើយបង្រៀនអ្នកផ្សេងឲ្យធ្វើតាម អ្នកនោះ
នឹងមានឋានៈតូចជាងគេ ក្នុងព្រះរាជ្យ*នៃស្ថានបរម
សុខ។ ផ្ទុយទៅវិញ អ្នកណាប្រតិបត្តិតាមវិន័យ
ហើយបង្រៀនអ្នកផ្សេងឲ្យប្រតិបត្តិតាមអ្នកនោះ នឹង
មានឋានៈធំ ក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ ២០ខ្ញុំសុំ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បើសេចក្ដីសុចរិត*
របស់អ្នករាល់គ្នា មិនប្រសើរជាងសេចក្ដីសុចរិតរបស់
ពួកធម្មាចារ្យ និងពួកខាងគណៈផារីស៊ី*ទេ អ្នករាល់
គ្នាពុំអាចចូល ទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខបាន
ឡើយ»។

## ព្រះបន្ទូលអំពីកំហឹង

២១«អ្នករាល់គ្នាធ្លាប់ឮសេចក្ដី ដែលមានថ្លែង
ប្រាប់បុព្វបុរស*ថា "កុំសម្លាប់មនុស្ស"[៤] អ្នកណា
សម្លាប់គេអ្នកនោះនឹងត្រូវគេផ្ដន្ទាទោស។ ២២រីឯខ្ញុំ
វិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា អ្នកណាខឹងនឹង
បងប្អូន អ្នកនោះនឹងត្រូវគេផ្ដន្ទាទោសដែរ។ អ្នកណា
ជេរប្រទេចផ្ដាសាបងប្អូន អ្នកនោះនឹងត្រូវក្រុមប្រឹក្សា
ជាន់ខ្ពស់*កាត់ទោស ហើយអ្នកណាត្មះតិះដៀលគេ[៥]
អ្នកនោះនឹងត្រូវគេផ្ដន្ទាទោស ធ្លាក់ក្នុងភ្លើងនរកអវី
ចី។ ២៣ ដូច្នេះ កាលណាអ្នកយកតង្វាយទៅថ្វាយ
ព្រះជាម្ចាស់ ហើយនៅទីនោះអ្នកនឹកឃើញថា បង
ប្អូនណាម្នាក់មានទំនាស់នឹងអ្នក ២៤ចូរទុកតង្វាយ
របស់អ្នក នៅកន្លែងថ្វាយតង្វាយ ហើយទៅស្រុះ
ស្រួលនឹងបងប្អូនរបស់អ្នកជាមុនសិន រួចសឹមវិលមក
ថ្វាយតង្វាយរបស់អ្នកវិញ។ ២៥កាលណាអ្នកធ្វើ
ដំណើរទៅតុលាការ ជាមួយគូវិវាទរបស់អ្នក ចូរស្រុះ
ស្រួលជាមួយអ្នកនោះជាប្រញាប់ក្រែងលោ គេបញ្ជូន
អ្នកទៅចៅក្រម ចៅក្រមបញ្ជូនអ្នកទៅនគរបាល
ហើយអ្នកត្រូវជាប់គុក។ ២៦ខ្ញុំសុំប្រាប់ឲ្យអ្នកដឹង
ច្បាស់ថា ដរាបណាអ្នកមិនបានបង់ប្រាក់ពិន័យគ្រប់
ចំនួន ឥតខ្វះមួយសេនទេនោះអ្នកនឹងមិនរួចខ្លួន
ឡើយ»។

## ព្រះបន្ទូលអំពីការផិតក្បត់

២៧«អ្នករាល់គ្នាធ្លាប់ឮសេចក្ដីថ្លែងទុកមកថា
"កុំប្រព្រឹត្តអំពើផិតក្បត់"[៦]។ ២៨រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់
ប្រាប់អ្នករាល់គ្នាថា អ្នកណាមើលស្ត្រីម្នាក់[៨] ហើយ
មានចិត្តស្រើបស្រាលចង់រួមបវេណីជាមួយនាង អ្នក

នោះដូចជាបានប្រព្រឹត្តអំពើផិតក្បត់ជាមួយនាង នៅ
ក្នុងចិត្តរបស់ខ្លួន រួចស្រេចទៅហើយ។ ២៩ប្រសិនបើ
ភ្នែកស្ដាំរបស់អ្នកនាំអ្នកឲ្យប្រព្រឹត្តអំពើបាប ចូរខ្វេះ
ចេញហើយបោះចោលឲ្យឆ្ងាយពីអ្នកទៅ បើអ្នកបាត់
ភ្នែកតែមួយនេះ ប្រសើរជាងបណ្ដោយឲ្យរូបកាយ
ទាំងមូលធ្លាក់ទៅក្នុងនរក។ ៣០ប្រសិនបើដៃស្ដាំរបស់
អ្នកនាំអ្នកឲ្យប្រព្រឹត្តអំពើបាប ចូរកាត់វាហើយបោះ
ចោលឲ្យឆ្ងាយពីអ្នកទៅ បើអ្នកបាត់តែអវយវៈមួយ
នេះ ប្រសើរជាងបណ្ដោយឲ្យរូបកាយទាំងមូលធ្លាក់
ទៅក្នុងនរក»។

## ព្រះបន្ទូលអំពីការលែងលះប្ដីប្រពន្ធ

(ម៉ាថាយ ១៩.៩ ម៉ាកុស ១០.១១-១២ លូកា ១៦.១៨)

៣១«មានសេចក្ដីថ្លែងទុកមកថា "បុរសណា
លែងភរិយាត្រូវធ្វើលិខិតលែងលះឲ្យនាង"[ប] ៣២រីឯខ្ញុំ
វិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា បុរសណាលែង
ភរិយារបស់ខ្លួន (លើកលែងតែរួមរស់ជាមួយគ្នា
ដោយឥតបានរៀបការ[ផ]) បុរសនោះធ្វើឲ្យនាងទៅជា
ស្ត្រីផិតក្បត់ ប្រសិនបើនាងរៀបការម្ដងទៀត។ រីឯ
បុរសណារៀបការនឹងស្ត្រីប្ដីលែង បុរសនោះក៏ប្រព្រឹត្ត
អំពើផិតក្បត់ដែរ»។

## ព្រះបន្ទូលអំពីសម្បថ

៣៣«អ្នករាល់គ្នាធ្លាប់បានឮសេចក្ដី ដែលមាន
ថ្លែងប្រាប់បុព្វបុរស*ថា៖ "កុំបំភ្លេចពាក្យសម្បថ
ចោលឡើយ។ ត្រូវតែធ្វើតាមគ្រប់ពាក្យដែលអ្នកបាន
ស្បថនឹងព្រះអម្ចាស់"[ព]។ ៣៤រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់
ប្រាប់អ្នករាល់គ្នាថា កុំស្បថឲ្យសោះកុំស្បថដោយ
យកមេឃជាសាក្សីឡើយ ព្រោះមេឃជាបល្ល័ង្ករបស់
ព្រះជាម្ចាស់ ៣៥ក៏កុំស្បថដោយយកផែនដីជាសាក្សី
ដែរ ព្រោះផែនដីជាកំណល់ទ្រព្រះបាទារបស់ព្រះអ
ង្គ។ កុំស្បថដោយយកក្រុងយេរូសាឡឹមជាសាក្សី
ព្រោះយេរូសាឡឹមជាក្រុងរបស់ព្រះមហាក្សត្រដ៏ឧត្ត
ម។ ៣៦កុំស្បថដោយយកក្បាលអ្នកជាសាក្សី ព្រោះ
អ្នកពុំអាចធ្វើឲ្យសក់របស់អ្នកទៅជាសឬខ្មៅបាន
ឡើយ សូម្បីតែមួយសរសៃក៏ពុំបានផង។ ៣៧ត្រូវ
និយាយឲ្យទៀងទាត់ បើ"មែន"ឲ្យប្រាកដជា"មែន"
បើ"ទេ"ឲ្យប្រាកដជា"ទេ"។ រីឯពាក្យពន្លើសសុទ្ធតែ
មកពីមារកំណាចទាំងអស់»។

## ព្រះបន្ទូលអំពីគំនុំសងសឹក

(លូកា៦.២៩-៣០)

៣៨«អ្នករាល់គ្នាធ្លាប់បានឮសេចក្ដីថ្លែងទុកមក
ថា"ប្រសិនបើគេវាយភ្នែកអ្នកម្ខាង ត្រូវវាយភ្នែកគេតែ
ម្ខាងវិញ ប្រសិនបើគេវាយអ្នកបាក់ធ្មេញមួយ ត្រូវ
វាយគេឲ្យបាក់ធ្មេញតែមួយដែរ"[ភ]។ ៣៩រីឯខ្ញុំវិញ ខ្ញុំសុំ
បញ្ជាក់ប្រាប់អ្នករាល់គ្នាថា កុំតបតនឹងមនុស្ស
កំណាចឲ្យសោះ បើមានគេទះកំផ្លៀងស្ដាំរបស់អ្នក
ចូរបែរឲ្យគេទះម្ខាងទៀតទៅ។ ៤០បើមានគេប្ដឹងចង់
បានអាវក្នុងរបស់អ្នក ចូរឲ្យគេយកអាវធំថែមទៀត
ទៅ។ ៤១បើមានគេបង្ខំអ្នកឲ្យធ្វើដំណើរមួយយោជន៍
ចូរទៅពីរយោជន៍ជាមួយគេចុះ។ ៤២អ្នកណាសុំអ្វីពី
អ្នក ចូរឲ្យគេទៅ ហើយកុំគេចមុខចេញពីអ្នកដែលសុំ
ខ្ចីអ្វីៗពីអ្នកដែរ»។

## ត្រូវស្រឡាញ់ខ្មាំងសត្រូវ

(លូកា៦.២៧-២៨, ៣២-៣៦)

៤៣«អ្នករាល់គ្នាធ្លាប់បានឮសេចក្ដីថ្លែងទុកមក
ថា"ចូរស្រឡាញ់បងប្អូនឯទៀតៗ[ម] ហើយស្អប់ខ្មាំង
សត្រូវរបស់អ្នក"។ ៤៤រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នក
រាល់គ្នាថា ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា
ព្រមទាំងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទាន
ពរឲ្យអស់អ្នក ដែលបៀតបៀនអ្នករាល់គ្នាផង។ ៤៥
ធ្វើដូច្នេះ អ្នករាល់គ្នានឹងបានទៅជាបុត្រធីតារបស់
ព្រះបិតាដែលគង់នៅស្ថានបរមសុខ ដ្បិតព្រះអង្គ
ប្រទានឲ្យព្រះអាទិត្យរបស់ព្រះអង្គរះបំភ្លឺទាំងមនុស្ស

អាក្រក់ ទាំងមនុស្សល្អ ហើយទ្រង់ប្រទានទឹកភ្លៀង
ឲ្យទាំងមនុស្សសុចរិត ទាំងមនុស្សទុច្ចរិតផងដែរ។
៤៦ប្រសិនបើអ្នករាល់គ្នាស្រឡាញ់តែអស់អ្នក ដែល
ស្រឡាញ់អ្នករាល់គ្នា តើនឹងទទួលរង្វាន់អ្វី? សូម្បីតែ
អ្នកទារពន្ធ*ក៏ចេះស្រឡាញ់គ្នាគេដែរ។ ៤៧បើអ្នក
រាល់គ្នារាប់រកតែបងប្អូនរបស់ខ្លួនប៉ុណ្ណោះ តើមានអ្វីអ
ស្ចារ្យ? សូម្បីតែសាសន៍ដទៃក៏ប្រព្រឹត្តដូច្នោះដែរ។
៤៨ព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរម
សុខ ទ្រង់គ្រប់លក្ខណ៍យ៉ាងណា សុំឲ្យអ្នករាល់គ្នា
បានគ្រប់លក្ខណ៍យ៉ាងនោះដែរ»។

## ការធ្វើទានដល់ជនក្រីក្រ

៦ ១«កុំធ្វើបុណ្យទាន[ឃ] នៅមុខមនុស្សម្នា ដើម្បីឲ្យតែ
គេឃើញនោះឡើយ។ ធ្វើបែបនេះអ្នករាល់គ្នាពុំបាន
ទទួលរង្វាន់អ្វី ពីព្រះបិតារបស់អ្នករាល់គ្នា ដែលគង់
នៅស្ថានបរមសុខ*ទេ។ ២ពេលណាអ្នកធ្វើទានដល់
ជនក្រីក្រ កុំស្រែកប្រកាសក្អេងៗដូចពួកមានពុតតែង
ធ្វើនៅក្នុងធម្មសាលា* ឬនៅតាមដងផ្លូវ ដើម្បីឲ្យ
មនុស្សម្នាកោតសរសើរនោះឡើយ។ ខ្ញុំសុំប្រាប់អ្នក
រាល់គ្នាឲ្យដឹងច្បាស់ថា អ្នកទាំងនោះបានទទួលរង្វាន់
របស់គេហើយ។ ៣រីឯអ្នកវិញ កាលណាដៃស្ដាំអ្នកធ្វើ
ទានមិនបាច់ឲ្យដៃឆ្វេងដឹងឡើយ ៤ដើម្បីឲ្យទានរបស់
អ្នកនៅស្ងាត់កំបាំង ហើយព្រះបិតារបស់អ្នកទត
ឃើញអំពើ ដែលអ្នកធ្វើ នៅក្នុងទីស្ងាត់កំបាំង ទ្រង់
នឹងប្រទានរង្វាន់មកអ្នកវិញ»។

## ព្រះបន្ទូលអំពីការអធិស្ឋាន

(លូកា ១១.២-៤)

៥«កាលណាអ្នករាល់គ្នាអធិស្ឋាន* កុំធ្វើដូចពួក
អ្នកមានពុត ដែលចូលចិត្តឈរអធិស្ឋាននៅក្នុងធម្ម
សាលា*និងនៅត្រង់ថ្នល់កែង ដើម្បីឲ្យមនុស្សម្នា
ឃើញនោះឡើយ។ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹង
ច្បាស់ថា ពួកទាំងនោះបានទទួលរង្វាន់របស់គេហើ
យ។ ៦រីឯអ្នកវិញ កាលណាអ្នកអធិស្ឋានត្រូវចូលទៅ
ក្នុងបន្ទប់បិទទ្វារឲ្យជិត ហើយទូលទៅកាន់ព្រះបិតា
របស់អ្នក ដែលគង់នៅក្នុងទីស្ងាត់កំបាំង។ព្រះបិតា
របស់អ្នកដែលទតឃើញ នៅក្នុងទីស្ងាត់កំបាំង ទ្រង់
នឹងប្រទានរង្វាន់មកអ្នកជាពុំខាន។ ៧ពេលទូលទៅ
ព្រះបិតា កុំពោលពាក្យច្រំដែលៗ ឥតប្រយោជន៍ដូច
សាសន៍ដទៃនោះឡើយ។ គេនឹកស្មានថា បើពោល
ពាក្យយ៉ាងច្រើនដូច្នេះព្រះរបស់គេនឹងស្ដាប់គេ។ ៨កុំ
ធ្វើដូចគេឡើយ ដ្បិតព្រះបិតារបស់អ្នករាល់គ្នាជ្រាប
នូវអ្វីៗ ដែលអ្នករាល់គ្នាត្រូវការមុនអ្នករាល់គ្នាទូល
សូមព្រះអង្គទៅទៀត។ ៩អ្នករាល់គ្នាត្រូវទូលព្រះអង្គ
ដូចតទៅ៖

ឱព្រះបិតានៃយើងខ្ញុំ
ដែលគង់នៅស្ថានបរមសុខ*អើយ!
១០ សូមសម្ដែងព្រះបារមីឲ្យមនុស្សលោក
ស្គាល់ព្រះនាមព្រះអង្គ
សូមឲ្យព្រះរាជ្យ*ព្រះអង្គបានមកដល់
សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ
បានសម្រេចនៅលើផែនដី
ដូចនៅស្ថានបរមសុខដែរ។
១១ សូមប្រទានអាហារ
ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។
១២ សូមអត់ទោសឲ្យយើងខ្ញុំ
ដូចយើងខ្ញុំអត់ទោសឲ្យ
អស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។
១៣ សូមកុំបណ្ដោយឲ្យយើងខ្ញុំ
ចាញ់ការល្បួងឡើយ
តែសូមរំដោះយើងខ្ញុំឲ្យរួចពីមារ*កំណាច
{ដ្បិតព្រះអង្គគ្រងរាជ្យ
ទ្រង់មានឫទ្ធានុភាពនិងសិរីរុងរឿង
អស់កល្បជាអង្វែងតរៀងទៅ។
អាម៉ែន។}

១៤បើអ្នករាល់គ្នាអត់ទោសឲ្យមនុស្សលោក
ព្រះបិតារបស់អ្នករាល់គ្នានៅស្ថានបរមសុខ* ក៏អត់
ទោសឲ្យអ្នករាល់គ្នាដែរ។ ១៥ប៉ុន្តែបើអ្នករាល់គ្នាមិន
អត់ទោសឲ្យមនុស្សលោកទេនោះ ព្រះបិតារបស់អ្នក
រាល់គ្នាក៏មិនអត់ទោសឲ្យអ្នករាល់គ្នាដែរ»។

### ការតមអាហារ

១៦«កាលណាអ្នករាល់គ្នាតមអាហារ កុំធ្វើមុខ
ក្រៀមដូចពួកអ្នកមានពុតនោះឡើយ។ ពួកគេបង្ហាញ
ទឹកមុខឲ្យអ្នកដទៃឃើញថា ខ្លួនតមអាហារ។ ខ្ញុំសុំ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកទាំងនោះបាន
ទទួលរង្វាន់របស់គេហើយ។ ១៧រីឯអ្នកវិញ កាលណា
អ្នកតមអាហារ ត្រូវលាបទឹកអប់លើក្បាលហើយលុប
មុខផង ១៨កុំឲ្យមនុស្សម្នាឃើញថា អ្នកតមឡើយ គឺ
ឲ្យតែព្រះបិតារបស់អ្នកដែលគង់នៅក្នុងទីស្ងាត់កំបាំង
ទតឃើញប៉ុណ្ណោះ ពេលនោះព្រះបិតារបស់អ្នក
ដែលទតឃើញនៅក្នុងទីស្ងាត់កំបាំងនឹងប្រទានរង្វាន់
មកអ្នកជាមិនខាន»។

### អំពីសម្បត្តិសួគ៌

(លូកា ១២.៣៣-៣៤)

១៩«កុំសន្សំទ្រព្យសម្បត្តិទុកសម្រាប់ខ្លួន នៅ
លើផែនដីជាកន្លែងដែលមានកណ្ដៀរ និងច្រែះស៊ីជា
កន្លែងដែលមានចោរទម្លាយជញ្ជាំង ចូលមកលួចប្លន់
នោះឲ្យសោះ។ ២០ចូរប្រមូលទ្រព្យសម្បត្តិទុកនៅ
ស្ថានបរមសុខ*វិញ ជាស្ថានដែលគ្មានកណ្ដៀរនិង
ច្រែះស៊ី ជាស្ថានដែលគ្មានចោរទម្លាយជញ្ជាំងចូល
មកលួចប្លន់ឡើយ ២១ដ្បិតទ្រព្យសម្បត្តិអ្នកនៅកន្លែង
ណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ»។

### ពាក្យប្រស្នាអំពីចង្កៀង

(លូកា ១១.៣៤-៣៦)

២២«ភ្នែកប្រៀបបាននឹងចង្កៀងរបស់រូបកាយ
បើភ្នែកអ្នកនៅភ្លឺល្អ រូបកាយអ្នកទាំងមូលក៏ភ្លឺដែរ ២៣
តែបើភ្នែកអ្នកងងឹតវិញ រូបកាយអ្នកទាំងមូលក៏ងងឹត
ដែរ។ ប្រសិនបើពន្លឺនៅក្នុងអ្នកត្រឡប់ទៅជាងងឹត
ប៉ុណ្ណឹងទៅហើយ នោះមិនដឹងជាសេចក្ដីងងឹតនឹងទៅ
ជាសូន្យសុងដល់កម្រិតណាទៀតទេ»។

### ត្រូវពឹងផ្អែកលើព្រះជាម្ចាស់

(លូកា ១៦.១៣; ១២.២២-៣១)

២៤«គ្មានអ្នកណាម្នាក់ អាចបម្រើម្ចាស់ពីរបាន
ទេ ព្រោះអ្នកនោះនឹងស្អប់មួយ ស្រឡាញ់មួយ ស្មោះ
ត្រង់នឹងម្នាក់ មើលងាយម្នាក់ទៀតជាពុំខាន។ អ្នក
រាល់គ្នាក៏ពុំអាចគោរពបម្រើព្រះជាម្ចាស់ផង ហើយ
គោរពបម្រើទ្រព្យសម្បត្តិ ទុកជាព្រះផងបានឡើយ»
។

២៥«ហេតុនេះហើយ បានជាខ្ញុំសុំប្រាប់អ្នករាល់
គ្នាកុំឲ្យខ្វល់ខ្វាយ អំពីម្ហូបអាហារសម្រាប់ចិញ្ចឹមជីវិត
ឬសម្លៀកបំពាក់សម្រាប់បិទបាំងកាយឡើយ។ ជីវិត
មានតម្លៃលើសម្ហូបអាហារ ហើយរូបកាយក៏មានតម្លៃ
លើសសម្លៀកបំពាក់ទៅទៀត។ ២៦ចូររំពៃមើលបក្សា
បក្សីនៅលើមេឃ វាមិនដែលសាបព្រោះមិនដែល
ច្រូតកាត់ មិនដែលប្រមូលស្រូវដាក់ជង្រុកឡើយ
ប៉ុន្តែព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរម
សុខ* ទ្រង់ចិញ្ចឹមវា។ រីឯអ្នករាល់គ្នា អ្នករាល់គ្នាមាន
តម្លៃលើសបក្សាបក្សី ទាំងនោះទៅទៀត។ ២៧ក្នុង
ចំណោមអ្នករាល់គ្នា ទោះបីខំខ្វល់ខ្វាយយ៉ាងណាក៏
ដោយក៏គ្មាននរណាអាចនឹងបង្កើនអាយុរបស់ខ្លួនឲ្យ
វែងបានដែរ សូម្បីតែបន្តិចក៏មិនបានផង។

២៨ហេតុដូចម្ដេច បានជាអ្នករាល់គ្នាខ្វល់ខ្វាយ
អំពីសម្លៀកបំពាក់? ចូរសង្កេតមើលផ្កានៅតាមវាល
វាដុះឡើងយ៉ាងណា។ វាមិនដែលធ្វើការនឿយហត់ឬ
ត្បាញរវៃឡើយ ២៩ប៉ុន្តែ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា សូ
ម្បីតែព្រះបាទសាឡូម៉ូន កាលពីជំនាន់ដែលទ្រង់មាន

សិរីរុងរឿងដ៏ប្រសើរបំផុតនោះក៏ដោយ ក៏ទ្រង់គ្មាន
ព្រះភូសាល្អ ស្មើនឹងផ្កាមួយទងនេះផង។ ៣០ មនុស្ស
មានជំនឿតិចអើយ! ប្រសិនបើព្រះជាម្ចាស់ផ្តល់
សម្រស់ឲ្យផ្កា ដែលរីកនៅតាមវាលថ្ងៃនេះ តែថ្ងៃ
ស្អែកត្រូវគេដុតចោល យ៉ាងហ្នឹងទៅហើយ តើព្រះអង្គ
នឹងទំនុកបម្រុងអ្នករាល់គ្នាលើសនេះយ៉ាងណាទៅ
ទៀត?។ ៣១ហេតុនេះកុំខ្វល់ខ្វាយដោយពោលថា
"យើងនឹងមានអ្វីបរិភោគមានអ្វីស្លៀកពាក់?" នោះ
ឡើយ ៣២ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះទេ ដែល
ខំស្វះស្វែងរករបស់ទាំងនោះ។ រីឯព្រះបិតាដែលគង់
នៅស្ថានបរមសុខ ទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នា
ត្រូវការ។ ៣៣ចូរស្វែងរកព្រះរាជ្យ*របស់ព្រះជាម្ចាស់
និងសេចក្តីសុចរិត*របស់ព្រះអង្គជាមុនសិន ទើបព្រះ
អង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត។
៣៤កុំខ្វល់ខ្វាយអំពីហេតុការណ៍ ដែលនឹងកើតមាន
នៅថ្ងៃស្អែកឡើយ ចាំស្អែកសឹមគិតពីរឿងថ្ងៃស្អែក
ទៅ!បើមានការលំបាកកើតឡើងនៅថ្ងៃណា ត្រូវដោះ
ស្រាយសម្រាប់តែថ្ងៃនោះបានហើយ»។

## កុំថ្កោលទោសអ្នកដទៃ

(លូកា៦.៣៧-៣៨, ៤១-៤២)

៧ ១«កុំថ្កោលទោសអ្នកដទៃឲ្យសោះ ដើម្បីកុំឲ្យ ព្រះ
ជាម្ចាស់ថ្កោលទោសអ្នករាល់គ្នា ២បើអ្នករាល់គ្នា
ថ្កោលទោសគេយ៉ាងណា ព្រះជាម្ចាស់ក៏នឹងថ្កោល
ទោសអ្នករាល់គ្នា យ៉ាងនោះដែរ។ ព្រះអង្គនឹងវាល់
ឲ្យអ្នករាល់គ្នា តាមរង្វាល់ដែលអ្នករាល់គ្នាវាល់ឲ្យអ្នក
ដទៃ។ ៣ ហេតុអ្វីបានជាអ្នកមើលឃើញល្អងធូលីនៅ
ក្នុងភ្នែកបងប្អូន តែមើលមិនឃើញធ្នឹមនៅក្នុងភ្នែក
របស់អ្នកដូច្នេះ? ៤បើមានធ្នឹមនៅក្នុងភ្នែករបស់អ្នក
ម្តេចក៏អ្នកនិយាយទៅបងប្អូនថា "ទុកឲ្យខ្ញុំផ្តិតយក
ល្អងធូលី ចេញពីភ្នែកអ្នក"! ៥ មនុស្សមានពុតអើយ!
ចូរយកធ្នឹមចេញពីភ្នែកអ្នកជាមុនសិន ទើបអ្នកមើល
ឃើញច្បាស់ ល្មមនឹងផ្តិតយកល្អងធូលីចេញពីភ្នែក
របស់បងប្អូនអ្នកបាន។

៦កុំយកអ្វីៗដែលជារបស់វិសុទ្ធ* ទៅឲ្យឆ្កែ
ឡើយហើយក៏កុំបោះត្បូងពេជ្ររបស់អ្នករាល់គ្នានៅ
មុខ ជ្រូកដែរ ក្រែងលោវាជាន់ឈ្លី រួចបែរមកត្របាក់
ខាំអ្នករាល់គ្នាវិញ»។

## អំពីរបៀបដែលត្រូវអធិស្ឋាន

(លូកា១១.៩-១៣)

៧«ចូរសុំ នោះព្រះជាម្ចាស់នឹងប្រទានឲ្យអ្នក
រាល់គ្នា ចូរស្វែងរក នោះអ្នករាល់គ្នានឹងបានឃើញ
ចូរគោះទ្វារ នោះព្រះអង្គនឹងបើកឲ្យអ្នករាល់គ្នាជាពុំ
ខាន ៨ដ្បិតអ្នកណាសុំ អ្នកនោះរមែងតែងតែបាន
ទទួល អ្នកណាស្វែងរក អ្នកនោះរមែងតែងតែបាន
ឃើញ ហើយគេតែងតែបើកទ្វារឲ្យអ្នកដែលគោះ។៩
ក្នុងចំណោមអ្នករាល់គ្នា បើកូនសុំនំប៉័ងមិនដែលមាន
នរណាយកដុំថ្មឲ្យវាឡើយ ១០ហើយបើកូនសុំត្រី ក៏
មិនដែលមាននរណាយកពស់អាសិរពិសឲ្យវាដែរ។
១១សូម្បីតែអ្នករាល់គ្នាដែលជាមនុស្សអាក្រក់ក៏ចេះឲ្យ
របស់ល្អៗទៅកូន ចុះចំណង់បើព្រះបិតារបស់អ្នក
រាល់គ្នាដែលគង់នៅស្ថានបរមសុខ* តើព្រះអង្គនឹង
ប្រទានអ្វីៗដ៏ល្អៗ ឲ្យអស់អ្នកដែលទូលសូមពីព្រះអង្គ
យ៉ាងណាទៅទៀត!»។

## ទ្វារចង្អៀត

(លូកា១៣.២៤)

១២«ដូច្នេះ បើអ្នករាល់គ្នាចង់ឲ្យអ្នកដទៃប្រព្រឹត្ត
ចំពោះខ្លួនបែបណា ត្រូវប្រព្រឹត្តចំពោះគេបែបនោះដែ
រ។ ធម្មវិន័យនិងគម្ពីរព្យាការីមានចែងទុកមកដូច្នេះឯ
ង។

១៣ចូរនាំគ្នាចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែល
នាំទៅរកសេចក្តីវិនាសអន្តរាយធំណាស់ ហើយផ្លូវ
ទៅរកសេចក្តីវិនាសក៏ទូលាយដែរ មានមនុស្សជា

ច្រើនចូលតាមទ្វារនោះ។ ១៤រីឯទ្វារដែលនាំទៅរក
ជីវិតចង្អៀតហើយពិបាកដើរផង មានមនុស្សតិចទេ
រកផ្លូវនោះឃើញ»។

## ប្រស្នាអំពីដើមឈើល្អ និងដើមឈើអាក្រក់

(លូកា ៦.៤៣-៤៤)

១៥«ចូរប្រយ័ត្ននឹងពួកព្យាការី*ក្លែងក្លាយ គេ
ក្លែងខ្លួនមករកអ្នករាល់គ្នាដោយពាក់ស្បែកចៀម តែ
គេមានចិត្តសាហាវដូចចចក។ ១៦អ្នករាល់គ្នាអាច
ស្គាល់គេបានតាមអំពើដែលគេប្រព្រឹត្ត។ ពុំដែលមាន
នរណាបេះផ្លែទំពាំងបាយជូរ និងផ្លែឧទុម្ពរ*ពីគុម្ពបន្លា
ឡើយ។ ១៧ដើមឈើល្អតែងផ្ដល់ផ្លែល្អរីឯដើមឈើ
អាក្រក់តែងផ្ដល់ផ្លែអាក្រក់។ ១៨ដើមឈើល្អមិនអាច
ផ្ដល់ផ្លែអាក្រក់ទេ រីឯដើមឈើអាក្រក់ក៏មិនអាចផ្ដល់
ផ្លែល្អបានដែរ។ ១៩ដើមឈើណាមិនផ្ដល់ផ្លែល្អ គេ
នឹងកាប់យកទៅដុត។ ២០រីឯពួកព្យាការីក្លែងក្លាយក៏
ដូច្នោះដែរអ្នករាល់គ្នាអាចស្គាល់គេបានតាមអំពើ
ដែលគេប្រព្រឹត្ត»។

## សាវ័កដ៏ពិតប្រាកដ

(លូកា ១៣.២៥-២៧)

២១«អ្នកដែលចូល ទៅក្នុងព្រះរាជ្យ*នៃស្ថាន
បរមសុខ* មិនមែនជាអ្នកដែលគ្រាន់តែហៅខ្ញុំថា
"ព្រះអម្ចាស់! ព្រះអម្ចាស់!"ប៉ុណ្ណោះទេ គឺជាអ្នកដែល
ធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅ
ស្ថានបរមសុខនោះវិញ។ ២២នៅថ្ងៃនោះនឹងមាន
មនុស្សជាច្រើនពោលមកខ្ញុំថា "ព្រះអម្ចាស់ ព្រះ
អម្ចាស់អើយ! យើងខ្ញុំធ្លាប់ថ្លែងព្រះបន្ទូលក្នុងព្រះនាម
ព្រះអង្គយើងខ្ញុំធ្លាប់ដេញខ្មោច ក្នុងព្រះនាមព្រះអង្គ
ហើយយើងខ្ញុំក៏ធ្លាប់ធ្វើការអស្ចារ្យជាច្រើនក្នុងព្រះ
នាមព្រះអង្គដែរ"។ ២៣ពេលនោះខ្ញុំនឹងប្រកាសប្រាប់
អ្នករាល់គ្នាថា "ពួកអ្នកប្រព្រឹត្តអំពើទុច្ចរិតអើយ! ចូរ
ថយចេញឲ្យឆ្ងាយពីខ្ញុំទៅខ្ញុំមិនដែលស្គាល់អ្នករាល់
គ្នាទេ!"[៧]»។

## ប្រស្នាអំពីមនុស្សពីរនាក់សង់ផ្ទះ

(លូកា ៦.៤៦-៤៩)

២៤«អ្នកណាស្ដាប់ពាក្យខ្ញុំនេះ ហើយប្រព្រឹត្ត
តាមអ្នកនោះប្រៀបបាន ទៅនឹងមនុស្សឈ្លាសវៃម្នាក់
ដែលបានសង់ផ្ទះរបស់ខ្លួននៅលើផ្ទាំងថ្ម។ ២៥ទោះបី
ភ្លៀងបង្អុរចុះមក ហើយមានទឹកជន់មានខ្យល់បក់
បោកប៉ះនឹងផ្ទះនោះ យ៉ាងណាក៏ដោយក៏ផ្ទះនោះមិន
រលំដែរ ព្រោះមានគ្រឹះនៅលើផ្ទាំងថ្ម។២៦រីឯអ្នកដែល
ស្ដាប់ពាក្យខ្ញុំនេះ តែមិនប្រព្រឹត្តតាមប្រៀបបានទៅ
នឹងមនុស្សឆោតល្ងង់ម្នាក់ ដែលបានសង់ផ្ទះរបស់ខ្លួន
នៅលើដីខ្សាច់ ២៧ពេលភ្លៀងបង្អុរចុះមក ហើយមាន
ទឹកជន់មានខ្យល់បក់បោកប៉ះនឹងផ្ទះនោះ ផ្ទះនោះ
រលំបាក់បែកខ្ទេចអស់គ្មានសល់»។

២៨កាលព្រះយេស៊ូមានព្រះបន្ទូលទាំងនេះ ចប់
សព្វគ្រប់ហើយ មហាជនងឿងឆ្ងល់យ៉ាងខ្លាំងអំពី
សេចក្ដីដែលព្រះអង្គប្រៀនប្រដៅ ២៩ព្រោះព្រះអង្គ
មានព្រះបន្ទូលប្រកបដោយអំណាច ខុសប្លែកពីពួកធ
ម្មាចារ្យ*របស់ពួកគេ។

## ព្រះយេស៊ូប្រោស មនុស្សឃ្លង់ម្នាក់ឲ្យបានជា

(ម៉ាកុស ១.៤០-៤៥ លូកា ៥.១២-១៤)

៨ ១កាលព្រះយេស៊ូយាងចុះពីលើភ្នំមកវិញ មានមហា
ជនជាច្រើន នាំគ្នាដើរតាមព្រះអង្គ។ ២ ពេលនោះ
មានមនុស្សឃ្លង់ម្នាក់ ចូលមកក្រាបថ្វាយបង្គំព្រះអង្គ
ទូលថា៖ «លោកម្ចាស់អើយ!ប្រសិនបើលោកមិន
យល់ទាស់ទេ សូមប្រោសខ្ញុំប្របាទឲ្យជាស្អាត
បរិសុទ្ធ*ផង»។ ៣ព្រះយេស៊ូលូកព្រះហស្ដទៅពាល់
គាត់ ទាំងមានព្រះបន្ទូលថា៖ «ខ្ញុំយល់ព្រមហើយ

ចូរឲ្យបានជាស្អាតបរិសុទ្ធចុះ»។រំពេចនោះ គាត់ក៏បានជាស្អាតបរិសុទ្ធពីរោគឃ្លង់ភ្លាម។ ៤ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ចូរប្រយ័ត្នឲ្យមែនទែន កុំនិយាយប្រាប់ឲ្យនរណាដឹងរឿងនេះឡើយ ផ្ទុយទៅវិញត្រូវទៅបង្ហាញខ្លួនដល់លោកបូជាចារ្យ* ហើយថ្វាយតង្វាយដូចលោកម៉ូសេ* បានបង្គាប់មក ដើម្បីជាសក្ខីភាពបញ្ជាក់ថាអ្នកបានជាមែន»។

## ព្រះយេស៊ូប្រោសអ្នកបម្រើរបស់នាយទាហានរ៉ូម៉ាំងឲ្យបានជា

(លូកា ៧.១-១០)

៥នៅពេលព្រះយេស៊ូយាង ចូលក្រុងកាផានុម មាននាយទាហានរ៉ូម៉ាំងម្នាក់ ចូលមកគាល់ព្រះអង្គ ទូលអង្វរថា៖ ៦«លោកម្ចាស់អើយ! អ្នកបម្រើរបស់ខ្ញុំប្របាទដេកស្ដូកស្ដឹង នៅឯផ្ទះទាំងឈឺចុកចាប់យ៉ាងខ្លាំង»។ ៧ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំនឹងទៅមើលគាត់ឲ្យបានជា»។ ៨នាយទាហានទូលព្រះអង្គថា៖ «លោកម្ចាស់ខ្ញុំប្របាទមានឋានៈទន់ទាបណាស់ មិនសមនឹងលោកអញ្ជើញចូលក្នុងផ្ទះខ្ញុំប្របាទទេ សូមលោកមានប្រសាសន៍តែមួយម៉ាត់ប៉ុណ្ណោះ អ្នកបម្រើរបស់ខ្ញុំប្របាទនឹងជាសះស្បើយមិនខាន។ ៩ខ្ញុំប្របាទជាអ្នកនៅក្រោមបញ្ជាគេ ហើយមានកូនទាហាន នៅក្រោមបញ្ជាខ្ញុំប្របាទដែរបើខ្ញុំប្របាទបញ្ជាអ្នកណាម្នាក់ឲ្យទៅ គេនឹងទៅ បើប្រាប់ម្នាក់ទៀតឲ្យមក គេនឹងមក។ ពេលខ្ញុំប្របាទប្រាប់អ្នកបម្រើឲ្យធ្វើការអ្វីមួយ គេនឹងធ្វើតាម»។ ១០ កាលព្រះយេស៊ូទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ ព្រះអង្គស្ងើចសរសើរណាស់ ក៏មានព្រះបន្ទូលទៅកាន់អស់អ្នកដែលដើរតាមព្រះអង្គថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ខ្ញុំមិនដែលឃើញនរណាមានជំនឿបែបនេះ នៅស្រុកអ៊ីស្រាអែលឡើយ។ ១១ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា នឹងមានមនុស្សជាច្រើនពីទិសខាងកើត និងទិសខាងលិចមកចូលរួមពិធីជប់លៀង ក្នុងព្រះរាជ្យ*នៃស្ថានបរមសុខ*ជាមួយលោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប។ ១២រីឯអស់អ្នកដែលត្រូវចូលក្នុងព្រះរាជ្យព្រះជាម្ចាស់ បែរជាដេញឲ្យទៅនៅខាងក្រៅ ក្នុងទីងងឹតជាកន្លែងដែលគេយំសោកខឹងសង្កៀតធ្មេញ»។ ១៣បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូល ទៅនាយទាហានរ៉ូម៉ាំងថា៖ « អញ្ជើញត្រឡប់ទៅវិញទៅ សុំឲ្យបានសម្រេចតាមជំនឿរបស់លោកចុះ!»។ អ្នកបម្រើក៏បានជាសះស្បើយនៅពេលនោះ។

## ព្រះយេស៊ូប្រោសអ្នកជំងឺជាច្រើនឲ្យបានជា

(ម៉ាកុស ១.២៩-៣៤ លូកា ៤.៣៨-៤១)

១៤បន្ទាប់មកទៀត ព្រះយេស៊ូយាងទៅផ្ទះលោកសិលា ទតឃើញម្ដាយក្មេករបស់គាត់កំពុងគ្រុន សម្រាន្តនៅលើគ្រែ។ ១៥ ព្រះអង្គពាល់ដៃគាត់ គាត់ក៏បាត់គ្រុន ហើយក្រោកឡើងបម្រើព្រះអង្គ។

១៦លុះដល់ល្ងាច គេនាំមនុស្សខ្មោចចូលជាច្រើននាក់មករកព្រះអង្គ ព្រះអង្គក៏ដេញខ្មោចដោយមានព្រះបន្ទូល ហើយប្រោសអ្នកជំងឺឲ្យបានជាគ្រប់ៗគ្នា ១៧ស្របនឹងសេចក្ដីដែលមានចែងទុកតាមរយៈព្យាការី*អេសាយថា៖

*«ព្រះអង្គបានទទួលយកភាពពិការរបស់យើង ហើយព្រះអង្គក៏ទទួលយកជំងឺរបស់យើងដែរ»*[១]។

## លក្ខណសម្បត្តិរបស់អ្នកដែលចង់តាមព្រះយេស៊ូ

(លូកា ៩.៥៧-៦២)

១៨កាល ព្រះយេស៊ូ ឃើញបណ្ដាជនចោមរោមព្រះអង្គ ទ្រង់ក៏បញ្ជាឲ្យគេចេញទូកទៅត្រើយម្ខាង។ ១៩ពេលនោះ មានធម្មាចារ្យ*ម្នាក់ចូលមកជិតព្រះអង្គ

ទូលថា៖ «លោកគ្រូ! ខ្ញុំប្របាទសុខចិត្តទៅតាមលោក ទោះបីលោកអញ្ជើញទៅទីណាក៏ដោយ»។ ២០ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់វិញថា៖ «សត្វកញ្ជ្រោងមានរូងរបស់វា បក្សាបក្សីក៏មានសំបុករបស់វាដែរ រីឯបុត្រមនុស្សវិញ គ្មានទីជម្រកសម្រាកសោះឡើយ»។ ២១មានសាវ័កមួយរូបទៀតទូលព្រះអង្គថា៖ «លោកម្ចាស់ សូមលោកអនុញ្ញាតឲ្យខ្ញុំប្របាទត្រឡប់ ទៅបញ្ចុះសពឪពុកសិន»។ ២២ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «សុំអញ្ជើញមកតាមខ្ញុំទុកឲ្យមនុស្សស្លាប់បញ្ចុះសពគ្នាគេចុះ»។

## ព្រះយេស៊ូធ្វើឲ្យរលកស្ងប់

(ម៉ាកុស ៤.៣៥-៤១ លូកា ៨.២២-២៥)

២៣ព្រះយេស៊ូយាងចុះទូក ហើយពួកសាវ័ក*នាំគ្នាទៅជាមួយព្រះអង្គដែរ។ ២៤ពេលនោះ មានខ្យល់ព្យុះបក់បោក មកលើសមុទ្រយ៉ាងខ្លាំងបណ្ដាលឲ្យរលកជះមកគ្របពីលើទូក។ រីឯព្រះយេស៊ូវិញ ទ្រង់ផ្ទំលក់។ ២៥ពួកសាវ័ក*ចូលទៅជិតដាស់ព្រះអង្គថា៖ «លោកម្ចាស់អើយ! សូមជួយផងយើងស្លាប់ឥឡូវហើយ»។ ២៦ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «មនុស្សមានជំនឿតិចអើយ! ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យដូច្នេះ?»។ ព្រះអង្គក្រោកឈរឡើង មានព្រះបន្ទូលគំរាមខ្យល់ព្យុះនិងសមុទ្រពេលនោះសមុទ្រក៏ស្ងប់ឈឹង។ ២៧ពួកសាវ័កនាំគ្នាស្ងើចសរសើរ ហើយពោលថា៖ «តើលោកនេះមានឋានៈអ្វី បានជាខ្យល់ព្យុះនិងសមុទ្រស្ដាប់បង្គាប់លោកដូច្នេះ?»។

## ព្រះយេស៊ូប្រោសបុរសខ្មោចចូលពីរនាក់

(ម៉ាកុស ៥.១-២០ លូកា ៨.២៦-៣៩)

២៨កាលព្រះយេស៊ូនិងពួកសាវ័ក បានទៅដល់ត្រើយម្ខាង ក្នុងតំបន់កាដារ៉ា មានបុរសខ្មោចចូលពីរនាក់ចេញពីទីបញ្ចុះសព ដើរតម្រង់មករកព្រះអង្គ។ បុរសទាំងពីរនេះកាចណាស់ គ្មាននរណាហ៊ានដើរកាត់តាមនោះទេ។ ២៩អ្នកទាំងពីរស្រែកឡើងថា៖ «ព្រះបុត្រារបស់ព្រះជាម្ចាស់អើយ! តើព្រះអង្គចង់ធ្វើអ្វីយើងខ្ញុំ? ព្រះអង្គយាងមកទីនេះដើម្បីធ្វើទុក្ខទោសយើងខ្ញុំ មុនពេលកំណត់ឬ?»។ ៣០នៅឆ្ងាយពីនោះបន្តិច មានជ្រូកមួយហ្វូងធំកំពុងរកស៊ី។ ៣១ពួកខ្មោចអង្វរព្រះយេស៊ូថា៖ «បើព្រះអង្គចង់ដេញយើងខ្ញុំសូមបញ្ជូនយើងខ្ញុំឲ្យចូលទៅក្នុងជ្រូកមួយហ្វូងនេះទៅ»។ ៣២ព្រះយេស៊ូមានព្រះបន្ទូលទៅខ្មោចថា៖ «ទៅចុះ!»។ ពួកខ្មោចក៏ចេញពីបុរសទាំងពីរចូលទៅក្នុងជ្រូក។ ពេលនោះហ្វូងជ្រូកបោលចុះតាមជម្រាលភ្នំតម្រង់ទៅសមុទ្រ លង់ទឹកងាប់អស់ទៅ។ ៣៣អ្នកថែរក្សាហ្វូងជ្រូក នាំគ្នាយករឿងអស់ទាំងនេះ រត់ទៅប្រាប់អ្នកភូមិ ព្រមទាំងរៀបរាប់ហេតុការណ៍ អំពីបុរសខ្មោចចូលទាំងពីរនាក់នោះផង។ ៣៤អ្នកភូមិទាំងអស់ក៏នាំគ្នា ចេញមកជួបព្រះយេស៊ូ លុះបានឃើញហើយ គេអង្វរព្រះអង្គឲ្យចាកចេញពីស្រុកភូមិរបស់គេ។

## ព្រះយេស៊ូប្រោស មនុស្សខ្វិនម្នាក់ឲ្យដើររួច

(ម៉ាកុស ២.១-១២ លូកា ៥.១៧-២៦)

៩ ១បន្ទាប់មក ព្រះយេស៊ូយាងចុះទូកឆ្លងសមុទ្រទៅក្រុង[ល]របស់ព្រះអង្គវិញ។ ២ពេលនោះមានគេសែងមនុស្សខ្វិនដៃ ខ្វិនជើងម្នាក់មករកព្រះអង្គ។ព្រះយេស៊ូឈ្វេងយល់ជំនឿរបស់អ្នកទាំងនោះ ព្រះអង្គក៏មានព្រះបន្ទូលទៅកាន់អ្នកពិការថា៖ «កូនអើយ! ចូរក្លាហានឡើង ខ្ញុំអត់ទោសឲ្យអ្នកបានរួចពីបាប* ហើយ!»។ ៣ពួកធម្មាចារ្យ*ខ្លះឮដូច្នេះក៏នឹកក្នុងចិត្តថា៖ «អ្នកនេះប្រមាថព្រះជា ម្ចាស់!»។ ៤ព្រះយេស៊ូឈ្វេងយល់គំនិតអ្នកទាំងនោះ ទើបទ្រង់មានព្រះបន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាមានគំនិត

អាក្រក់បែបនេះ? ៥បើខ្ញុំនិយាយថា "ខ្ញុំអត់ទោសឲ្យអ្នកបានរួចពីបាបហើយ" ឬថា "ចូរក្រោកឡើងដើរទៅចុះ"តើឃ្លាមួយណាស្រួលនិយាយជាង? ៦ប៉ុន្តែខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា បុត្រមនុស្សមានអំណាចអត់ទោសឲ្យមនុស្សនៅក្នុងលោកនេះបានរួចពីបាប»។ ព្រះអង្គក៏មានព្រះបន្ទូលទៅអ្នកខ្វិនថា៖ «ចូរក្រោកឡើងយកគ្រែស្នែងរបស់អ្នក ដើរទៅផ្ទះវិញទៅ!»។ ៧អ្នកខ្វិនក៏ក្រោកឡើងដើរត្រឡប់ទៅផ្ទះវិញ។ ៨កាលមហាជនបានឃើញដូច្នេះ គេស្ញែងខ្លាចជាខ្លាំងទាំងនាំគ្នាលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ ដែលបានប្រោសប្រទានអំណាចដ៏អស្ចារ្យយ៉ាងនេះ ដល់មនុស្សលោក។

## ព្រះយេស៊ូត្រាស់ហៅលោកម៉ាថាយ

(ម៉ាកុស២.១៣-១៧ លូកា៥.២៧-៣២)

៩កាលព្រះយេស៊ូយាងពីទីនោះ ទៅមុខបន្តិច ព្រះអង្គទតឃើញបុរសម្នាក់ ឈ្មោះម៉ាថាយអង្គុយនៅកន្លែងយកពន្ធ*។ ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «សុំអញ្ជើញមកតាមខ្ញុំ»។ គាត់ក៏ក្រោកឡើងដើរតាមព្រះអង្គទៅ។

១០បន្ទាប់មក ព្រះអង្គសោយព្រះស្ងោយនៅផ្ទះលោកម៉ាថាយ មានអ្នកទារពន្ធ ព្រមទាំងមនុស្សបាបជាច្រើន មកអង្គុយរួមតុជាមួយព្រះយេស៊ូ និងពួកសាវ័កដែរ។ ១១ពួកខាងគណៈផារីស៊ី*ឃើញដូច្នេះ គេនិយាយទៅកាន់សាវ័ករបស់ព្រះអង្គថា៖ «ហេតុអ្វីបានជា គ្រូរបស់អ្នករាល់គ្នាបរិភោគជាមួយអ្នកទារពន្ធនិងមនុស្សបាប?»។ ១២ព្រះយេស៊ូឮដូច្នេះក៏មានព្រះបន្ទូលថា៖ «មនុស្សសុខភាពល្អមិនត្រូវការគ្រូពេទ្យទេ មានតែអ្នកជំងឺប៉ុណ្ណោះដែលត្រូវការ។ ១៣ ចូរអ្នករាល់គ្នាទៅរិះគិតមើល សេចក្ដីដែលមានចែងទុកមកថា៖ "យើងមិនចង់បានយញ្ញបូជាទេ គឺចង់បានតែសេចក្ដីមេត្តាករុណាប៉ុណ្ណោះ"[ហ] មានន័យដូចម្ដេច? ខ្ញុំមិនមែនមករកមនុស្សសុចរិតទេ គឺមករកមនុស្សបាប»។

## អំពីការតមអាហារ

(ម៉ាកុស២.១៨-២២ លូកា៥.៣៣-៣៨)

១៤ពេលនោះ ពួកសិស្សរបស់លោកយ៉ូហានចូលមកគាល់ព្រះអង្គ ហើយទូលថា៖ «យើងខ្ញុំនិងពួកខាងគណៈផារីស៊ី*តមអាហារ ចុះហេតុដូចម្ដេចបានជាសិស្សរបស់លោកមិនតមដូច្នេះ?»។ ១៥ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយទៅគេវិញថា៖ «ក្នុងពិធីមង្គលការ ពេលកូនកំឡោះនៅជាមួយ តើភ្ញៀវអាចកាន់ទុក្ខកើតឬ? ទេ!។ ថ្ងៃក្រោយពេលគេចាប់ស្វាមីយកទៅ ទើបភ្ញៀវទាំងនោះតមអាហារវិញ។

១៦ពុំដែលមាននរណាយកក្រណាត់ថ្មី មកប៉ះសម្លៀកបំពាក់ចាស់ឡើយ ដ្បិតបំណះនឹងធ្វើឲ្យសម្លៀកបំពាក់នោះ រហែកលើសដើមទៅទៀត។ ១៧ ពុំដែលមាននរណា ច្រកស្រាទំពាំងបាយជូរថ្មីទៅក្នុងថង់ស្បែកចាស់ដែរ បើធ្វើដូច្នេះថង់ស្បែកមុខជាធ្លាយ ស្រានឹងហូរចេញហើយ ថង់ស្បែកត្រូវខូចខាតមិនខាន។ គេតែងតែច្រកស្រាថ្មីទៅក្នុងថង់ស្បែកថ្មីទើបទាំងស្រាទាំងថង់ស្បែកនៅគង់បាន»។

## ព្រះយេស៊ូប្រោសស្ត្រីមានជំងឺធ្លាក់ឈាមឲ្យបានជានិងប្រោសកូនស្រីលោកយ៉ៃរ៉ូសឲ្យរស់ឡើងវិញ

(ម៉ាកុស៥.២១-៤៣ លូកា៨.៤០-៥៦)

១៨កាល ព្រះយេស៊ូ កំពុងតែមានព្រះបន្ទូលទាំងនេះទៅគេ មាននាម៉ឺនម្នាក់ចូលមកក្រាបថ្វាយបង្គំព្រះអង្គទូលថា៖ «កូនស្រីរបស់ខ្ញុំប្របាទទើបនឹងផុតដង្ហើមថ្មីៗនេះ សូមលោកមេត្តាអញ្ជើញទៅដាក់ដៃ*លើនាង នាងនឹងមានជីវិតរស់ពុំខាន»។ ១៩ព្រះយេស៊ូក្រោកឡើង យាងទៅជាមួយគាត់ពួកសាវ័ក*ក៏

ទៅជាមួយដែរ។

២០មានស្ត្រីម្នាក់កើតជំងឺធ្លាក់ឈាមដប់ពីរឆ្នាំមកហើយ នាងមកពីក្រោយព្រះយេស៊ូ ហើយពាល់ជាយព្រះពស្ត្រព្រះអង្គ ២១ដ្បិតនាងរិះគិតក្នុងចិត្តថា «បើខ្ញុំគ្រាន់តែបានពាល់អាវលោក ខ្ញុំមុខជាទទួលការសង្គ្រោះមិនខាន»។ ២២ព្រះយេស៊ូបែរទៅក្រោយទតឃើញនាង ក៏មានព្រះបន្ទូលថា៖ «កូនស្រីអើយ! ចូរក្លាហានឡើង ជំនឿរបស់នាងបានសង្គ្រោះនាងហើយ»។ ស្ត្រីធ្លាក់ឈាមបានជាសះស្បើយនៅពេលនោះ។

២៣កាលព្រះយេស៊ូយាងទៅដល់ផ្ទះនាម៉ឺននោះ ព្រះអង្គទតឃើញអ្នកលេងភ្លេងកំដរសព និងឃើញមនុស្សម្នាជ្រួលច្របល់ ទ្រង់មានព្រះបន្ទូលទៅគេថា ៖ ២៤«នាំគ្នាចេញទៅ! ក្មេងស្រីនេះមិនស្លាប់ទេ នាងគ្រាន់តែដេកលក់ទេតើ»។ គេចំអកដាក់ព្រះអង្គ។ ២៥កាលព្រះអង្គដេញគេចេញទៅក្រៅអស់ ហើយ ព្រះអង្គយាងចូលទៅក្នុងបន្ទប់ចាប់ដៃក្មេងស្រីនោះ នាងក៏ក្រោកឡើង។ ២៦ដំណឹងនេះលេចឮខ្ចរខ្ចាយពាសពេញតំបន់នោះទាំងមូល។

## ព្រះយេស៊ូប្រោស មនុស្សខ្វាក់ពីរនាក់ឲ្យបានភ្លឺ

២៧កាលព្រះយេស៊ូកំពុងតែយាង ចេញពីទីនោះ មានមនុស្សខ្វាក់ពីរនាក់មកតាមព្រះអង្គ ស្រែកថា៖« ព្រះរាជវង្សព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាយើងខ្ញុំផង»។ ២៨ពេលព្រះអង្គយាងទៅដល់ផ្ទះ មនុស្សខ្វាក់ទាំងពីរនាក់ចូលទៅជិតព្រះអង្គ។ ព្រះយេស៊ូមានព្រះបន្ទូលទៅអ្នកទាំងពីរថា៖ «តើអ្នកជឿថា ខ្ញុំអាចធ្វើឲ្យភ្នែកអ្នកភ្លឺបានឬ?»។គេទូលព្រះអង្គថា៖ «យើងខ្ញុំជឿហើយព្រះអម្ចាស់អើយ»។ ២៩ព្រះអង្គក៏ពាល់ភ្នែកអ្នកទាំងពីរ ទាំងមានព្រះបន្ទូលថា៖ «សុំឲ្យបានសម្រេចតាមជំនឿរបស់អ្នកចុះ»។ ៣០ពេលនោះ ភ្នែករបស់គេក៏បានភ្លឺ។ ព្រះយេស៊ូហាមប្រាមគេយ៉ាងតឹងតែងថា៖ «ចូរប្រយ័ត្នកុំឲ្យនរណាដឹងឡើយ»។ ៣១ប៉ុន្តែ បុរសទាំងពីរចេញទៅផ្សព្វផ្សាយរឿងនោះ ឲ្យគេដឹងពាសពេញស្រុក។

## ព្រះយេស៊ូប្រោស មនុស្សគម្នាក់ឲ្យនិយាយបាន

៣២លុះអ្នកទាំងពីរចេញផុតទៅ មានគេនាំមនុស្សគម្នាក់ដែលមានខ្មោចចូល មកគាល់ព្រះយេស៊ូ។ ៣៣កាលព្រះអង្គដេញខ្មោចចេញហើយមនុស្សគក៏និយាយបាន។ មហាជននាំគ្នាស្ងើចសរសើរយ៉ាងខ្លាំងទាំងពោលថា៖ «យើងមិនដែលឃើញការអស្ចារ្យបែបនេះ នៅស្រុកអ៊ីស្រាអែលឡើយ»។ ៣៤ប៉ុន្តែពួកខាងគណៈផារីស៊ីពោលថា៖ «គាត់ដេញខ្មោចបានដូច្នេះ មកពីស្ដេចខ្មោចបានប្រគល់អំណាចឲ្យ»។

## ព្រះយេស៊ូអាណិតមហាជន

(ម៉ាកុស ៦.៣៤ លូកា ១០.២)

៣៥បន្ទាប់មក ព្រះយេស៊ូយាងទៅតាមក្រុង និងតាមភូមិនានា ព្រះអង្គបង្រៀនអ្នកស្រុកនៅក្នុងធម្មសាលា*ព្រមទាំងប្រកាសដំណឹងល្អ* អំពីព្រះរាជ្យ* ហើយប្រោសអ្នកជំងឺនិងអ្នកពិការគ្រប់ប្រភេទឲ្យបានជាផង។ ៣៦កាលព្រះអង្គទតឃើញមហាជនទ្រង់មានព្រះហឫទ័យ អាណិត អាសូរគេ ពន់ពេកណាស់ ព្រោះអ្នកទាំងនោះអស់កម្លាំងល្វើយធ្លាក់ទឹកចិត្តប្រៀបបីដូចជាចៀមដែលគ្មានអ្នកគង្វាលថែទាំ។ ៣៧ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកសាវ័កថា៖ «ស្រូវដែលត្រូវច្រូតមានច្រើនណាស់តែអ្នកច្រូតមានតិចពេក។ ៣៨ហេតុនេះ ចូរអង្វរម្ចាស់ស្រែឲ្យចាត់អ្នកច្រូតមកក្នុងស្រែរបស់លោក»។

## ព្រះយេស៊ូតែងតាំងគ្រីស្តទូត១២រូប

(ម៉ាកុស ៣.១៣-១៩ លូកា ៦.១២-១៦)

១០ ¹ព្រះយេស៊ូត្រាស់ហៅសាវ័កទាំងដប់ពីររូបមក
ព្រះអង្គប្រទានឲ្យគេមានអំណាចដេញខ្មោច ព្រម
ទាំងមានអំណាចប្រោសអ្នកជំងឺគ្រប់យ៉ាង និងអ្នក
ពិការគ្រប់ប្រភេទឲ្យបានជាផង។ ២ គ្រីស្តទូត*ទាំង
ដប់ពីរមាននាមដូចតទៅ៖ អ្នកទីមួយគឺស៊ីម៉ូនហៅ
សិលានិងអន់ទ្រេជាប្អូនរបស់គាត់ យ៉ាកុបនិងយ៉ូ
ហានជាប្អូនរបស់គាត់ដែលត្រូវជាកូនរបស់លោកសេ
បេដេ ៣ភីលីពនិងបារថូឡូមេ ថូម៉ាស់ និងម៉ាថាយជា
អ្នកទារពន្ធ* យ៉ាកុបជាកូនរបស់លោកអាល់ផាយ
និងថាដេ ៤ស៊ីម៉ូនជាអ្នកជាតិនិយម និងយូដាអ៊ីស្ការី
យ៉ុតជាអ្នកក្បត់ព្រះអង្គ។

## ព្រះយេស៊ូចាត់សាវ័កទាំង ១២ទៅ ប្រកាសដំណឹងល្អ

(ម៉ាកុស ៦.៧-១៣ លូកា ៩.១-៦)

៥ព្រះយេស៊ូចាត់សាវ័ក*ទាំងដប់ពីររូបនេះ
ឲ្យទៅដោយផ្ដែផ្ដាំថា៖ «កុំទៅរកសាសន៍ដទៃឡើយ
ហើយក៏កុំចូលទៅក្នុងភូមិរបស់ជនជាតិសាម៉ារីដែរ ៦
គឺត្រូវ ទៅស្វែងរកអស់អ្នកដែលវង្វេង[ឃ] ក្នុងចំណោម
ជនជាតិអ៊ីស្រាអែលនោះវិញ។ ៧ពេលធ្វើដំណើរទៅ
ចូរប្រកាសថា ព្រះរាជ្យ*នៃស្ថានបរមសុខ*មកជិត
បង្កើយហើយ។ ៨ចូរមើលអ្នកជំងឺឲ្យបានជាប្រោស
មនុស្សស្លាប់ឲ្យរស់ឡើងវិញ ធ្វើឲ្យមនុស្សឃ្លង់បាន
ជាស្អាតបរិសុទ្ធ* ដេញខ្មោចចេញពីមនុស្ស។ អ្នក
រាល់គ្នាបានទទួលអំណាចដោយឥតបង់ថ្លៃ ត្រូវជួយ
គេវិញ ដោយឥតគិតថ្លៃដែរ។ ៩កុំរកមាសប្រាក់ឬ
លុយកាក់ដាក់ក្នុងថង់ឡើយ ១០ហើយកុំយកថង់
យាម កុំយកអាវពីរបន្លាស់ កុំយកស្បែកជើងឬដំបង
ទៅជាមួយ ដ្បិតអ្នកធ្វើការត្រូវតែទទួលម្ហូបអាហារ។
១១ពេលអ្នករាល់គ្នាចូលទៅក្នុងភូមិ ឬក្រុងណា
មួយ ចូរសួររកអ្នកដែលសមនឹងទទួលអ្នករាល់គ្នាឲ្យ
ស្នាក់នៅ។ ត្រូវស្នាក់នៅផ្ទះអ្នកនោះ រហូតដល់ពេល
អ្នករាល់គ្នាចេញពីទីនោះ។ ១២ពេលចូលទៅក្នុងផ្ទះ
ណាត្រូវជម្រាបសួរ[អ]អ្នកផ្ទះនោះ ១៣ប្រសិនបើអ្នកផ្ទះ
នោះ សមនឹងទទួលសេចក្ដីសុខសាន្តនោះសេចក្ដី
សុខសាន្តនឹងកើតមានដល់គេ ដូចពាក្យជម្រាបសួរ
របស់អ្នករាល់គ្នាមិនខាន។ ផ្ទុយទៅវិញបើគេមិនសម
នឹងទទួលទេ សេចក្ដីសុខសាន្តរបស់អ្នករាល់គ្នានឹង
វិលមករកអ្នករាល់គ្នាវិញ[ក]។ ១៤បើគេមិនព្រមទទួល
អ្នករាល់គ្នា ហើយបើគេមិនព្រមស្ដាប់ពាក្យរបស់អ្នក
រាល់គ្នាទេ ចូរចេញពីផ្ទះនោះឬពីក្រុងនោះទាំង
រលាស់ធូលីដីចេញពីជើងរបស់អ្នករាល់គ្នាផង[ខ]។
១៥ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថានៅថ្ងៃព្រះជា
ម្ចាស់វិនិច្ឆ័យទោសមនុស្សលោក អ្នកក្រុងសូដុម និង
អ្នកក្រុងកូម៉ូរ៉ានឹងទទួលទោសស្រាលជាងអ្នកក្រុង
នោះ»។

## អំពីការបៀតបៀន

(ម៉ាកុស ១៣.៩-១៣ លូកា ២១.១២-១៧)

១៦«ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅ ដូចឲ្យចៀមទៅ
កណ្ដាលហ្វូងចចក។ ហេតុនេះត្រូវចេះប្រយ័ត្នខ្លួន
ដូចសត្វពស់ ហើយកាន់ចិត្តស្លូតត្រង់ដូចសត្វព្រាប។
១៧ចូរប្រយ័ត្នកុំទុកចិត្តមនុស្សលោកឲ្យសោះ ដ្បិតគេ
នឹងចាប់បញ្ជូនអ្នករាល់គ្នាទៅតុលាការគេនឹងយក
រំពាត់ខ្សែតី មកវាយអ្នករាល់គ្នា នៅក្នុងធម្មសាលា
របស់គេ។ ១៨គេនឹងបញ្ជូនអ្នករាល់គ្នាទៅឲ្យលោក
ទេសាភិបាល និងឲ្យស្ដេចនានាកាត់ទោសព្រោះតែ
អ្នករាល់គ្នាតាមខ្ញុំ។ ប៉ុន្តែ ពេលនោះជាឱកាស
សម្រាប់ឲ្យអ្នករាល់គ្នាផ្ដល់សក្ខីភាព ឲ្យពួកលោក
និងឲ្យសាសន៍ដទៃដឹងឮទៅវិញ។ ១៩ពេលគេចាប់
បញ្ជូនអ្នករាល់គ្នាទៅកាត់ទោស ចូរកុំភ័យបារម្ភនឹង
រកពាក្យ ដែលអ្នករាល់គ្នាត្រូវនិយាយយ៉ាងណាៗ
នោះឡើយ ដ្បិតព្រះជាម្ចាស់នឹងប្រទានពាក្យដែល

អ្នករាល់គ្នាត្រូវនិយាយ នៅពេលនោះតែម្ដង។ ២០មិន
មែនអ្នករាល់គ្នាទេ ដែលនិយាយគឺព្រះវិញ្ញាណនៃ
ព្រះបិតារបស់អ្នករាល់គ្នា នឹងមានព្រះបន្ទូលនៅក្នុង
ចិត្តអ្នករាល់គ្នា។

២១បងប្អូននឹងចាប់បញ្ជូនគ្នាឯង ទៅឲ្យគេ
សម្លាប់ឪពុកនឹងចាប់បញ្ជូនកូន ទៅឲ្យគេសម្លាប់
ហើយកូនៗលើកគ្នាប្រឆាំងនឹងឪពុកម្ដាយ ព្រមទាំង
បញ្ជូនទៅឲ្យគេសម្លាប់ទៀតផង។ ២២មនុស្សគ្រប់ៗ
រូបនឹងស្អប់អ្នករាល់គ្នា ព្រោះតែនាមខ្ញុំ។ ប៉ុន្តែអ្នកណា
ស៊ូទ្រាំរហូតដល់ចុងបញ្ចប់ ព្រះជាម្ចាស់នឹងសង្គ្រោះ
អ្នកនោះ។ ២៣ប្រសិនបើគេបៀតបៀនអ្នករាល់គ្នានៅ
ក្រុងណាមួយ ចូររត់ទៅក្រុងមួយទៀតទៅ។ ខ្ញុំសុំ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បុត្រមនុស្ស*នឹងមក
ដល់ មុនអ្នករាល់គ្នាទៅដល់ក្រុងទាំងប៉ុន្មានក្នុងស្រុក
អ៊ីស្រាអែលទៅទៀត។

២៤ពុំដែលមានសិស្សណា ចេះជាងគ្រូឡើយ
ហើយក៏ពុំដែលមានអ្នកបម្រើណា ធំជាងម្ចាស់ដែរ
២៥ បើសិស្សចេះបានដូចគ្រូ ហើយអ្នកបម្រើបានដូច
ម្ចាស់ នោះល្មមគ្រប់គ្រាន់ហើយ។ ប្រសិនបើគេឲ្យ
ឈ្មោះម្ចាស់ផ្ទះថាបេលសេប៊ូល[ក]ទៅហើយ គេមុខជា
ឲ្យឈ្មោះអ្នកនៅក្នុងផ្ទះនោះ រឹតតែអាក្រក់ជាងនេះ
ទៅទៀតមិនខាន»។

## ព្រះយេស៊ូទូន្មានសាវ័កកុំឲ្យភ័យច្បារម្ត

(លូកា ១២.២-៧)

២៦«កុំខ្លាចពួកអ្នកទាំងនោះឡើយ ដ្បិតការ
លាក់កំបាំងទាំងអស់ នឹងត្រូវបើកឲ្យគេឃើញហើយ
អាថ៌កំបាំងទាំងប៉ុន្មាន ក៏នឹងត្រូវបើកឲ្យគេដឹងដែរ។
២៧អ្វីៗដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នា ក្នុងទីងងឹតចូរ
យកទៅនិយាយនៅក្នុងពន្លឺថ្ងៃ ហើយអ្វីៗដែលគេ
ខ្សឹបដាក់ត្រចៀក ចូរយកទៅប្រកាសនៅពីលើផ្ទះ។
២៨កុំខ្លាចអស់អ្នក ដែលសម្លាប់បានត្រឹមតែរូបកាយ
ហើយពុំអាចសម្លាប់ព្រលឹងបាននោះឲ្យសោះ គឺត្រូវ
ខ្លាចព្រះជាម្ចាស់វិញ ព្រោះទ្រង់អាចធ្វើឲ្យទាំង
ព្រលឹងទាំងរូបកាយ ធ្លាក់ទៅក្នុងភ្លើងនរកបាន។
២៩ ធម្មតាគេលក់ចាបពីរថ្លៃមួយសេន។ ទោះបីថោក
យ៉ាងនេះក៏ដោយ ប្រសិនបើព្រះបិតារបស់អ្នករាល់
គ្នាមិនយល់ព្រមទេនោះ ក៏គ្មានចាបណាមួយធ្លាក់ចុះ
ដល់ដីបានឡើយ។ ៣០រីឯអ្នករាល់គ្នាវិញ សូម្បីតែ
សក់នៅលើក្បាលអ្នករាល់គ្នា ក៏ព្រះអង្គរាប់អស់ដែ
រ។ ៣១ដូច្នេះ ចូរអ្នករាល់គ្នាកុំខ្លាចអ្វីឡើយ ព្រោះអ្នក
រាល់គ្នាមានតម្លៃ លើសចាបទាំងអស់ទៅទៀត»។

## អ្នកទទួលស្គាល់ និង អ្នកមិនទទួលស្គាល់ ព្រះយេស៊ូ

(លូកា ១២.៨-៩)

៣២«អ្នកណាទទួលស្គាល់ខ្ញុំ នៅចំពោះមុខ
មនុស្សលោក ខ្ញុំនឹងទទួលស្គាល់អ្នកនោះវិញ នៅ
ចំពោះព្រះភក្ត្រព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថាន
បរមសុខ។ ៣៣រីឯអ្នកណាបដិសេធមិនទទួលស្គាល់ខ្ញុំ
នៅចំពោះមុខមនុស្សលោក ខ្ញុំក៏បដិសេធមិនទទួល
ស្គាល់អ្នកនោះ នៅចំពោះព្រះភក្ត្រព្រះបិតារបស់ខ្ញុំ
ដែលគង់នៅស្ថានបរមសុខ*ដែរ»។

## ការច្បាក់បែកគ្នាព្រោះជំនឿ

(លូកា ១២.៥១-៥៣)

៣៤«កុំនឹកស្មានថា ខ្ញុំមកនេះដើម្បីនាំយកសន្តិ
ភាពមកឲ្យផែនដីឡើយ។ ខ្ញុំមិនមែននាំសន្តិភាពមក
ទេ តែខ្ញុំមកបំបែកមនុស្សចេញពីគ្នា[ឃ]។ ៣៥ខ្ញុំមកធ្វើ
ឲ្យកូនប្រុសបែកពីឪពុក កូនស្រីបែកពីម្ដាយ កូន
ប្រសាស្រីបែកពីម្ដាយក្មេក។ ៣៦អ្នកដែលនៅក្នុងផ្ទះ
ជាមួយគ្នាក្លាយទៅជាសត្រូវនឹងគ្នា»។

## សាវ័កដ៏ពិតប្រាកដរបស់ព្រះយេស៊ូ

(លូកា ១៤.២៦-២៧)

៣៧«អ្នកណាស្រឡាញ់ឪពុកម្ដាយ ខ្លាំងជាង
ស្រឡាញ់ខ្ញុំ អ្នកនោះមិនសមនឹងធ្វើជាសាវ័ក*របស់ខ្ញុំ
ឡើយ។ អ្នកដែលស្រឡាញ់កូនប្រុសកូនស្រីរបស់
ខ្លួន ខ្លាំងជាងស្រឡាញ់ខ្ញុំ ក៏មិនសមនឹងធ្វើជាសាវ័ក
របស់ខ្ញុំដែរ។ ៣៨អ្នកណាមិនយកឈើឆ្កាងរបស់ខ្លួន
ហើយមិនមកតាមខ្ញុំទេ អ្នកនោះមិនសមធ្វើជាសាវ័ក
របស់ខ្ញុំឡើយ។ ៣៩អ្នកណាចង់រក្សាទុកជីវិតរបស់ខ្លួន
អ្នកនោះនឹងបាត់បង់ជីវិត រីឯអ្នកដែលបាត់បង់ជីវិត
ព្រោះតែខ្ញុំ នឹងបានជីវិតនោះ មកវិញ»។

## អ្នកណាទទួលអ្នករាល់គ្នាក៏ដូចជាទទួលខ្ញុំដែរ

៤០អ្នកណាទទួលអ្នករាល់គ្នា ក៏ដូចជាទទួលខ្ញុំ
ហើយអ្នកណាទទួលខ្ញុំ ក៏ដូចជាទទួលព្រះអង្គដែល
ចាត់ខ្ញុំឲ្យមកនោះដែរ។ ៤១អ្នកណាទទួលព្យាការី*
ម្នាក់ក្នុងនាមលោកជាព្យាការី អ្នកនោះនឹងទទួល
រង្វាន់ដូចព្យាការី។ អ្នកណាទទួលមនុស្សសុចរិត*
ម្នាក់ក្នុងនាមជាមនុស្សសុចរិត អ្នកនោះនឹងទទួល
រង្វាន់ដូចមនុស្សសុចរិត។ ៤២អ្នកណាឲ្យទឹកត្រជាក់
សូម្បីតែមួយកែវ ដល់អ្នកតូចតាចម្នាក់ក្នុងនាមជាសា
វ័ក*របស់ខ្ញុំ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នក
នោះនឹងទទួលរង្វាន់ជាមិនខាន»។

## លោកយ៉ូហានបាទីស្ដចាត់សិស្សទៅជួបព្រះយេស៊ូ

(លូកា ៧.១៨-៣៥)

១១ ១កាលព្រះយេស៊ូ មានព្រះបន្ទូល ផ្ដែផ្ដាំសាវ័ក*
ទាំងដប់ពីររូប ចប់សព្វគ្រប់ហើយព្រះអង្គយាងចាក
ចេញពីទីនោះ ទៅបង្រៀននិងប្រកាសដំណឹងល្អ*
ដល់ប្រជាជន នៅតាមភូមិនានា។

២ពេលនោះ លោកយ៉ូហានជាប់ក្នុងមន្ទីរឃុំ
ឃាំងហើយឮគេនិយាយអំពីកិច្ចការទាំងប៉ុន្មាន ដែល
ព្រះគ្រីស្ដ*បានធ្វើ។ លោកក៏ចាត់សិស្សឲ្យទៅទូល
សួរព្រះយេស៊ូថា៖ ៣«តើលោកជាព្រះគ្រីស្ដដែលត្រូវ
យាងមកឬមួយយើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេងទៀត?»។
៤ព្រះយេស៊ូមានព្រះបន្ទូល ទៅសិស្សទាំងនោះថា៖«
ចូរអ្នករាល់គ្នាទៅជម្រាបលោកយ៉ូហាន នូវហេតុ
ការណ៍ ដែលអ្នករាល់គ្នាបានឮ និងបានឃើញនេះ
ទៅ ៥គឺមនុស្សខ្វាក់មើលឃើញ មនុស្សខ្វិនដើរបាន
មនុស្សឃ្លង់ជា ស្អាតបរិសុទ្ធ មនុស្សថ្លង់ស្ដាប់ឮ
មនុស្សស្លាប់បានរស់ឡើងវិញ ហើយមានគេនាំ
ដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ៦អ្នកណាមិនរវាត
ចិត្តចេញពីជំនឿ ដោយសារខ្ញុំអ្នកនោះពិតជាមាន
សុភមង្គលហើយ!»។

៧ពេលពួកសិស្សរបស់លោកយ៉ូហាន ចេញផុត
ទៅព្រះយេស៊ូមានព្រះបន្ទូលទៅមហាជន អំពីលោក
យ៉ូហានថា៖ «តើអ្នករាល់គ្នាទៅវាលរហោស្ថានរក
មើលអ្វី? រកមើលដើមត្រែងដែលត្រូវខ្យល់បក់នោះ
ឬ?។ ៨តើអ្នករាល់គ្នាទៅរកមើលអ្វី?រកមើលមនុស្ស
ស្លៀកពាក់ល្អរុងរឿងឬ? តាមធម្មតាអស់អ្នកដែល
ស្លៀកពាក់ល្អរុងរឿង គេរស់នៅក្នុងដំណាក់ស្ដេចឯ
ណោះ!។ ៩បើដូច្នេះតើអ្នករាល់គ្នាទៅរកមើលអ្វី? រក
មើលព្យាការី*ម្នាក់ឬ?។ ត្រូវហើយ! ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងថាលោកនោះប្រសើរជាងព្យាការីទៅទៀត
១០ដ្បិតក្នុងគម្ពីរមានចែងអំពីលោកយ៉ូហានថា "យើង
ចាត់ទូតយើងឲ្យទៅមុនព្រះអង្គ ដើម្បីរៀបចំផ្លូវរបស់
ព្រះអង្គ"[ច]។ ១១ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា
បណ្ដាមនុស្សដែលកើតមកក្នុងលោកនេះ[ឆ] គ្មាន
នរណាមានឋានៈធំជាងលោកយ៉ូហានបាទីស្ដឡើ
យ។ប៉ុន្តែអ្នកណាតូចជាងគេ នៅក្នុងព្រះរាជ្យ*នៃ
ស្ថានបរមសុខ*អ្នកនោះប្រសើរលើសលោកយ៉ូហាន
ទៅទៀត។

១២តាំងពីជំនាន់លោកយ៉ូហានបាទីស្ដ មកទល់
សព្វថ្ងៃព្រះរាជ្យនៃស្ថានបរមសុខ បានរងនូវអំពើ
ឃោរឃៅ ហើយមនុស្សឃោរឃៅបាននាំគ្នាប្រើ

កម្លាំងដណ្ដើមយកព្រះរាជ្យនេះផង។ ១៣ តាំងពីដើមរហូតមកដល់ ជំនាន់លោកយ៉ូហានព្យាការីទាំងអស់បានថ្លែងទុក អំពីព្រះរាជ្យនេះហើយក្នុងធម្មវិន័យ*ក៏មានចែងទុកដែរ។ ១៤ជឿខ្ញុំចុះ លោកយ៉ូហានហ្នឹងហើយ ជាព្យាការីអេលីដែលត្រូវមក។ ១៥អ្នកណាឮពាក្យនេះ សុំយកទៅពិចារណាទៅ!

១៦តើខ្ញុំអាចប្រដូចមនុស្សជំនាន់នេះ ទៅនឹងជនប្រភេទណា? អ្នកទាំងនោះប្រៀបបានទៅនឹងកូនក្មេង ដែលអង្គុយលេងនៅតាមផ្សារ ហើយស្ដីបន្ទោសគ្នាទៅវិញទៅមកថា៖ ១៧"យើងបានផ្លុំខ្លុយ តែពួកឯងពុំព្រមរាំទេ យើងបានស្មូតបទទំនួញ ក៏ពួកឯងពុំព្រមគក់ទ្រូងយំដែរ"។ ១៨យ៉ាងណាមិញលោកយ៉ូហានបានមក លោកតមអាហារ តមស្រា តែគេថាលោកមានខ្មោចចូល ១៩រីឯបុត្រមនុស្ស*ក៏បានមកដែរ លោកបរិភោគអាហារ និងពិសាស្រាតែគេថា " មើលចុះ! អ្នកនេះគិតតែពីស៊ីផឹក ហើយសេពគប់ជាមួយពួកទារពន្ធ* និងមនុស្សបាប"។ប៉ុន្តែមនុស្សលោកទទួលស្គាល់ថា ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ពិតជាល្អត្រឹមត្រូវមែន ដោយគេបានឃើញកិច្ចការដែលព្រះអង្គធ្វើ»។

## ព្រះយេស៊ូបន្ទោសអ្នកក្រុងនានាដែលពុំព្រមជឿ

(លូកា ១០.១៣-១៥)

២០ពេលនោះ ព្រះអង្គចាប់ផ្ដើមស្ដីបន្ទោសអ្នកក្រុងនានាយ៉ាងខ្លាំង ព្រោះគេបានឃើញព្រះអង្គសម្ដែងការអស្ចារ្យផ្សេងៗក្នុងក្រុងរបស់គេ តែគេពុំព្រមប្រែចិត្តគំនិតសោះ៖

២១«អ្នកក្រុងខូរ៉ាស៊ីនអើយ! អ្នកត្រូវវេទនាជាពុំខាន។ អ្នកក្រុងបេតសៃដាអើយ! អ្នកក៏ត្រូវវេទនាដែរ។ ប្រសិនបើអ្នកក្រុងទីរ៉ូសនិងអ្នកក្រុងស៊ីដូនបានឃើញការអស្ចារ្យ ដូចអ្នករាល់គ្នាឃើញនៅទីនេះ ម្ល៉េះសមអ្នកក្រុងទាំងនោះប្រែចិត្តគំនិត ហើយស្លៀកបាវអង្គុយក្នុងផេះជាមិនខាន។ ២២ហេតុនេះហើយ បានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថានៅថ្ងៃ ដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក អ្នកក្រុងទីរ៉ូស និងអ្នកក្រុងស៊ីដូនទទួលទោសស្រាលជាងអ្នករាល់គ្នា។

២៣អ្នកក្រុងកាផានុមអើយ! កុំនឹកស្មានថាអ្នកនឹងបានថ្កើងឡើងដល់ស្ថានសួគ៌ឡើយ អ្នកនឹងធ្លាក់ទៅស្ថាននរកវិញ។ ប្រសិនបើ អ្នកក្រុងសូដុមបានឃើញការអស្ចារ្យ ដែលកើតមាននៅកណ្ដាលចំណោមអ្នករាល់គ្នា ម្ល៉េះសមក្រុងសុដុមនៅស្ថិតស្ថេរគង់វង្សដរាបមកទល់សព្វថ្ងៃជាមិនខាន។ ២៤ហេតុនេះ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យទោសមនុស្សលោក អ្នកក្រុងសូដុមនឹងទទួលទោសស្រាលជាងអ្នករាល់គ្នា»។

## ព្រះបិតា និង ព្រះបុត្រា

(លូកា ១០.២១-២២)

២៥នៅពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលឡើងថា៖ «បពិត្រព្រះបិតាជាអម្ចាស់នៃស្ថានបរមសុខ*និង ជាអម្ចាស់នៃផែនដី ទូលបង្គំសូមសរសើរតម្កើងព្រះអង្គ ព្រោះទ្រង់បានសម្ដែងការទាំងនេះឲ្យមនុស្សតូចតាចយល់ តែទ្រង់បានលាក់មិនឲ្យអ្នកប្រាជ្ញ និងអ្នកចេះដឹងយល់ទេ។ ២៦មែនហើយ!ព្រះអង្គសព្វព្រះហឫទ័យសម្រេចដូច្នេះ។

២៧ព្រះបិតារបស់ខ្ញុំបានប្រគល់អ្វីៗទាំងអស់មកខ្ញុំ គ្មានអ្នកណាស្គាល់ព្រះបុត្រាក្រៅពីព្រះបិតា ហើយក៏គ្មាននរណាស្គាល់ព្រះបិតា ក្រៅពីព្រះបុត្រា និងអ្នកដែលព្រះបុត្រាសព្វព្រះហឫទ័យ សម្ដែងឲ្យស្គាល់នោះដែរ»។

## ចន័យរបស់ព្រះយេស៊ូ

២៨«អស់អ្នកដែលនឿយហត់ និងមានបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានសម្រាក។

២៩ចូរយកនឹម[ឈ]របស់ខ្ញុំ ដាក់លើអ្នករាល់គ្នាហើយ
រៀនពីខ្ញុំទៅ អ្នករាល់គ្នាមុខជាបានស្ងប់ចិត្តមិនខាន
ដ្បិតខ្ញុំស្លូតនិងមានចិត្តសុភាព។ ៣០នឹមរបស់ខ្ញុំស្រួល
ហើយបន្ទុក[ឈ]ដែលខ្ញុំដាក់លើអ្នករាល់គ្នាក៏ស្រាល
ដែរ»។

## ព្រះយេស៊ូមានអំណាចលើវិន័យថ្ងៃសប្ប័ទ

(ម៉ាកុស២.២៣-២៨; លូកា៦.១-៥)

១២ ១មានគ្រាមួយ ព្រះយេស៊ូយាងកាត់វាលស្រែ នៅ
ថ្ងៃសប្ប័ទ* សាវ័ក*របស់ព្រះអង្គឃ្លានពេក ក៏នាំគ្នា
បូតកួរស្រូវមកបរិភោគ។ ២ពួកខាងគណៈផារីស៊ី*
ឃើញដូច្នោះ ទូលព្រះអង្គថា៖ «សូមលោកមើលចុះ
ពួកសិស្សរបស់លោកនាំគ្នាធ្វើការ ដែលបញ្ញត្តិហាម
មិនឲ្យធ្វើ នៅថ្ងៃសប្ប័ទ!»។ ៣ព្រះយេស៊ូតបទៅគេ
វិញថា៖ «ក្នុងគម្ពីរមានអត្ថបទមួយ ស្ដីអំពីការដែល
ព្រះបាទដាវីឌ និងបរិពារបានប្រព្រឹត្តនៅពេលឃ្លាន ៤
គឺស្ដេចយាងចូលទៅក្នុងដំណាក់របស់ព្រះជាម្ចាស់
ហើយយកនំប៉័ងដែលគេតាំងថ្វាយព្រះជាម្ចាស់ មក
សោយជាមួយពួកបរិពារ។តាមវិន័យ* មានតែពួក
បូជាចារ្យ*ប៉ុណ្ណោះដែលបរិភោគនំប៉័ងនេះបាន រីឯ
ព្រះរាជាគ្មានសិទ្ធិសោយទេ ហើយពួកបរិពារក៏គ្មាន
សិទ្ធិបរិភោគដែរ តើអ្នករាល់គ្នាធ្លាប់អានអត្ថបទនោះ
ឬទេ? ៥ម៉្យាងទៀតនៅថ្ងៃសប្ប័ទ ពួកបូជាចារ្យដែល
បំពេញមុខងារនៅក្នុងព្រះវិហារ* សុទ្ធតែរំលោភលើវិ
ន័យថ្ងៃសប្ប័ទ តែឥតមានទោសឡើយ តើអ្នករាល់
គ្នាដែលអានធម្មវិន័យនោះទេ? ៦ខ្ញុំសុំប្រាប់អ្នករាល់
គ្នាថា នៅទីនេះមានម្នាក់ប្រសើរជាងព្រះវិហារទៅ
ទៀត។ ៧ប្រសិនបើអ្នករាល់គ្នាយល់អត្ថន័យនៃ
សេចក្ដី ដែលមានចែងទុកមកថា "យើងមិនចង់បាន
យញ្ញបូជាទេ គឺចង់បានតែចិត្តមេត្តាករុណាប៉ុណ្ណោះ"
[ញ] នោះអ្នករាល់គ្នាមុខជាមិនប្រកាន់ទោសជន ដែល
គ្មានទោសទាំងនេះឡើយ ៨ដ្បិតបុត្រមនុស្ស*ជា
ម្ចាស់លើថ្ងៃសប្ប័ទ*»។

## ព្រះយេស៊ូប្រោសមនុស្សស្វិតដៃម្នាក់ឲ្យបានជា

(ម៉ាកុស៣.១-៦ លូកា៦.៦-១១)

៩ព្រះយេស៊ូចាកចេញពីទីនោះ យាងចូលទៅ
ក្នុងធម្មសាលា*របស់គេ។ ១០មានបុរសស្វិតដៃម្នាក់
នៅក្នុងធម្មសាលានោះដែរ។ គេនាំគ្នាទូលសួរព្រះ
អង្គថា៖ «នៅថ្ងៃសប្ប័ទ* តើយើងមានសិទ្ធិប្រោស
អ្នកជំងឺឲ្យបានជាឬទេ?»។ គេសួរដូច្នេះ ក្នុងគោល
បំណងរកលេស ដើម្បីចោទប្រកាន់ព្រះអង្គ។ ១១ព្រះ
អង្គមានព្រះបន្ទូលទៅគេថា៖ «ក្នុងចំណោមអ្នករាល់
គ្នា បើនរណាម្នាក់មានចៀមតែមួយហើយចៀមនោះ
ធ្លាក់អណ្ដូង នៅថ្ងៃសប្ប័ទ តើអ្នកនោះមិនទៅស្រង់
យកចៀមឡើងមកវិញទេឬ?។ ១២រីឯមនុស្សវិញ គេ
មានតម្លៃលើសចៀមឆ្ងាយណាស់!ដូច្នេះយើងមាន
សិទ្ធិធ្វើអំពើល្អនៅថ្ងៃសប្ប័ទបាន»។

១៣ព្រះអង្គមានព្រះបន្ទូល ទៅកាន់បុរសស្វិតដៃ
នោះថា៖ «ចូរលាតដៃមើល៍!»។ បុរសនោះលាតដៃ
ហើយដៃគាត់ក៏បានជា ដូចដៃម្ខាងទៀត។

១៤ពួកខាងគណៈផារីស៊ី* ចេញពីធម្មសាលា*
ហើយពិគ្រោះគ្នា រកមធ្យោបាយធ្វើគុតព្រះអង្គ។ ១៥
កាលព្រះយេស៊ូជ្រាបដូច្នោះ ព្រះអង្គយាងចាកចេញ
ពីទីនោះ ទាំងមានមហាជនជាច្រើនដើរតាមព្រះអង្គ
ទៅដែរ។ ព្រះអង្គបានប្រោសពួកគេឲ្យជាពីជំងឺទាំង
អស់គ្នា ១៦តែព្រះអង្គគំរាមគេយ៉ាងម៉ឺងម៉ាត់មិនឲ្យ
និយាយប្រាប់អ្នកដទៃថា ព្រះអង្គជានរណាឡើយ ១៧
ដើម្បីឲ្យស្របនឹងសេចក្ដីដែលមានចែងទុកតាមរយៈ
ព្យាការី*អេសាយថា៖

១៨ *«លោកនេះហើយជាអ្នកបម្រើដែលយើងបាន*
*ជ្រើសរើស ជាអ្នកដែលយើងស្រឡាញ់*

*ហើយធ្វើឲ្យចិត្តយើងរីករាយ។យើងនឹងដាក់*
*វិញ្ញាណរបស់យើង*
*ឲ្យសណ្ឋិតលើលោក*
*ហើយលោកនឹងប្រាប់ឲ្យជាតិសាសន៍*
*ទាំងអស់ស្គាល់សេចក្ដីសុចរិត។*
១៩ *លោកនឹងមិនឈ្លោះប្រកែកជាមួយនរណា*
*ឡើយ ហើយក៏មិនស្រែកដាក់នរណាផង*
*គ្មាននរណាឮសំឡេងរបស់លោកនៅតាម*
*ទីផ្សារទេ។*
២០ *លោកនឹងមិនកាច់ដើមត្រែងណាដែល*
*ទក់ហើយនោះឡើយ*
*ហើយក៏មិនផ្លុំពន្លត់ភ្លើងណាដែលហៀបនឹង*
*រលត់នោះដែរ។*
*លោកធ្វើដូច្នេះរហូតដល់លោកនាំ*
*សេចក្ដីសុចរិតឲ្យមានជ័យជំនះ។*
២១ *ជាតិសាសន៍ទាំងអស់នឹងនាំគ្នា*
*សង្ឃឹមលើលោក»ដ ។*

## ព្រះយេស៊ូឆ្លើយតបនឹងអ្នកចោទប្រកាន់ព្រះអង្គ

(ម៉ាកុស៣.២០-៣០ លូកា១១.១៤-២៣)

២២ពេលនោះ មានគេនាំបុរសខ្វាក់ចូលម្នាក់
មកគាល់ព្រះអង្គ។ ខ្មោចបានធ្វើឲ្យគាត់ខ្វាក់ផងថ្លង់ផ
ង។ ព្រះអង្គប្រោសគាត់ឲ្យជា គាត់ក៏និយាយបាននិង
មើលឃើញទៀតផង។ ២៣មហាជនស្រឡាំងកាំង
ទាំងអស់គ្នា គេពោលថា៖ «លោកនេះពិតជាព្រះរាជ
វង្សរបស់ព្រះបាទដាវីឌមែន!»។ ២៤ប៉ុន្តែពួកខាងគ
ណៈផារីស៊ី*ពោលថា៖ «អ្នកនេះដេញខ្មោចបាន
ដូច្នេះមកពីបេលសេប៊ូល[ប] ជាស្ដេចខ្មោចប្រគល់
អំណាចឲ្យប៉ុណ្ណោះ»។ ២៥ព្រះអង្គឈ្វេងយល់គំនិត
របស់គេ ទ្រង់មានព្រះបន្ទូលទៅគេថា៖ «នគរណាក៏
ដូចនគរណាដែរ ប្រសិនបើពលរដ្ឋបាក់បែកទាស់
ទែងគ្នាឯង នគរនោះមុខជាត្រូវវិនាសមិនខាន រីឯ
ក្រុង ឬក្រុមគ្រួសារណាបាក់បែកទាស់ទែងគ្នាឯង ក៏
មិនអាចនៅស្ថិតស្ថេរគង់វង្សបានដែរ។ ២៦បើមារ*
សាតាំងបណ្ដេញមារសាតាំង ហើយវាបាក់បែកទាស់
ទែងនឹងខ្លួនវា ធ្វើម្ដេចឲ្យរាជ្យរបស់វា នៅស្ថិតស្ថេរ
គង់វង្សបាន!។ ២៧ប្រសិនបើខ្ញុំដេញខ្មោចដោយ
អំណាចបេលសេប៊ូលមែន តើកូនចៅរបស់អ្នករាល់
គ្នាដេញខ្មោច ដោយអាងលើនរណាវិញ?។ ដូច្នេះ
កូនចៅរបស់អ្នករាល់គ្នានឹងដាក់ទោសអ្នករាល់គ្នាពុំ
ខាន។ ២៨ផ្ទុយទៅវិញ បើខ្ញុំដេញខ្មោចដោយព្រះ
វិញ្ញាណរបស់ព្រះជាម្ចាស់ បានសេចក្ដីថាព្រះរាជ្យ*
របស់ព្រះអង្គ មកដល់អ្នករាល់គ្នាហើយ។ ២៩ម្យ៉ាង
ទៀត ពុំមាននរណាអាចចូលទៅក្នុងផ្ទះមនុស្សខ្លាំង
ពូកែ ហើយរឹបអូសយកទ្រព្យសម្បត្តិរបស់គាត់បាន
ឡើយ លុះត្រាណាតែចងមនុស្សខ្លាំងពូកែនោះជា
មុនសិន ទើបអាចប្លន់យកទ្រព្យសម្បត្តិក្នុងផ្ទះគាត់បា
ន។ ៣០អ្នកណាមិនរួមជាមួយខ្ញុំអ្នកនោះប្រឆាំងនឹងខ្ញុំ
ហើយអ្នកណាមិនជួយប្រមូលផ្ដុំជាមួយខ្ញុំទេ អ្នកនោះ
ជាអ្នកកំចាត់កំចាយ។ ៣១ហេតុនេះហើយបានជាខ្ញុំសុំ
ប្រាប់អ្នករាល់គ្នាថា បើមនុស្សលោកប្រព្រឹត្តអំពើបាប
និងពោលពាក្យប្រមាថព្រះជាម្ចាស់ ព្រះអង្គនឹងលើក
លែងទោសឲ្យបានទាំងអស់ តែបើគេប្រមាថព្រះ
វិញ្ញាណវិញ ព្រះអង្គនឹងមិនលើកលែងទោសឲ្យឡើ
យ។ ៣២បើអ្នកណាពោលពាក្យទាស់នឹងបុត្រមនុស្ស*
ព្រះជាម្ចាស់នឹងលើកលែងទោសឲ្យបាន រីឯអ្នកដែល
ពោលពាក្យទាស់នឹងព្រះវិញ្ញាណដ៏វិសុទ្ធ* ទោះបីនៅ
ក្នុងលោកនេះ ឬនៅបរលោកក្ដីក៏ព្រះអង្គមិនលើក
លែងទោសឲ្យដែរ»។

## ដើមឈើល្អ ដើមឈើអាក្រក់

(លូកា៦.៤៣-៤៥)

៣៣«បើដើមល្អផ្លែក៏ល្អ តែបើដើមអាក្រក់វិញ
ផ្លែវាក៏អាក្រក់ដែរ ដ្បិតគេស្គាល់ដើមឈើតាមផ្លែ

របស់វា។ ៣៤នែ៎ពូជពស់វែកអើយ! អ្នករាល់គ្នា
និយាយសេចក្ដីល្អៗដូចម្ដេចបាន បើអ្នករាល់គ្នា
សុទ្ធតែជាមនុស្សអាក្រក់ដូច្នេះ! ដ្បិតមាត់របស់
មនុស្សតែងស្រដីចេញមកនូវសេចក្ដីណា ដែលមាន
ពេញហូរហៀរនៅក្នុងដួងចិត្តរបស់ខ្លួន។ ៣៥មនុស្ស
ល្អតែងប្រព្រឹត្តល្អ ព្រោះគេមានសុទ្ធតែគំនិតល្អនៅ
ក្នុងខ្លួន រីឯមនុស្សអាក្រក់វិញ តែងប្រព្រឹត្តអាក្រក់
ព្រោះគេមានសុទ្ធតែគំនិតអាក្រក់នៅក្នុងខ្លួន។ ៣៦ខ្ញុំ
សុំប្រាប់អ្នករាល់គ្នាថា នៅថ្ងៃព្រះជាម្ចាស់វិនិច្ឆ័យ
ទោសមនុស្សលោក ព្រះអង្គនឹងវិនិច្ឆ័យតាមពាក្យ
សំដីឥតប្រយោជន៍ដែលគេបាននិយាយ ៣៧ដ្បិតអ្នក
នឹងបានសុចរិតដោយសារពាក្យសំដីអ្នក ឬមួយអ្នក
ត្រូវទទួលទោស ក៏ដោយសារតែពាក្យសំដីរបស់អ្នក
ដែរ»។

## ទីសម្គាល់របស់លោកយ៉ូណាស

(ម៉ាកុស ៨.១១-១២ លូកា ១១.២៩-៣២)

៣៨នៅពេលនោះ មានពួកធម្មាចារ្យ*និងពួក
ខាងគណៈផារីស៊ី*ខ្លះទូលព្រះអង្គថា៖ «លោកគ្រូ
សូមលោកធ្វើទីសម្គាល់ដ៏អស្ចារ្យមួយ ឲ្យយើងខ្ញុំ
ឃើញផង!»។

៣៩ព្រះយេស៊ូមានព្រះបន្ទូល តបទៅគេថា៖«
មនុស្សជំនាន់នេះអាក្រក់ណាស់ ហើយក្បត់នឹងព្រះ
ជាម្ចាស់ផង។ គេចង់តែឃើញទីសម្គាល់ដ៏អស្ចារ្យ
ប៉ុន្តែព្រះជាម្ចាស់មិនប្រទានទីសម្គាល់ណាផ្សេង ក្រៅ
ពីទីសម្គាល់របស់ព្យាការី*យ៉ូណាសឡើយ។ ៤០
លោកយ៉ូណាសស្ថិតនៅក្នុងពោះត្រីធំបីថ្ងៃបីយប់
យ៉ាងណា បុត្រមនុស្សក៏នឹងស្ថិតនៅក្នុងដីបីថ្ងៃបីយប់
យ៉ាងនោះដែរ។ ៤១នៅថ្ងៃដែលព្រះជាម្ចាស់វិនិច្ឆ័យ
ទោសមនុស្សលោក អ្នកក្រុងនីនីវេនឹងក្រោកឡើង
ជាមួយមនុស្សជំនាន់នេះ ព្រមទាំងចោទប្រកាន់គេ
ផង ព្រោះកាលពីជំនាន់ដើម នៅពេលដែលអ្នកក្រុង
នីនីវេ ឮសេចក្ដីលោកយ៉ូណាសប្រកាស គេបានប្រែ
ចិត្តគំនិត។ រីឯនៅទីនេះមានម្នាក់ប្រសើរជាងលោក
យ៉ូណាសទៅទៀត។ ៤២នៅថ្ងៃដែលព្រះជាម្ចាស់
វិនិច្ឆ័យទោសមនុស្សលោកមហាក្សត្រីស្រុកខាងត្បូង
នឹងក្រោកឡើង ជាមួយមនុស្សជំនាន់នេះ ព្រមទាំង
ចោទប្រកាន់គេផង ព្រោះកាលពីជំនាន់ដើម ព្រះនាង
បានយាងមកពីតំបន់ដាច់ស្រយាលនៃផែនដី ដើម្បី
ស្ដាប់ព្រះបន្ទូលរបស់ព្រះបាទសាឡូម៉ូន ប្រកប
ដោយប្រាជ្ញាឈ្លាសវៃ។ រីឯនៅទីនេះ មានម្នាក់
ប្រសើរជាងព្រះបាទសាឡូម៉ូនទៅទៀត»។

## ត្រូវប្រយ័ត្នកុំឲ្យខ្មោចចូលម្ដងទៀត

(លូកា ១១.២៤-២៦)

៤៣«កាលបើខ្មោចចេញពីមនុស្សណាម្នាក់
ហើយ វាតែងស្វែងរកទីជម្រក នៅវាលហួតហែង តែ
ប្រសិនបើវារកពុំឃើញទេ ៤៤វាមុខជានិយាយថា "
អញនឹងវិលត្រឡប់ទៅផ្ទះដែលអញទើបចេញមក"។
លុះទៅដល់ឃើញផ្ទះនោះនៅទំនេរ បោសស្អាត
ហើយតុបតែងល្អ ៤៥វានឹងចេញទៅបបួលខ្មោច
ប្រាំពីរទៀត ដែលសុទ្ធតែអាក្រក់ជាងវាមកចូលនៅ
ក្នុងអ្នកនោះ បណ្ដាលឲ្យគាត់រឹងរឹតតែអាក្រក់លើស
ដើមទៅទៀត។ រីឯមនុស្សអាក្រក់នៅជំនាន់នេះ ក៏
នឹងកើតមានដូច្នោះដែរ»។

## ព្រះញាតិវង្សពិតប្រាកដរបស់ព្រះយេស៊ូ

(ម៉ាកុស ៣.៣១-៣៥ លូកា ៨.១៩-២១)

៤៦ព្រះអង្គកំពុងតែមានព្រះបន្ទូល ទៅកាន់
មហាជននៅឡើយ ស្រាប់តែមាតានិងបងប្អូនរបស់
ព្រះអង្គមកឈរចាំនៅខាងក្រៅ ចង់និយាយជាមួយ
ព្រះអង្គ។ ៤៧មានម្នាក់ទូលព្រះអង្គថា៖ «ម្ដាយលោក
និងបងប្អូនលោកនៅខាងក្រៅ ចង់និយាយជាមួយ
លោក»។ ៤៨ព្រះអង្គមានព្រះបន្ទូលតបទៅគាត់វិញ
ថា៖ «តើនរណាជាម្ដាយខ្ញុំ? នរណាជាបងប្អូនខ្ញុំ?»

។ ៤៩ព្រះអង្គលើកព្រះហស្តចង្អុលទៅពួកសាវ័ក*
ទាំងមានព្រះបន្ទូលថា៖ «អ្នកទាំងនេះហើយជាមាតា
និងជាបងប្អូនរបស់ខ្ញុំ ៥០ដ្បិតអ្នកណាធ្វើតាមព្រះហឫ
ទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខ*
អ្នកនោះហើយជាបងប្អូនប្រុសស្រី និង ជាម្ដាយរបស់
ខ្ញុំ»។

## ប្រស្នាអំពីគ្រាប់ពូជ

(ម៉ាកុស ៤.១-២០ លូកា ៨.៤-១៥)

១៣ ១នៅគ្រានោះ ព្រះយេស៊ូចាកចេញពីផ្ទះ យាង
ទៅគង់នៅមាត់សមុទ្រ។ ២មានមហាជនច្រើនកុះករ
មកចោមរោមព្រះអង្គ ព្រះអង្គក៏យាងចុះទៅគង់ក្នុង
ទូកមួយ រីឯបណ្ដាជនឈរនៅមាត់ច្រាំង។ ៣ព្រះអង្គ
មានព្រះបន្ទូលទៅគេយ៉ាងច្រើន ដោយប្រើប្រស្នាដូច
តទៅ៖

«មានបុរសម្នាក់ ចេញទៅព្រោះគ្រាប់ពូជ។ ៤
ពេលគាត់ព្រោះ មានគ្រាប់ពូជខ្លះធ្លាក់ទៅលើផ្លូវ
ហើយសត្វមកចឹកស៊ីអស់ទៅ។ ៥មានគ្រាប់ពូជខ្លះ
ទៀតធ្លាក់ទៅលើកន្លែងមានថ្ម ពុំសូវមានដី។ គ្រាប់
ពូជក៏ដុះឡើងភ្លាម ព្រោះដីមិនជ្រៅ។ ៦លុះដល់ថ្ងៃ
ក្ដៅឡើង ពន្លកទាំងនោះក្រៀមស្វិតអស់ទៅ ព្រោះ
ឫសចាក់មិនបានជ្រៅ។ ៧គ្រាប់ពូជខ្លះទៀតធ្លាក់ទៅ
លើដីមានបន្លា។ បន្លាក៏ដុះឡើងរួបរឹតស្រូវមិនឲ្យដុះ
បានឡើយ។ ៨គ្រាប់ពូជខ្លះទៀតធ្លាក់ទៅលើដីមានជី
ជាតិល្អ មួយគ្រាប់ឲ្យផលជាមួយរយគ្រាប់ មួយទៀត
ឲ្យហុកសិប និងមួយទៀតឲ្យសាមសិប។ ៩អស់អ្នក
ដែលឮពាក្យនេះ សូមយកទៅពិចារណាចុះ![ខ]»។

១០ពេលនោះពួកសាវ័កនាំគ្នាចូលមកជិតព្រះ
អង្គទូលសួរថា៖ «ហេតុដូចម្ដេចបានជាព្រះគ្រូមាន
ព្រះបន្ទូលទៅកាន់បណ្ដាជន ដោយប្រើពាក្យប្រស្នា
ដូច្នេះ?»។ ១១ព្រះអង្គតបទៅគេវិញថា៖ «មកពីព្រះ
ជាម្ចាស់បានប្រោសប្រទាន ឲ្យអ្នករាល់គ្នាយល់
គម្រោងការណ៍ដ៏លាក់កំបាំង របស់ព្រះរាជ្យ*នៃស្ថាន
បរមសុខ* រីឯអ្នកដទៃវិញ ព្រះអង្គមិនប្រទានឲ្យយល់
ឡើយ។ ១២អ្នកណាមានហើយព្រះជាម្ចាស់នឹង
ប្រទានថែមទៀត ដើម្បីឲ្យអ្នកនោះបានបរិបូណ៌រីឯ
អ្នកដែលគ្មាន ព្រះអង្គនឹងហូតយកអ្វីៗដែលអ្នកនោះ
មានផង។ ១៣ហេតុនេះហើយបានជាខ្ញុំនិយាយទៅគេ
ដោយប្រើពាក្យប្រស្នា គឺទោះបីគេមើលក៏ពុំឃើញ
ទោះបីគេស្ដាប់ក៏ពុំឮ ហើយក៏ពុំយល់ដែរ ១៤ដើម្បីឲ្យ
បានស្របនឹងសេចក្ដីដែលព្យាការី*អេសាយថ្លែងទុក
អំពីពួកគេថា៖

*"អ្នករាល់គ្នាស្ដាប់មែន*
*តែពុំឮទេ ហើយក៏ពុំយល់ផង។*
*អ្នករាល់គ្នាមើលមែន តែមិនឃើញសោះ*
១៥ *ដ្បិតចិត្តប្រជារាស្ត្រនេះរឹងណាស់*
*ហើយត្រចៀកគេក៏ធ្ងន់។ គេនាំគ្នាបិទភ្នែកមិន*
*ឲ្យមើលឃើញ*
*មិនឲ្យត្រចៀកស្ដាប់ឮ*
*មិនឲ្យប្រាជ្ញាយល់*
*ហើយមិនចង់វិលមកវិញទេ*
*ក្រែងលោយើងប្រោសគេឲ្យបានជា[គ]។*

១៦រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នាមានសុភមង្គល
ហើយ ព្រោះភ្នែកអ្នករាល់គ្នាមើលឃើញ ត្រចៀកអ្នក
រាល់គ្នាស្ដាប់ឮ! ១៧ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់
ថា មានព្យាការីនិងមនុស្សសុចរិត*ជាច្រើនមាន
បំណង ចង់ឃើញហេតុការណ៍ដែលអ្នករាល់គ្នា
ឃើញនេះដែរ តែមិនបានឃើញទេ គេចង់ឮសេចក្ដី
ដែលអ្នករាល់គ្នាឮនេះដែរ តែមិនបានឮឡើយ!។

១៨ដូច្នេះសុំស្ដាប់អត្ថន័យនៃប្រស្នា អំពីអ្នក
ព្រោះស្រូវដូចតទៅ៖ ១៩អ្នកដែលបានឮព្រះបន្ទូល
អំពីព្រះរាជ្យ* តែមិនយល់ ប្រៀបបាននឹងអ្នកដែល
ទទួលគ្រាប់ពូជនៅតាមផ្លូវ ដ្បិតមារកំណាចមកឆក់
យកព្រះបន្ទូល ដែលបានធ្លាក់ក្នុងចិត្តគេនោះទៅ។

២០រីឯអ្នកដែលទទួលគ្រាប់ពូជលើដីមានថ្ម គឺអស់អ្នក
ដែលបានឮព្រះបន្ទូលហើយ ក៏ទទួលយកភ្លាមដោយ
អំណរ ២១ប៉ុន្តែគេពុំបានទុកឲ្យព្រះបន្ទូលចាក់ឫសនៅ
ក្នុងខ្លួនគេឡើយ គេជាប់ចិត្តតែមួយភ្លែតប៉ុណ្ណោះ លុះ
ដល់មានទុក្ខលំបាកឬត្រូវគេបៀតបៀន ព្រោះតែព្រះ
បន្ទូល គេក៏បោះបង់ចោលជំនឿភ្លាម។ ២២អ្នកដែល
ទទួលគ្រាប់ពូជក្នុងដីមានបន្លា គឺអ្នកដែលបានឮព្រះ
បន្ទូល ប៉ុន្តែការខ្វល់ខ្វាយអំពីជីវិតក្នុងលោកីយ៍ ចិត្ត
លោភលន់ចង់បានទ្រព្យសម្បត្តិ រួបរឹតព្រះបន្ទូលមិន
ឲ្យបង្កើតផលបានឡើយ។ ២៣រីឯអ្នកដែលទទួល
គ្រាប់ពូជក្នុងដីមានជីជាតិល្អ គឺអស់អ្នកដែលបានឮ
ព្រះបន្ទូល ហើយយល់ គេបង្កបង្កើតផលខ្លះបានមួយ
ជាមួយរយ ខ្លះបានមួយជាហុកសិប និងខ្លះទៀតបាន
មួយជាសាមសិប»។

## ប្រស្នាអំពីស្រងែ

២៤ព្រះយេស៊ូមានព្រះបន្ទូល ជាពាក្យប្រស្នា
មួយទៀតទៅគេថា៖ «ព្រះរាជ្យ*នៃស្ថានបរមសុខ*
ប្រៀបបាននឹងបុរសម្នាក់ ដែលបានព្រោះគ្រាប់ពូជល្អ
ទៅក្នុងស្រែរបស់គាត់។ ២៥ពេលមនុស្សម្នាដេកលក់
អស់ មារសត្រូវរបស់គាត់បានមកព្រោះស្រងែនៅក្នុង
ស្រែនោះដែរ រួចចេញបាត់ទៅ។ ២៦ពេលស្រូវដុះ
ឡើងដាក់គ្រាប់ ស្រងែក៏ដុះឡើងដែរ។ ២៧ពួកអ្នក
បម្រើចូលមកជម្រាបម្ចាស់ស្រែថា៖ "លោកម្ចាស់!
លោកបានព្រោះតែគ្រាប់ពូជល្អក្នុងស្រែសោះ ចុះ
ស្រងែនេះមកពីណា?"។ ២៨ម្ចាស់តបវិញថា៖ "ពិត
ជាមានមារសត្រូវមកព្រោះហើយ!"។ ពួកអ្នកបម្រើ
សួរលោកទៀតថា៖ "តើលោកចង់ឲ្យយើងខ្ញុំទៅដក
ស្រងែនោះចេញឬ?"។ ២៩ម្ចាស់តបថា៖ "កុំអី! បើ
អ្នករាល់គ្នាដកក្រែងលោដោយស្រូវមកជាមួយដែរ
៣០ទុកឲ្យវាដុះជាមួយគ្នារហូតដល់ស្រូវទុំចុះ ពេល
នោះខ្ញុំនឹងប្រាប់ពួកអ្នកច្រូតថា ចូរប្រមូលស្រងែចង
ជាបាច់ យកទៅដុតចោលជាមុនសិន រួចសឹមប្រមូល
ស្រូវដាក់ជង្រុកឲ្យខ្ញុំ"»។

## ប្រស្នាអំពីគ្រាប់ពូជល្អិត និង មេនំប៉័ង

(ម៉ាកុស ៤.៣០-៣៤ លូកា ១៣.១៨-២១)

៣១ព្រះយេស៊ូមានព្រះបន្ទូល ជាពាក្យប្រស្នា
មួយទៀតទៅគេថា៖ «ព្រះរាជ្យនៃស្ថានបរមសុខ
ប្រៀបបីដូចជាគ្រាប់ពូជម៉្យាងដ៏ល្អិត ដែលបុរសម្នាក់
យកទៅដាំក្នុងចម្ការរបស់ខ្លួន។ ៣២គ្រាប់ពូជនោះតូច
ជាងគ្រាប់ពូជទាំងអស់ ប៉ុន្តែពេលដុះឡើងវាធំជាង
ដំណាំឯទៀតៗ គឺទៅជាដើមឈើមួយយ៉ាងធំហើយ
បក្សាបក្សីមកធ្វើសំបុក ស្នាក់អាស្រ័យនៅតាមមែក
របស់វា»។

៣៣ ព្រះអង្គមានព្រះបន្ទូល ជាពាក្យប្រស្នាមួយ
ទៀតថា៖ «ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបីដូចជា
មេនំប៉័ង ដែលស្ត្រីម្នាក់យកទៅលាយនឹងម្សៅពីរតៅ
ធ្វើឲ្យម្សៅនោះដោរឡើង»។

៣៤ព្រះយេស៊ូមានព្រះបន្ទូល អំពីសេចក្ដីទាំង
នេះទៅកាន់មហាជន ជាពាក្យប្រស្នាទាំងអស់ គឺព្រះ
អង្គមិនដែលមានព្រះបន្ទូលទៅគេដោយឥតប្រើពាក្យ
ប្រស្នាឡើយ ៣៥ដើម្បីឲ្យស្របនឹងសេចក្ដីដែលមាន
ចែងទុក តាមរយៈពួកព្យាការី*ថា៖

*«យើងនឹងនិយាយទៅគេជាពាក្យប្រស្នា*
*យើងនឹងប្រកាសសេចក្ដីលាក់កំបាំង*
*តាំងពីដើមកំណើតពិភពលោកមក*
*ឲ្យគេដឹង»*[ណ] ។

## ព្រះយេស៊ូពន្យល់ អត្ថន័យប្រស្នាអំពីស្រងែ

៣៦ពេលនោះ ព្រះយេស៊ូយាងចេញពីមហាជន
ចូលទៅក្នុងផ្ទះ។ ពួកសាវ័ក*នាំគ្នាចូលមកគាល់ព្រះ
អង្គ ទូលថា៖ «សូមព្រះគ្រូបកស្រាយប្រស្នាអំពី
ស្រងែក្នុងស្រែ ឲ្យយើងខ្ញុំបានយល់អត្ថន័យផង»។
៣៧ ព្រះអង្គមានព្រះបន្ទូលតបទៅគេវិញថា៖ «អ្នក

ព្រោះគ្រាប់ពូជល្អ គឺបុត្រមនុស្ស* ៣៨ ស្រែគឺពិភព
លោក គ្រាប់ពូជល្អគឺអ្នកដែលត្រូវចូលទៅក្នុងព្រះ
រាជ្យ រីឯស្រងែវិញ គឺកូនចៅរបស់មារ*កំណាច។
៣៩ សត្រូវដែលសាបព្រោះស្រងែ គឺមាររដូវចម្រូត គឺ
អវសានកាលនៃពិភពលោក ហើយអ្នកច្រូត គឺទេវ
ទូត*។ ៤០គេច្រូតស្រងែយកទៅដុតក្នុងភ្លើងយ៉ាង
ណា នៅអវសានកាលនៃពិភពលោកក៏នឹងកើតមាន
យ៉ាងនោះដែរ។ ៤១បុត្រមនុស្សនឹងចាត់ទេវទូតរបស់
លោកឲ្យមក។ ទេវទូតទាំងនោះនឹងប្រមូលពួកអ្នក
ដែលនាំគេឲ្យប្រព្រឹត្តអំពើបាប និងពួកអ្នកដែលបាន
ប្រព្រឹត្តអំពើទុច្ចរិត យកចេញពីព្រះរាជ្យ ៤២ បោះទៅ
ក្នុងភ្លើងដែលឆេះសន្ធោសន្ធៅហើយនៅទីនោះ មាន
តែសម្រែក យំសោក ខឹងសង្កៀតធ្មេញ។ ៤៣រីឯអ្នក
សុចរិត*វិញ គេនឹងស្ថិតនៅក្នុងព្រះរាជ្យនៃព្រះបិតា
របស់គេ ទាំងបញ្ចេញរស្មីភ្លឺដូចព្រះអាទិត្យ។ អ្នកណា
ឮពាក្យនេះ សូមយកទៅពិចារណាចុះ!»។

## ប្រស្នាស្ដីអំពីកំណប់និងអំពីពេជ្រដ៏មាន តម្លៃ

៤៤«ព្រះរាជ្យស្ថានបរមសុខ* ប្រៀបបីដូចជា
កំណប់ដែលគេកប់ទុកនៅក្នុងស្រែមួយ។ មានបុរស
ម្នាក់រកកំណប់នោះឃើញ ហើយកប់ទុកវិញ។ គាត់
មានចិត្តត្រេកអរជាខ្លាំងក៏ចេញទៅលក់ទ្រព្យសម្បត្តិ
ទាំងប៉ុន្មានដែលគាត់មាន យកប្រាក់ទិញដីស្រែ
នោះ។

៤៥ ម្យ៉ាងទៀត ព្រះរាជ្យនៃស្ថានបរមសុខប្រៀប
បីដូចជាអ្នកជំនួញម្នាក់ ដែលស្វែងរកទិញពេជ្រ [ត]
ល្អៗ។ ៤៦កាលបានឃើញពេជ្រមួយគ្រាប់ដ៏មានតម្លៃ
លើសលប់ហើយ គាត់ក៏ទៅលក់អ្វីៗទាំងប៉ុន្មានដែល
គាត់មាន យកប្រាក់មកទិញពេជ្រនោះ»។

## ប្រស្នាស្ដីអំពីអួន

៤៧«ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបីដូចជា
អួនមួយដែលគេរាយក្នុងសមុទ្រ ហើយជាប់បានត្រី
គ្រប់យ៉ាង។ ៤៨ពេលជាប់បានត្រីពេញហើយគេអូស
អួននោះឡើងមកលើគោក រួចអង្គុយរើសត្រីល្អៗដាក់
ក្នុងកញ្ជេរ រីឯត្រីមិនល្អវិញ គេបោះចោល។៤៩នៅ
អវសានកាលនៃពិភពលោក ក៏នឹងកើតមានដូច្នេះដែ
រ។ ពួកទេវទូត*នាំគ្នាមក ញែកមនុស្សទុច្ចរិតចេញពី
ចំណោមមនុស្សសុចរិត ៥០រួចបោះមនុស្សទុច្ចរិតទាំង
នោះ ទៅក្នុងភ្លើងដែលឆេះសន្ធោសន្ធៅ ហើយនៅទី
នោះមានតែសម្រែកយំសោក ខឹងសង្កៀតធ្មេញ។

៥១តើអ្នករាល់គ្នាយល់សេចក្ដីទាំងនេះ ឬទេ?»
ពួកសាវ័កទូលព្រះអង្គថា៖ «បាទ យល់!»។

៥២ព្រះអង្គមានព្រះបន្ទូលទៅគេទៀត ថា៖ «
ហេតុនេះហើយបានជាពួកធម្មាចារ្យដែល បានទទួល
ការអប់រំអំពីព្រះរាជ្យនៃស្ថានបរមសុខ*ប្រៀបបានទៅ
នឹងម្ចាស់ផ្ទះដែលយកទ្រព្យទាំងចាស់ ទាំងថ្មី ចេញពី
ឃ្លាំងរបស់គាត់ដូច្នោះដែរ»។

## អ្នកភូមិណាសារ៉ែតមិនព្រមទទួលស្គាល់ ព្រះយេស៊ូ

(ម៉ាកុស ៦.១-៦ លូកា ៤.១៦-៣០)

៥៣កាលព្រះយេស៊ូមានព្រះបន្ទូល ជាពាក្យ
ប្រស្នាទាំងនេះចប់សព្វគ្រប់ហើយ ព្រះអង្គក៏យាង
ចេញពីទីនោះ ៥៤ត្រឡប់ទៅភូមិស្រុករបស់ព្រះអង្គវិ
ញ។ ព្រះអង្គបង្រៀនអ្នកស្រុកនៅក្នុងធម្មសាលា*
របស់គេ ធ្វើឲ្យគេងឿងឆ្ងល់គ្រប់ៗគ្នា។ គេពោលថា៖
«តើគាត់បានទទួលប្រាជ្ញា និងឫទ្ធានុភាពធ្វើការអ
ស្ចារ្យទាំងនេះមកពីណា? ៥៥អ្នកនេះជាកូនរបស់ជាង
ឈើ ហើយម្ដាយរបស់គាត់ឈ្មោះនាងម៉ារីបងប្អូន
គាត់ឈ្មោះយ៉ាកុបយ៉ូសែប ស៊ីម៉ូន យូដាទេតើ! ៥៦
ប្អូនស្រីរបស់គាត់ទាំងប៉ុន្មានរស់នៅក្នុងភូមិជាមួយ
យើងដែរ។ ដូច្នេះគាត់ដឹងសេចក្ដីទាំងនេះពីណា
មក?»។ ៥៧ហេតុនេះហើយបានជាគេមិនអាចជឿ

ព្រះអង្គបាន។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ធម្មតាគេមើលងាយព្យាការី តែក្នុងស្រុកកំណើត
និងក្នុងផ្ទះរបស់លោកប៉ុណ្ណោះ!»។ ៥៨នៅទីនោះ
ព្រះយេស៊ូពុំបានធ្វើការអស្ចារ្យច្រើនឡើយព្រោះគេ
គ្មានជំនឿ។

## ស្ដេចហេរ៉ូដសម្លាប់លោកយ៉ូហានបាទីស្ដ

(ម៉ាកុស ៦.១៤-២៩ លូកា ៩.៧-៩)

១៤ ១នៅគ្រានោះ ព្រះបាទហេរ៉ូដជាស្ដេចអនុរាជ*
បានជ្រាបអំពីព្រះកិត្តិនាមរបស់ព្រះយេស៊ូ ២ទ្រង់មាន
រាជឱង្ការ ទៅពួកបរិពារថា៖ «យ៉ូហានបាទីស្ដបាន
រស់ឡើងវិញហើយ បានជាគាត់មានឫទ្ធានុភាព
សម្ដែងការអស្ចារ្យ យ៉ាងនេះ»។

៣ព្រះបាទហេរ៉ូដបានចាប់លោកយ៉ូហាន ដាក់
ច្រវាក់ យកទៅឃុំឃាំង ដោយទ្រង់ជឿតាមពាក្យព្រះ
នាងហេរ៉ូឌីយ៉ាដា ដែលត្រូវជាមហេសីរបស់ស្ដេចភី
លីពជាអនុជ* ៤ព្រោះលោកយ៉ូហានបានបន្ទោស
ស្ដេចថា «ព្រះករុណាគ្មានសិទ្ធិយកព្រះនាងមកធ្វើ
ជាមហេសីឡើយ»។ ៥ ស្ដេចហេរ៉ូដចង់សម្លាប់លោក
យ៉ូហាន តែទ្រង់ខ្លាចបណ្ដាជន ព្រោះពួកគេចាត់ទុក
លោកជាព្យាការី*មួយរូប។

៦នៅថ្ងៃបុណ្យខួបចំរើនព្រះជន្ម របស់ព្រះបាទ
ហេរ៉ូដបុត្រីរបស់ព្រះនាងហេរ៉ូឌីយ៉ាដា ចូលមករាំនៅ
មុខភ្ញៀវ ធ្វើឲ្យស្ដេចពេញចិត្តយ៉ាងខ្លាំង ៧រហូតដល់
ស្បថស្បែសន្យានឹងនាងថា បើនាងចង់បានអ្វីស្ដេច
ប្រទានឲ្យទាំងអស់។ ៨នាងទូលទៅស្ដេចវិញតាម
ពាក្យបង្គាប់របស់មាតាថា៖ «សូមទ្រង់ប្រទានក្បាល
របស់យ៉ូហានបាទីស្ដ ដាក់លើថាសមកឲ្យខ្ញុំម្ចាស់!»
។

៩ព្រះរាជាព្រួយព្រះហឫទ័យក្រៃលែង ព្រោះ
ទ្រង់បានស្បថនៅមុខភ្ញៀវទាំងអស់ ជ្រុលហួសទៅ
ហើយ។ ទ្រង់ក៏បញ្ជាឲ្យគេធ្វើតាមពាក្យសុំរបស់នាង
១០គឺចាត់ទាហានឲ្យទៅកាត់កលោកយ៉ូហាន ១១យក
ក្បាលដាក់លើថាសមួយ ប្រគល់ឲ្យនាង រួចនាង
យកទៅថ្វាយមាតា។

១២ពួកសិស្សរបស់លោកយ៉ូហាន មកយកសព
លោកទៅបញ្ចុះ ហើយនាំគ្នាយកដំណឹងទៅទូលព្រះ
យេស៊ូ។

## ព្រះយេស៊ូប្រទាននំប៉័ង ឲ្យមនុស្សប្រាំពាន់នាក់បរិភោគ

(ម៉ាកុស ៦.៣០-៤៤ លូកា ៩.១០-១៧ យ៉ូហាន ៦.១-១៤)

១៣កាលព្រះយេស៊ូបានជ្រាបដំណឹងនេះ ទ្រង់ក៏
យាងចុះទូក ចាកចេញជាមួយពួកសាវ័ក* ឆ្ពោះទៅ
កាន់កន្លែងមួយស្ងាត់ដាច់ឡែកពីបណ្ដាជន។ ប៉ុន្តែ
មហាជនបានដឹង ហើយនាំគ្នាចេញពីក្រុងនានាដើរ
ទៅតាមព្រះអង្គ។ ១៤កាលព្រះយេស៊ូយាងឡើងពី
ទូក ទតឃើញមហាជនដ៏ច្រើនយ៉ាងនេះព្រះអង្គមាន
ព្រះហឫទ័យ អាណិតអាសូរគេពន់ពេកណាស់ហើយ
ទ្រង់ក៏ប្រោសអ្នកជំងឺឲ្យបានជា។

១៥ពេលនោះ ថ្ងៃជ្រេណាស់ហើយ សាវ័កនាំគ្នា
ចូលមកជិតព្រះអង្គទូលថា៖ «ទីនេះស្ងាត់ណាស់
ហើយក៏ជិតយប់ផង សូមប្រាប់បណ្ដាជនទាំងនេះឲ្យ
ត្រឡប់ទៅវិញ រកទិញម្ហូបអាហារនៅតាមភូមិ»។១៦
ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូល ទៅកាន់សាវ័កថា៖ «
មិនបាច់ឲ្យគេត្រឡប់ទៅវិញទេ ចូរអ្នករាល់គ្នាយក
ម្ហូបអាហារឲ្យគេបរិភោគទៅ»។ ១៧សាវ័កទូលព្រះ
អង្គថា៖ «យើងខ្ញុំមាននំប៉័ងតែប្រាំដុំ និងត្រីងៀតពីរ
កន្ទុយប៉ុណ្ណោះ»។ ១៨ព្រះអង្គមានព្រះបន្ទូលថា៖ «
ចូរយកនំប៉័ងនិងត្រីនោះមកឲ្យខ្ញុំ»។ ១៩បន្ទាប់មក
ព្រះអង្គប្រាប់បណ្ដាជនឲ្យអង្គុយលើស្មៅ ព្រះអង្គ
យកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់
ទ្រង់ងើបព្រះភ័ក្ត្រឡើងលើ សរសើរតម្កើងព្រះជា
ម្ចាស់ ហើយកាច់នំប៉័ងប្រទានឲ្យពួកសាវ័ក* ពួកសាវ័

កក៏ចែកឲ្យបណ្ដាជនបរិភោគ។ ២០អ្នកទាំងនោះបាន
បរិភោគឆ្អែតគ្រប់ៗគ្នា ហើយពួកសាវ័កប្រមូលនំបុ័ង
ដែលនៅសល់ ដាក់បានពេញដប់ពីរល្អី។ ២១អស់អ្នក
ដែលបានបរិភោគនំបុ័ង មានប្រុសៗទាំងអស់
ប្រមាណប្រាំពាន់នាក់ ឥតគិតស្រីៗនិងក្មេងៗផង
ទេ។

## ព្រះយេស៊ូយាងលើទឹកសមុទ្រ

(ម៉ាកុស៦.៤៥-៥២ យ៉ូហាន៦.១៥-២១)

២២រំពេចនោះ ព្រះយេស៊ូបញ្ជាពួកសាវ័ក*ឲ្យចុះ
ទូក ឆ្លងទៅត្រើយម្ខាងមុនព្រះអង្គ ហើយព្រះអង្គក៏
ប្រាប់មហាជន ឲ្យវិលត្រឡប់ទៅវិញដែរ។ ២៣កាល
ព្រះអង្គឲ្យមហាជនចេញផុតអស់ហើយ ព្រះយេស៊ូ
យាងឡើងទៅលើភ្នំ ដាច់ឡែកពីគេ ដើម្បីអធិស្ឋាន*
។ លុះដល់យប់ ទ្រង់គង់នៅទីនោះតែមួយព្រះអង្គឯ
ង។

២៤ពេលនោះ ទូកចេញឆ្ងាយពីច្រាំង ហើយក៏
ត្រូវរលកបក់បោក ព្រោះបញ្ច្រាសខ្យល់។ ២៥ដល់
ពេលជិតភ្លឺ ព្រះអង្គយាងលើទឹកឆ្ពោះទៅរកពួកសាវ័
ក។ ២៦កាលពួកគេឃើញព្រះអង្គយាងលើទឹកសមុទ្រ
ដូច្នេះ គេភ័យរន្ធត់ ហើយស្រែកឡើងថា «ខ្មោច
លង!» ព្រោះគេភ័យពេក។ ២៧រំពេចនោះព្រះយេស៊ូ
មានព្រះបន្ទូលទៅគេថា៖ «ចូរតាំងចិត្តក្លាហានឡើង
ខ្ញុំទេតើកុំខ្លាចអី!»។ ២៨លោកសិលាទូលព្រះអង្គថា
៖ «លោកម្ចាស់ប្រសិនបើពិតជាលោកមែន សូម
បញ្ជាឲ្យខ្ញុំអាចដើរលើទឹកទៅរកលោកផង»។ ២៩
ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អញ្ជើញ
មក!» លោកសិលាក៏ចុះពីទូកដើរលើទឹកឆ្ពោះទៅរក
ព្រះយេស៊ូ។ ៣០ប៉ុន្តែកាលលោកឃើញខ្យល់បក់ខ្លាំង
លោកភ័យណាស់ហើយចាប់ផ្ដើមលិចទៅក្នុងទឹក។
លោកស្រែកឡើងថា៖ «លោកម្ចាស់អើយ សូមជួយ
ខ្ញុំផង!»។ ៣១ព្រះយេស៊ូក៏លូកព្រះហស្ដទាញគាត់
ឡើងភ្លាម ទាំងមានព្រះបន្ទូលថា៖ «មនុស្សមាន
ជំនឿតិចអើយ ហេតុដូចម្ដេចបានជាអ្នកមិនទុកចិត្ត
ដូច្នេះ?»។ ៣២បន្ទាប់មកព្រះអង្គនិងលោកសិលា
ចូលមកក្នុងទូក ហើយខ្យល់ក៏ស្ងប់។ ៣៣អ្នកនៅក្នុង
ទូកនាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ ទាំងពោលថា៖ «
ព្រះអង្គពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន!»។

៣៤ព្រះយេស៊ូនិងពួកសាវ័ក* បានឆ្លងទៅដល់
ត្រើយម្ខាង ត្រង់ស្រុកកេនេសារ៉ែត។ ៣៥អ្នកស្រុក
នោះស្គាល់ព្រះអង្គភ្លាម ហើយយកដំណឹងទៅផ្សព្វ
ផ្សាយពាសពេញតំបន់ទាំងមូល។ គេនាំអ្នកជំងឺទាំង
អស់មករកព្រះអង្គ ៣៦អង្វរសូមគ្រាន់តែពាល់ជាយ
ព្រះពស្ត្ររបស់ព្រះអង្គប៉ុណ្ណោះ អស់អ្នកដែលបាន
ពាល់ បានជាសះស្បើយ[៩]គ្រប់ៗគ្នា។

## ពួកខាងគណៈផារីស៊ីនិងទំនៀមទម្លាប់

(ម៉ាកុស៧.១-១៣)

១៥ ១មានពួកខាងគណៈផារីស៊ី និងពួកធម្មាចារ្យពី
ក្រុងយេរូសាឡឹម ចូលមកគាល់ព្រះយេស៊ូ ហើយ
ទូលថា៖ ២«ហេតុអ្វីបានជាសិស្សរបស់លោក មិន
គោរពតាមទំនៀមទម្លាប់របស់ចាស់បុរាណ គឺមិនធ្វើ
ពិធីលាងដៃ មុនពេលបរិភោគដូច្នេះ?»។ ៣ព្រះអង្គ
មានព្រះបន្ទូលតបទៅគេវិញថា៖ «ចុះអ្នករាល់គ្នា
ហេតុដូចម្ដេចបានជាអ្នករាល់គ្នាប្រព្រឹត្តល្មើសនឹងវិ
ន័យរបស់ព្រះជាម្ចាស់ ទៅកាន់តាមទំនៀមទម្លាប់
របស់អ្នករាល់គ្នាវិញដូច្នេះ?។ ៤ព្រះជាម្ចាស់មានព្រះ
បន្ទូលថា៖ "ចូរគោរពមាតាបិតារបស់អ្នក អ្នកណាជេរ
ប្រទេចផ្ដាសាមាតាបិតារបស់ខ្លួន នឹងត្រូវមានទោស
ដល់ជីវិត"[៩]។ ៥រីឯអ្នករាល់គ្នាវិញ បែរជាពោលថា៖
បើអ្នកណានិយាយទៅឪពុកម្ដាយថា "អ្វីៗដែលខ្ញុំត្រូវ
ជូនលោកឪពុកអ្នកម្ដាយនោះ ខ្ញុំបានទុកថ្វាយព្រះជា
ម្ចាស់រួចទៅហើយ" ៦អ្នកនោះមិនបាច់គោរពឪពុក
ម្ដាយទេ។ ត្រង់ហ្នឹងហើយ ដែលអ្នករាល់គ្នាបំបាត់

តម្លៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទៅប្រព្រឹត្តតាម
ទំនៀមទម្លាប់របស់អ្នករាល់គ្នាវិញ!។ ៧មនុស្សមាន
ពុតអើយ ពាក្យដែលព្យាការី*អេសាយថ្លែងទុកអំពី
អ្នករាល់គ្នាត្រូវណាស់គឺ៖

៨ *"ប្រជារាស្ត្រនេះគោរពយើងតែបបូរមាត់*
*រីឯចិត្តគេនៅឆ្ងាយពីយើង។*
៩ *គេថ្វាយបង្គំយើងឥតបានការអ្វីសោះ*
*ព្រោះគេបង្រៀនតែក្បួនច្បាប់របស់មនុស្ស*
*ប៉ុណ្ណោះ"*[ឥ]»។

## មូលហេតុដែលបណ្ដាលឲ្យមនុស្សមិនបរិសុទ្ធ

(ម៉ាកុស ៧.១៤-២៣)

១០បន្ទាប់មក ព្រះយេស៊ូត្រាស់ហៅបណ្ដាជន
រួចមានព្រះបន្ទូលទៅគេថា៖ «ចូរស្ដាប់ ហើយយល់
ឲ្យច្បាស់ថា ១១អ្វីៗដែលចូលតាមមាត់មនុស្សពុំដែល
ធ្វើឲ្យមនុស្សទៅជាមិនបរិសុទ្ធ[ន]ឡើយ ផ្ទុយទៅវិញ
មានតែអ្វីៗដែលចេញពីមាត់មនុស្សប៉ុណ្ណោះ ដែលធ្វើ
ឲ្យមនុស្សត្រឡប់ទៅជាមិនបរិសុទ្ធ»។
១២ពេលនោះ សាវ័ក*នាំគ្នាចូលមកជិតព្រះអង្គ
ហើយទូលថា៖ «សូមព្រះគ្រូជ្រាប ពួកខាងគណៈផា
រីស៊ី*ទាស់ចិត្តណាស់ មកពីឮព្រះគ្រូមានប្រសាសន៍
ដូច្នេះ»។ ១៣ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញ
ថា៖ «ព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខ*
នឹងដករុក្ខជាតិទាំងឡាយណាដែលព្រះអង្គមិនបាន
ដាំ។ ១៤កុំអំពល់នឹងគេធ្វើអ្វី អ្នកទាំងនោះសុទ្ធតែជា
មនុស្សខ្វាក់ ដឹកនាំមនុស្សខ្វាក់។ បើមនុស្សខ្វាក់ដឹក
ដៃមនុស្សខ្វាក់គេមុខជាធ្លាក់រណ្ដៅទាំងពីរនាក់មិន
ខាន»។ ១៥លោកសិលាទូលព្រះអង្គថា៖ «សូមព្រះ
គ្រូបកស្រាយពាក្យប្រស្នានេះឲ្យយើងខ្ញុំយល់ផង»។
១៦ព្រះអង្គមានព្រះបន្ទូលថា៖ «អ្នករាល់គ្នានៅតែ
គ្មានប្រាជ្ញាដូចគេដែរឬ! ១៧អ្នករាល់គ្នាត្រូវយល់ថា
អ្វីៗដែលចូលតាមមាត់មនុស្សត្រូវចូលទៅក្នុងពោះរួច
ធ្លាក់ទៅទីបន្ទោរបង់! ១៨ផ្ទុយទៅវិញ អ្វីៗដែលចេញពី
មាត់មនុស្សសុទ្ធតែផុសចេញពីចិត្តមក គឺសេចក្ដីនោះ
ឯង ដែលធ្វើឲ្យមនុស្សទៅជាមិនបរិសុទ្ធ* ១៩ដ្បិត
គំនិតអាក្រក់ ការកាប់សម្លាប់ អំពើផិតក្បត់ កាម
គុណថោកទាប ការលួចប្លន់ ពាក្យកុហក ពាក្យត្មះតិះ
ដៀល សុទ្ធតែចេញមកពីចិត្តមនុស្សទាំងអស់ ២០គឺ
ការទាំងនេះហើយដែលធ្វើឲ្យមនុស្សក្លាយទៅជាមិន
បរិសុទ្ធ។ រីឯការបរិភោគដោយមិនបានធ្វើពិធីលាង
ដៃនោះ ឥតធ្វើឲ្យមនុស្សក្លាយទៅជាមិនបរិសុទ្ធ
ឡើយ»។

## ស្ត្រីសាសន៍ដទៃម្នាក់ជឿព្រះយេស៊ូ

(ម៉ាកុស ៧.២៤-៣០)

២១បន្ទាប់មក ព្រះយេស៊ូយាងចាកចេញពីទី
នោះឆ្ពោះទៅកាន់តំបន់ជិតក្រុងទីរ៉ូស និងក្រុងស៊ីដូ
ន។២២មានស្ត្រីសាសន៍កាណានម្នាក់ ដែលរស់នៅ
ស្រុកនោះ ចូលមកគាល់ព្រះអង្គ ហើយទូលអង្វរថា៖
«ឱព្រះអម្ចាស់ ជាព្រះរាជវង្សរបស់ព្រះបាទដាវីឌ
អើយ សូមអាណិតមេត្តាខ្ញុំម្ចាស់ផង! កូនស្រីខ្ញុំម្ចាស់
ត្រូវខ្មោចចូល បណ្ដាលឲ្យវេទនាខ្លាំងណាស់»។ ២៣
ព្រះយេស៊ូពុំបានឆ្លើយតបនឹងនាងឡើយ។ ពួកសាវ័ក
នាំគ្នាចូលមកជិតព្រះអង្គទូលថា៖ «សូមព្រះគ្រូ
ប្រោសប្រណីដល់នាងផង ព្រោះនាងចេះតែស្រែក
អង្វរពីក្រោយយើង»។ ២៤ព្រះអង្គមានព្រះបន្ទូលតប
ថា៖ «ព្រះជាម្ចាស់បានចាត់ឲ្យខ្ញុំមករក តែអស់អ្នក
ដែលវង្វេង ក្នុងចំណោមជនជាតិអ៊ីស្រាអែល
ប៉ុណ្ណោះ»។
២៥ប៉ុន្តែ ស្ត្រីនោះចូលមកក្រាបទៀបព្រះបាទា
ព្រះអង្គ ហើយទូលថា៖ «ព្រះអម្ចាស់អើយ សូមជួយ
ខ្ញុំម្ចាស់ផង!»។ ២៦ព្រះអង្គមានព្រះបន្ទូលតបថា៖ «
មិនគួរយកអាហាររបស់កូនចៅបោះទៅឲ្យកូនឆ្កែស៊ី

ឡើយ»។ ២៧នាងទូលព្រះអង្គថា៖ «ពិតមែនហើយ
ព្រះអម្ចាស់! ប៉ុន្តែកូនឆ្កែស៊ីកំទេចអាហារដែលជ្រុះពីតុ
របស់ម្ចាស់វា»។ ២៨ព្រះយេស៊ូក៏មានព្រះបន្ទូលទៅ
នាងថា៖ «នាងអើយ នាងមានជំនឿមាំមួនណាស់
ដូច្នេះសូមឲ្យបានសម្រេចតាមចិត្តនាងប្រាថ្នាចុះ!»។
កូនស្រីរបស់នាងបានជាតាំងពីពេលនោះមក។

## ព្រះយេស៊ូប្រោសអ្នកមានជំងឺផ្សេងៗឲ្យបានជា

(ម៉ាកុស ៧.៣១)

២៩ព្រះយេស៊ូចាកចេញពីទីនោះ ឆ្ពោះទៅកាន់
ឆ្នេរសមុទ្រកាលីឡេ។ បន្ទាប់មក ព្រះអង្គយាងឡើង
ទៅលើភ្នំ លុះយាងដល់ ហើយព្រះអង្គគង់ចុះ ៣០
មានមហាជនច្រើនកុះករនាំគ្នាចូលមករកព្រះអង្គ
ទាំងនាំមនុស្សខ្វិន មនុស្សខ្វាក់ មនុស្សពិការជើង
មនុស្សគថ្លង់ និងអ្នកមានជំងឺឯទៀតៗ មកជាមួយ។
គេដាក់អ្នកទាំងនោះ នៅទៀបព្រះបាទាព្រះអង្គ
ហើយព្រះអង្គប្រោសគេ ឲ្យបានជាទាំងអស់គ្នា។៣១
ពេលឃើញមនុស្សគនិយាយបាន មនុស្សពិការជើង
ជាដូចធម្មតា មនុស្សខ្វិនដើរបាន និងមនុស្សខ្វាក់
មើលឃើញ មហាជននាំគ្នាកោតស្ញប់ស្ញែងក្រៃលែង
ទាំងលើកតម្កើងសិរីរុងរឿងរបស់ព្រះនៃជនជាតិអ៊ី
ស្រាអែលផង។

## ព្រះយេស៊ូប្រទាននំបុ័ងឲ្យមនុស្សបួនពាន់នាក់បរិភោគ

(ម៉ាកុស ៨.១-១០)

៣២ព្រះយេស៊ូត្រាស់ហៅពួកសាវ័ក*មក ទ្រង់
មានព្រះបន្ទូលថា៖ «ខ្ញុំអាណិតអាសូរបណ្ដាជននេះ
ពន់ពេកណាស់ ដ្បិតគេនៅជាមួយខ្ញុំអស់រយៈពេលបី
ថ្ងៃមកហើយ ហើយគ្មានអ្វីបរិភោគសោះ។ ខ្ញុំមិនចង់
ឲ្យគេត្រឡប់ទៅវិញទាំងពោះទទេឡើយ ក្រែងគេ
អស់កម្លាំងដួលតាមផ្លូវ»។ ៣៣ពួកសាវ័កទូលព្រះអង្គ
ថា៖ «នៅទីនេះស្ងាត់ណាស់ តើយើងបានម្ហូប
អាហារឯណា ឲ្យបណ្ដាជនច្រើនយ៉ាងនេះបរិភោគ
គ្រាន់?»។ ៣៤ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «
តើអ្នករាល់គ្នាមាននំបុ័ងប៉ុន្មានដុំ?»។ពួកគេទូលថា៖
«មានប្រាំពីរដុំ និងមានត្រីតូចៗខ្លះដែរ»។៣៥ព្រះអង្គ
ក៏ប្រាប់បណ្ដាជន ឲ្យអង្គុយផ្ទាល់នឹងដី ៣៦ទ្រង់យកនំ
បុ័ងទាំងប្រាំពីរដុំ និងត្រីមកកាន់អរព្រះគុណព្រះជា
ម្ចាស់ ហើយកាច់ប្រទានឲ្យពួកសាវ័កពួកសាវ័កក៏
យកទៅចែកបណ្ដាជន។ ៣៧ពួកគេបរិភោគឆ្អែតគ្រ
ប់ៗគ្នា ហើយប្រមូលនំបុ័ង និងត្រី ដែលនៅសល់
បានប្រាំពីរជាល។ ៣៨អស់អ្នកដែលបានបរិភោគមាន
ចំនួនបួនពាន់នាក់ ឥតគិតស្រីៗនិងក្មេងៗផងទេ។
៣៩បន្ទាប់មក ព្រះអង្គប្រាប់មហាជនឲ្យវិលត្រឡប់ទៅ
ផ្ទះវិញ រួចទ្រង់យាងចុះទូក ឆ្ពោះទៅតំបន់ម៉ាកាដា
ន។

## ពួកខាងគណៈផារីស៊ីនិងពួកខាងគណៈសាឌូស៊ីចង់ឃើញការអស្ចារ្យទុកជាទីសម្គាល់

(ម៉ាកុស ៨.១១-១៣លូកា ១២.៥៤-៥៦)

១៦ ១ពេលនោះ ពួកខាងគណៈផារីស៊ីនិង ពួកខាងគ
ណៈសាឌូស៊ី នាំគ្នាចូលមកគាល់ព្រះយេស៊ូ ក្នុង
គោលបំណងចាប់កំហុសព្រះអង្គ។ គេសុំឲ្យព្រះអង្គ
សម្ដែងទីសម្គាល់មួយ បញ្ជាក់ថាព្រះអង្គបានទទួល
អំណាចពីព្រះជាម្ចាស់មក។ ២ប៉ុន្តែព្រះអង្គមានព្រះ
បន្ទូលតបទៅគេថា៖ {«នៅពេលថ្ងៃលិច កាលណា
អ្នករាល់គ្នាឃើញផ្ទៃមេឃពណ៌ក្រហម អ្នករាល់គ្នា
តែងពោលថា ស្អែកថ្ងៃល្អហើយ។ ៣នៅពេលព្រឹក
ព្រហាមកាលណាអ្នករាល់គ្នាឃើញផ្ទៃមេឃខ្មៅងងឹតដាស
អ្នករាល់គ្នាតែងពោលថា ថ្ងៃនេះភ្លៀងហើយ។អ្នក
រាល់គ្នាយល់ហេតុការណ៍ផ្សេងៗ នៅលើមេឃបាន

តែអ្នករាល់គ្នាមិនយល់ទីសម្គាល់ នាសម័យនេះ
សោះ!} ៤មនុស្សជំនាន់នេះអាក្រក់ណាស់ ហើយ
ក្បត់នឹងព្រះជាម្ចាស់ផង គេចង់តែឃើញទីសម្គាល់ដ៏
អស្ចារ្យ ប៉ុន្តែព្រះអង្គ មិនប្រទានទីសម្គាល់ណាផ្សេង
ក្រៅពី ទីសម្គាល់របស់ព្យាការី*យ៉ូណាសឡើយ»។
បន្ទាប់មក ព្រះយេស៊ូយាងចាកចេញពីគេទៅ។

## ពុតត្បុតរបស់ពួកខាងគណៈផារីស៊ីនិងពួកខាងគណៈសាឌូស៊ី

(ម៉ាកុស ៨.១៤-២១)

៥ពេលឆ្លងទៅត្រើយម្ខាង ពួកសាវ័កភ្លេចយកនំ
ប៉័ងទៅជាមួយ ៦ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖
«ចូរអ្នករាល់គ្នាប្រយ័ត្ននឹងមេម្សៅរបស់ពួកខាងគ
ណៈផារីស៊ី* និងមេម្សៅរបស់ពួកខាងគណៈសាឌូ
ស៊ី*ឲ្យមែនទែន»។ ៧ពួកសាវ័កជជែកគ្នាគេថា៖ «
យើងមិនបានយកនំប៉័ងមកទេ!»។ ៨ព្រះយេស៊ូជ្រាប
គំនិតរបស់គេ ក៏មានព្រះបន្ទូលថា៖«មនុស្សមាន
ជំនឿតិចអើយ ម្ដេចក៏ជជែកគ្នាអំពីរឿងគ្មាននំប៉័ង
ដូច្នេះ? ៩អ្នករាល់គ្នានៅតែពុំទាន់យល់ទៀតឬ?
កាលខ្ញុំចែកនំប៉័ងប្រាំដុំឲ្យមនុស្សប្រាំពាន់នាក់នោះ
អ្នករាល់គ្នាប្រមូលបានប៉ុន្មានល្អីអ្នករាល់គ្នាចាំឬទេ?
១០ហើយកាលខ្ញុំចែកនំប៉័ងប្រាំពីរដុំឲ្យមនុស្សបួនពាន់
នាក់អ្នករាល់គ្នាប្រមូលបានប៉ុន្មានជាល? ១១ហេតុ
ដូចម្ដេចបានជាអ្នករាល់គ្នាមិនយល់ដូច្នេះ ខ្ញុំគ្មាន
បំណងនិយាយអំពីនំប៉័ងទេ គឺខ្ញុំចង់ឲ្យអ្នករាល់គ្នា
ប្រយ័ត្ននឹងមេម្សៅ របស់ពួកខាងគណៈផារីស៊ី* និង
ពួកខាងគណៈសាឌូស៊ី*ឯណោះ»។
១២ពេលនោះ ពួកសាវ័កយល់ថា ព្រះអង្គចង់ឲ្យ
គេប្រយ័ត្ននឹងសេចក្ដីដែលពួកខាងគណៈផារីស៊ីនិង
ពួកខាងគណៈសាឌូស៊ីបង្រៀនមិនមែនប្រយ័ត្នអំពីមេ
ម្សៅនោះឡើយ។

## លោកស៊ីម៉ូនប្រកាសថាព្រះយេស៊ូជាព្រះគ្រិស្ត

(ម៉ាកុស ៨.២៧-៣០ លូកា ៩.១៨-២១)

១៣កាល ព្រះយេស៊ូយាងមកដល់ស្រុកសេសា
រេភីលីព ព្រះអង្គមានព្រះបន្ទូលសួរពួកសាវ័ក*ថា៖«
មនុស្សទាំងឡាយថា បុត្រមនុស្សជានរណា?»។១៤
គេទូលថា៖ «អ្នកខ្លះថាលោកជាលោកយ៉ូហានបាទី
ស្ដអ្នកខ្លះថា លោកជាព្យាការី*អេលី អ្នកខ្លះទៀតថា
លោកជាព្យាការីយេរេមី ឬជាព្យាការីណាមួយរូប»។
១៥ព្រះអង្គសួរគេទៀតថា៖ «ចុះអ្នករាល់គ្នាវិញ តើ
អ្នករាល់គ្នាថាខ្ញុំជានរណាដែរ?»។១៦លោកស៊ីម៉ូ
នសិលាទូលព្រះអង្គថា៖ «លោកជាព្រះគ្រិស្ដ*ជា
ព្រះបុត្រារបស់ព្រះជាម្ចាស់ ដ៏មានព្រះជន្មគង់នៅ»។
១៧ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់វិញថា៖ «ស៊ី
ម៉ូនកូនលោកយ៉ូណាសអើយអ្នកពិតជាមានសុភ
មង្គលមែន អ្នកដឹងសេចក្ដីនេះមិនមែនដោយខ្លួនឯង[ផ]
ទេ គឺព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខ*
បានសម្ដែងឲ្យអ្នកដឹង។ ១៨ខ្ញុំសុំប្រាប់អ្នកថា អ្នក
ឈ្មោះសិលា ហើយនៅលើផ្ទាំងសិលានេះ ខ្ញុំនឹងសង់
ព្រះសហគមន៍*របស់ខ្ញុំ។សេចក្ដីស្លាប់[ព]ពុំមាន
អំណាចលើព្រះសហគមន៍នេះបានឡើយ ១៩ខ្ញុំនឹង
ប្រគល់កូនសោព្រះរាជ្យ*នៃស្ថានបរមសុខឲ្យអ្នក។
អ្វីៗដែលអ្នកចង[ភ]នៅលើផែនដីនេះ ព្រះជាម្ចាស់នឹង
ចងនៅស្ថានបរមសុខហើយអ្វីៗ ដែលអ្នកស្រាយ[ភ]
នៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថានបរម
សុខដែរ»។
២០បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលហាមពួក
សាវ័ក*មិនឲ្យប្រាប់នរណាថា ព្រះអង្គជាព្រះគ្រិស្ដ*
ឡើយ។
២១តាំងពីពេលនោះមក ព្រះយេស៊ូ[ម]ចាប់ផ្ដើម
ប្រាប់ឲ្យពួកសាវ័កដឹងថា ព្រះអង្គត្រូវតែយាងទៅក្រុង
យេរូសាឡឹម។ ពួកព្រឹទ្ធាចារ្យ*ពួកនាយកបូជាចារ្យ*
និងពួកធម្មាចារ្យ*នឹងនាំគ្នាធ្វើបាបព្រះអង្គឲ្យរងទុក្ខ

លំបាកយ៉ាងខ្លាំង ថែមទាំងធ្វើគុតព្រះអង្គទៀតផង
តែបីថ្ងៃក្រោយមកព្រះអង្គនឹងមានព្រះជន្មរស់ឡើងវិ
ញ។ ២២លោកសិលា*នាំព្រះយេស៊ូទៅដាច់ឡែកពី
គេ ហើយទូលជំទាស់ថា៖«ព្រះអម្ចាស់អើយ! សូម
ព្រះជាម្ចាស់មេត្តាអាណិតកុំឲ្យការណ៍នេះកើតមាន
ដល់ព្រះអង្គឡើយ»។២៣ព្រះយេស៊ូបែរមកមានព្រះ
បន្ទូល ទៅលោកសិលាថា៖ «នែ៎មារ*សាតាំងអើយ!
ថយទៅខាងក្រោយខ្ញុំ ដ្បិតអ្នកកំពុងរារាំងផ្លូវខ្ញុំគំនិត
អ្នកមិនមែនជាគំនិតរបស់ព្រះជាម្ចាស់ទេ គឺជាគំនិត
របស់មនុស្សលោកសុទ្ធសាធ»។

២៤បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់
ពួកសាវ័កថា៖ «បើអ្នកណាចង់មកតាមក្រោយខ្ញុំ ត្រូវ
លះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួន
ហើយមកតាមខ្ញុំចុះ ២៥ដ្បិតអ្នកណាចង់បានរួចជីវិត
អ្នកនោះនឹងបាត់បង់ជីវិត ប៉ុន្តែអ្នកណាបាត់បង់ជីវិត
ព្រោះតែខ្ញុំ អ្នកនោះនឹងបានជីវិតវិញ។ ២៦បើមនុស្ស
ម្នាក់បានពិភពលោកទាំងមូល មកធ្វើជាសម្បត្តិរបស់
ខ្លួន តែបាត់បង់ជីវិតនោះនឹងមានប្រយោជន៍អ្វី? តើ
មនុស្សអាចយកអ្វីមកប្ដូរនឹងជីវិតរបស់ខ្លួនបាន? ២៧
លុះដល់បុត្រមនុស្ស*ប្រកបដោយសិរីរុងរឿង ព្រះ
បិតារបស់ព្រះអង្គយាងមកជាមួយពួកទេវទូតរបស់
ព្រះអង្គ ព្រះអង្គនឹងប្រទានរង្វាន់ ឬដាក់ទោសម្នាក់ៗ
តាមអំពើដែលខ្លួនបានប្រព្រឹត្ត។២៨ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា អ្នកខ្លះដែលនៅទីនេះនឹងមិន
ស្លាប់ទេ មុនបានឃើញបុត្រមនុស្សយាងមកគ្រងព្រះ
រាជ្យ*»។

## សិរីរុងរឿងរបស់ព្រះយេស៊ូ

(ម៉ាកុស ៩.២-៨ លូកា ៩.២៨-៣៦)

១៧ ១ប្រាំមួយថ្ងៃក្រោយមក ព្រះយេស៊ូនាំលោក
សិលា លោកយ៉ាកុប និងលោកយ៉ូហានជាប្អូន ឡើង
ទៅលើភ្នំដាច់ឡែកពីគេ។ ២ពេលនោះព្រះអង្គប្រែជា
មានទ្រង់ទ្រាយប្លែកពីមុន នៅមុខសាវ័ក*ទាំងបីគឺព្រះ
ភ័ក្ត្ររបស់ព្រះអង្គបញ្ចេញរស្មីចែងចាំង ដូចពន្លឺថ្ងៃ
ហើយព្រះពស្ត្ររបស់ព្រះអង្គ ត្រឡប់ជាមានពណ៌ស
ដូចពន្លឺ។ ៣សាវ័កទាំងបីបានឃើញលោកម៉ូសេ* និង
ព្យាការី*អេលី សន្ទនាជាមួយព្រះយេស៊ូ។ ៤លោក
សិលាទូលព្រះអង្គថា៖«ព្រះអម្ចាស់! យើងខ្ញុំបាននៅ
ទីនេះប្រសើរណាស់បើព្រះអង្គសព្វព្រះហឫទ័យ
ទូលបង្គំនឹងសង់ជម្រកបី គឺមួយសម្រាប់ព្រះអង្គ មួយ
សម្រាប់លោកម៉ូសេ និងមួយទៀតសម្រាប់ព្យាការីអេ
លី»។ ៥កាលលោកសិលាកំពុងតែមានប្រសាសន៍
នៅឡើយ ស្រាប់តែមានពពក*ដ៏ភ្លឺមកគ្របបាំងគេ
ទាំងអស់គ្នា ហើយមានព្រះសូរសៀងបន្លឺពីក្នុងពពក
មកថា៖ «នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង
យើងគាប់ចិត្តនឹងព្រះអង្គណាស់ ចូរស្ដាប់ព្រះអង្គ
ចុះ!»។ ៦ពួកសាវ័កឮដូច្នោះ ក៏នាំគ្នាក្រាបចុះ ដាក់
មុខដល់ដី ព្រោះគេភ័យខ្លាចជាខ្លាំង។ ៧ព្រះយេស៊ូ
យាងចូលទៅជិតដាក់ព្រះហស្ដលើគេ ទាំងមានព្រះ
បន្ទូលថា៖«ចូរនាំគ្នាក្រោកឡើង កុំខ្លាចអី!»។ ៨
កាលពួកសាវ័កងើបមុខឡើង ឃើញតែព្រះយេស៊ូ
មួយព្រះអង្គប៉ុណ្ណោះពុំឃើញមាននរណាទៀតឡើ
យ។

៩ពេលព្រះអង្គយាងចុះពីលើភ្នំ ជាមួយសាវ័ក*
ទាំងបី ព្រះយេស៊ូហាមប្រាមគេថា៖ «កុំនិយាយ
ប្រាប់នរណា អំពីហេតុការណ៍ដែលអ្នករាល់គ្នាបាន
ឃើញនេះឲ្យសោះ ត្រូវចាំរហូតដល់បុត្រមនុស្ស*
មានជីវិតរស់ឡើងវិញ»។

១០ពួកសាវ័ក*ទូលសួរព្រះអង្គថា៖ «ហេតុដូច
ម្ដេចបានជាពួកធម្មាចារ្យ* ចេះតែនិយាយថា ព្យាការី
អេលីត្រូវអញ្ជើញមកមុន?»។ ១១ព្រះអង្គមានព្រះ
បន្ទូលតបថា៖ «ព្យាការីអេលីអញ្ជើញមកមែន ដើម្បី
រៀបចំសព្វគ្រប់ទាំងអស់ឡើងវិញ។ ១២ខ្ញុំសុំប្រាប់អ្នក
រាល់គ្នាថា ព្យាការីអេលីបានអញ្ជើញមករួចហើយ តែ

ពួកគេមិនព្រមទទួលស្គាល់លោកទេមិនតែប៉ុណ្ណោះ
សោត គេថែមទាំងបានធ្វើបាបលោកសព្វបែបយ៉ាង
តាមអំពើចិត្តរបស់គេទៀតផង។ បុត្រមនុស្សក៏នឹង
ត្រូវគេធ្វើបាបដូច្នោះដែរ»។ ១៣ពេលនោះពួកសាវ័ក
យល់ថា ព្រះអង្គមានព្រះបន្ទូលអំពីលោកយ៉ូហាន
បាទីស្ដ*។

## ព្រះយេស៊ូដេញខ្មោចចេញពីក្មេងម្នាក់

(ម៉ាកុស ៩.១៤-២៧ លូកា ៩.៣៧-៤៣)

១៤កាល ព្រះយេស៊ូនិងសាវ័ក*ទាំងបីរូបមក
ដល់កន្លែងដែលបណ្ដាជននៅជុំគ្នា មានបុរសម្នាក់
ចូលមកគាល់ព្រះអង្គ។ គាត់លុតជង្គង់ចុះ ១៥ទូលថា
៖«លោកម្ចាស់អើយ សូមលោកអាណិតមេត្តាកូន
ប្រុសរបស់ខ្ញុំប្របាទផង វាឆ្កួតជ្រូកបណ្ដាលឲ្យវាឈឺ
ចុកចាប់ខ្លាំងណាស់ វាដួលទៅក្នុងភ្លើង និងធ្លាក់ទឹក
ជាញឹកញាប់។ ១៦ខ្ញុំប្របាទបាននាំវាមកជួបសាវ័ក
របស់លោកដែរ តែគេពុំអាចមើលវាឲ្យជាបានទេ»។
១៧ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «នែ៎ពួកមនុស្ស
អាក្រក់មិនព្រមជឿអើយ! តើត្រូវឲ្យខ្ញុំទ្រាំនៅជាមួយ
អ្នករាល់គ្នាដល់ពេលណាទៀត! ចូរនាំក្មេងនោះមក
ឲ្យខ្ញុំ»។ ១៨បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូល
គំរាមខ្មោច ខ្មោចក៏ចេញហើយក្មេងនោះបានជាតាំង
ពីពេលនោះមក។

១៩ពេលនោះ ពួកសាវ័កចូលមកគាល់ព្រះ
យេស៊ូដាច់ឡែកពីគេទូលថា៖ «ហេតុអ្វីបានជាយើង
ខ្ញុំពុំអាចដេញខ្មោចនោះបាន?»។ ២០ព្រះអង្គមាន
ព្រះបន្ទូលតបទៅគេថា៖ «មកពីអ្នករាល់គ្នាមាន
ជំនឿតិចពេក។ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា
បើអ្នករាល់គ្នាមានជំនឿប៉ុនគ្រាប់ពូជមួយដ៏ល្អិត អ្នក
រាល់គ្នានឹងបញ្ជាទៅភ្នំនោះថា "ចូរចេញពីនេះទៅនៅ
កន្លែងផ្សេងទៅ!" ភ្នំមុខជាធ្វើតាមពាក្យអ្នករាល់ គ្នា
មិនខាន ដ្បិតគ្មានការអ្វីដែលអ្នករាល់គ្នាធ្វើមិនកើត
ឡើយ។ {២១គេអាចដេញខ្មោចប្រភេទនេះឲ្យចេញ
បានលុះត្រាតែអធិស្ឋាន* និងតមអាហារ»។}

## ព្រះយេស៊ូប្រកាសអំពី ព្រះអង្គត្រូវសោយទិវង្គត

(ម៉ាកុស ៩.៣០-៣២ លូកា ៩.៤៣-៤៥)

២២កាលពួកសាវ័ក*នៅជុំគ្នា ក្នុងស្រុកកាលីឡេ
ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «បុត្រមនុស្ស
នឹងត្រូវគេបញ្ជូន ទៅក្នុងកណ្ដាប់ដៃរបស់មនុស្ស
លោកជាមិនខាន។ ២៣គេនឹងសម្លាប់លោក ប៉ុន្តែនៅ
ថ្ងៃទីបី លោកនឹងមានជីវិតរស់ឡើងវិញ»។ ឮដូច្នោះ
ពួកសាវ័ក*ព្រួយចិត្តជាខ្លាំង។

## ការបង់ពន្ធព្រះវិហារនៅក្រុងយេរូសាឡឹម

២៤លុះព្រះយេស៊ូយាងមក ដល់ក្រុងកាផានុម
ជាមួយពួកសាវ័ក អ្នកហូតពន្ធសម្រាប់ព្រះវិហារ[ឃ]នាំ
គ្នាចូលមករកលោកសិលា ហើយសួរថា៖«លោកគ្រូ
របស់អ្នកបង់ពន្ធសម្រាប់ព្រះវិហារឬទេ?»។ ២៥
លោកតបវិញថា៖ «បាទ! លោកបង់!»។ កាល
លោកសិលាទៅដល់ផ្ទះ ព្រះយេស៊ូមានព្រះបន្ទូល
ទៅគាត់មុនថា៖ «ស៊ីម៉ូន! តាមយោបល់អ្នក ស្ដេច
នៅផែនដីនេះទារពន្ធអាករពីនរណា? ពីបុត្ររបស់
ស្ដេច ឬពីអ្នកផ្សេង?»។ ២៦លោកទូលថា៖ «ពីអ្នក
ផ្សេង»។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «
មែន បើដូច្នេះបុត្ររបស់ស្ដេចមិនត្រូវបង់ពន្ធឡើយ២៧
ប៉ុន្តែ ដើម្បីកុំឲ្យអ្នកទាំងនោះទាស់ចិត្ត ចូរទៅស្ទូចត្រី
សមុទ្រ ហើយយកត្រីដែលស្ទូចបានមុនគេមកបើក
មាត់ អ្នកនឹងឃើញកាក់មួយ ចូរយកកាក់នោះទៅបង់
ពន្ធឲ្យខ្ញុំ និងឲ្យអ្នកចុះ!»។

## អ្នកធំជាងគេ

(ម៉ាកុស ៩.៣៣-៣៧ លូកា ៩.៤៦-៤៨)

១៨ ១ពេលនោះ សាវ័កនាំគ្នាចូលមកគាល់ព្រះយេស៊ូ

ហើយទូលថា៖ «តើអ្នកណាមានឋានៈធំជាងគេ នៅ
ក្នុងព្រះរាជ្យ*នៃស្ថានបរមសុខ*?»។ ២ព្រះអង្គហៅ
ក្មេងតូចម្នាក់ ឲ្យមកឈរនៅកណ្ដាលចំណោមពួក
សាវ័ក ៣រួចមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា បើអ្នករាល់គ្នាមិនដូរចិត្តគំនិតឲ្យ
បានដូចក្មេងតូចៗទេ អ្នករាល់គ្នាមិនអាចចូលទៅក្នុង
ព្រះរាជ្យ* នៃស្ថានបរមសុខ*បានឡើយ។ ៤អ្នកណា
ដាក់ខ្លួនដូចក្មេងតូចនេះ អ្នកនោះមានឋានៈធំជាងគេ
ក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ ៥អ្នកណាទទួលក្មេង
តូចណាម្នាក់ដូចក្មេងនេះក្នុងនាមខ្ញុំ ក៏ដូចជាបាន
ទទួលខ្ញុំដែរ»។

## កុំនាំអ្នកដទៃប្រព្រឹត្តអំពើបាប

(ម៉ាកុស ៩.៤២-៤៨ លូកា ១៧.១-២)

៦«អ្នកណានាំអ្នកតូចតាចម្នាក់ ក្នុងបណ្ដាអ្នក
ដែលជឿលើខ្ញុំនេះ ឲ្យប្រព្រឹត្តអំពើបាប ចំពោះអ្នក
នោះ ប្រសិនបើគេយកត្បាល់ថ្មយ៉ាងធំមកចងកគាត់
ទម្លាក់ទៅក្នុងបាតសមុទ្រឲ្យលង់ទឹក ប្រសើរជាងទុក
គាត់ឲ្យនៅរស់! ៧មនុស្សលោកមុខជាត្រូវវេទនាមិន
ខាន ដ្បិតមានហេតុផ្សេងៗជាច្រើន នាំឲ្យគេប្រព្រឹត្ត
អំពើបាប។ ហេតុផ្សេងៗ ដែលនាំឲ្យគេប្រព្រឹត្តអំពើ
បាបនោះ ត្រូវតែមានចៀសមិនផុត ប៉ុន្តែអ្នកណានាំ
គេឲ្យប្រព្រឹត្តអំពើបាប អ្នកនោះត្រូវវេទនាហើយ!

៨ប្រសិនបើដៃឬជើងរបស់អ្នក នាំអ្នកឲ្យប្រព្រឹត្ត
អំពើបាប ចូរកាត់វាបោះចោលឲ្យឆ្ងាយទៅ បើអ្នក
ចូលទៅក្នុងជីវិត មានតែដៃម្ខាងឬជើងម្ខាងនោះ
ប្រសើរជាងមានដៃពីរឬមានជើងពីរ ហើយត្រូវធ្លាក់
ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច។ ៩ប្រសិនបើ
ភ្នែករបស់អ្នក នាំអ្នកឲ្យប្រព្រឹត្តអំពើបាប ចូរខ្វេះវា
ចេញ ហើយបោះចោលឲ្យឆ្ងាយទៅ បើអ្នកចូលទៅ
ក្នុងជីវិត មានតែភ្នែកម្ខាងនោះប្រសើរជាងមានភ្នែក
ពីរ ហើយត្រូវធ្លាក់ទៅក្នុងភ្លើងនរក។

១០ចូរប្រយ័ត្ន កុំមាក់ងាយនរណាម្នាក់ ក្នុង
ចំណោមអ្នកតូចតាចនេះឡើយ។ ខ្ញុំសុំប្រាប់អ្នករាល់
គ្នាថា ទេវទូត*របស់ពួកគេស្ថិតនៅឯស្ថានបរមសុខ*
ទាំងឃើញព្រះភ័ក្ត្ររបស់ព្រះបិតាដែលគង់នៅស្ថាន
បរមសុខ គ្រប់ពេលវេលាផង {១១ដ្បិតបុត្រមនុស្ស
បានមកសង្គ្រោះមនុស្សដែលវិនាសបាត់បង់»។}

## ប្រស្នាអំពីចៀមដែលវង្វេងបាត់ហើយរក ឃើញវិញ

(លូកា ១៥.៤-៧)

១២«តើអ្នករាល់គ្នាយល់យ៉ាងណា ប្រសិនបើ
បុរសម្នាក់មានចៀមមួយរយក្បាល ហើយចៀមមួយ
វង្វេងបាត់?។ គាត់មុខជាទុកចៀមកៅសិបប្រាំបួន
នៅលើភ្នំ ហើយទៅតាមរកចៀមដែលបាត់នោះពុំខា
ន។ ១៣ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បើគាត់
រកចៀមនោះឃើញវិញ គាត់មុខតែត្រេកអរសប្បាយ
ជាមិនខាន គឺសប្បាយលើសពីឃើញចៀមកៅសិប
ប្រាំបួន ដែលមិនវង្វេងបាត់ទៅទៀត។ ១៤រីឯព្រះបិតា
របស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ*ក៏
ដូច្នោះដែរ ទ្រង់មិនសព្វព្រះហឫទ័យឲ្យអ្នកណាម្នាក់
ក្នុងចំណោមអ្នកតូចតាចទាំងនេះវិនាសបាត់បង់
ឡើយ»។

## ត្រូវអត់ទោសឲ្យគេជានិច្ច

១៥«ប្រសិនបើ មានបងប្អូនណាម្នាក់បាន
ប្រព្រឹត្តអំពើបាបអ្វីមួយ ចូរទៅជួបអ្នកនោះស្ងាត់ៗតែ
ពីរនាក់ ហើយស្ដីប្រដៅគាត់ទៅ។ បើគាត់ស្ដាប់អ្នក
អ្នកនឹងរក្សាបងប្អូននោះ មិនឲ្យបាត់ឡើយ ១៦តែបើ
គាត់មិនព្រមស្ដាប់អ្នកទេ ចូរនាំម្នាក់ ឬពីរនាក់ទៀត
ទៅជាមួយ ជួយដាស់តឿន ដើម្បីសម្រួលរឿងទាំង
អស់ ដោយមានសាក្សីពីរឬបីនាក់[ល]។ ១៧ប្រសិនបើ
គាត់មិនព្រមស្ដាប់ពាក្យអ្នកទាំងនោះ ត្រូវនាំរឿងនេះ
ទៅប្រាប់ព្រះសហគមន៍* ហើយបើគាត់នៅតែមិន

ព្រមស្ដាប់ព្រះសហគមន៍ទៀតនោះ ត្រូវចាត់ទុកគាត់
ដូចជាសាសន៍ដទៃ ឬដូចជាអ្នកទារពន្ធ*ចុះ។ ១៨ខ្ញុំសុំ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថាអ្វីៗទាំងអស់ដែល
អ្នករាល់គ្នាចងនៅលើផែនដីនេះ ព្រះជាម្ចាស់នឹងចង
នៅស្ថានបរមសុខ ហើយអ្វីៗដែលអ្នករាល់គ្នាស្រាយ
នៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថាន
បរមសុខដែរ។ ១៩ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់
ទៀតថា ក្នុងចំណោមអ្នករាល់គ្នាប្រសិនបើមានពីរ
នាក់នៅលើផែនដីនេះ រួមចិត្តគំនិតគ្នា ទូលសូមអ្វីក៏
ដោយព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខ
នឹងប្រទានឲ្យជាមិនខាន ២០ដ្បិតនៅទីណាមានពីរឬ
បីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ ខ្ញុំក៏ស្ថិតនៅទីនោះ ជាមួយ
គេដែរ។

២១ពេលនោះ លោកសិលាចូលមកជិតព្រះ
យេស៊ូ ហើយទូលថា៖ «បពិត្រព្រះអម្ចាស់បើបងប្អូន
ចេះតែប្រព្រឹត្តអំពើបាប មកលើទូលបង្គំ តើទូលបង្គំ
ត្រូវអត់ទោសឲ្យគេប៉ុន្មានដង? រហូតដល់ប្រាំពីរដង
ឬ?»។ ២២ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំ
សុំប្រាប់អ្នកថា អ្នកត្រូវអត់ទោសឲ្យគេមិនត្រឹមតែ
ប្រាំពីរដងប៉ុណ្ណោះទេ គឺត្រូវអត់ទោសឲ្យគេចិតសិប
ដង ប្រាំពីរដង[ស]»។

## ប្រស្នាអំពីអ្នកបម្រើ ដែលពុំព្រមអត់ទោសឲ្យគេ

២៣«ហេតុនេះ ព្រះរាជ្យនៃស្ថានបរមសុខ*
ប្រៀបបាននឹងស្ដេចមួយអង្គ ដែលចង់គិតបញ្ជីជា
មួយអ្នកបម្រើ។ ២៤ពេលព្រះរាជាចាប់ផ្ដើមគិតបញ្ជី
មានគេនាំកូនបំណុលម្នាក់ ដែលជំពាក់ប្រាក់រាប់
លានណែន[ហ]មក។ ២៥ដោយអ្នកនោះគ្មានប្រាក់សង
ស្ដេចក៏ចេញបញ្ជា ឲ្យលក់ទាំងគាត់ទាំងប្រពន្ធ ទាំង
កូន ទាំងរបស់របរដែលគាត់មានដើម្បីយកប្រាក់មក
សងបំណុល។ ២៦អ្នកបម្រើនោះលុតជង្គង់ក្រាបទៀប
ព្រះបាទាស្ដេច ទូលអង្វរថា៖ "សូមទ្រង់មេត្តាអត់ឱន
ពន្យារពេលឲ្យទូលបង្គំផង ទូលបង្គំនឹងសងព្រះអង្គ
វិញគ្រប់ចំនួន"។ ២៧ព្រះរាជាមានព្រះហឫទ័យ
អាណិត អាសូរអ្នកបម្រើនោះពន់ពេកណាស់ព្រះអង្គ
ក៏ឲ្យគាត់ទៅវិញ ទាំងលុបបំណុលចោលថែមទៀតផ
ង។

២៨ពេលអ្នកបម្រើនោះចេញទៅ គាត់បានជួប
នឹងគូកនម្នាក់ ដែលជំពាក់ប្រាក់គាត់មួយរយដួង*
គាត់ចាប់អ្នកនោះច្របាច់ក ទាំងពោលថា៖ "សង
ប្រាក់អញទាំងអស់មក!"។ ២៩គូកនរបស់អ្នកនោះក៏
លុតជង្គង់ចុះ អង្វរថា "សុំអត់ឱនពន្យារពេល ឲ្យគ្នា
ផង គ្នានឹងសងឯងវិញគ្រប់ចំនួន"។ ៣០ប៉ុន្តែអ្នកបម្រើ
នោះពុំព្រមទេ មិនតែប៉ុណ្ណោះសោត គាត់ចាប់អ្នក
ជំពាក់ប្រាក់យកទៅឃុំឃាំង រហូតទាល់តែបានសង
បំណុលគ្រប់ចំនួន។ ៣១អ្នកបម្រើឯទៀតៗឃើញ
ដូច្នោះ ទាស់ចិត្តជាខ្លាំងគេយករឿងនេះ ទៅទូលស្ដេ
ច។ ៣២ស្ដេចក៏ហៅអ្នកបម្រើនោះមកសួរថា៖"នែ៎អ្នក
បម្រើអាក្រក់!យើងបានលុបបំណុលឯងទាំងប៉ុន្មាន
ចោលអស់ ព្រោះឯងបានទទូចអង្វរយើង។ ៣៣យើង
បានអាណិតមេត្តាឯង។ ហេតុដូចម្ដេចបានជា ឯងពុំ
ព្រមអាណិតមេត្តាគូកនរបស់ឯងផងដូច្នេះ?"។ ៣៤
ស្ដេចទ្រង់ខ្ញាល់ក្រៃលែងក៏បញ្ជាឲ្យគេយកអ្នកនោះ
ទៅធ្វើទារុណកម្ម រហូតទាល់តែសងបំណុលគ្រប់ចំនួ
ន។ ៣៥ចំពោះអ្នករាល់គ្នា បើម្នាក់ៗមិនព្រមលើក
លែងទោស ឲ្យបងប្អូនដោយស្មោះអស់ពីចិត្តទេ ព្រះ
បិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខក៏នឹងធ្វើ
ទារុណកម្មអ្នករាល់គ្នាដូច្នោះដែរ»។

## ព្រះដំបូន្មានអំពីរឿងលែងលះប្ដីប្រពន្ធ

(ម៉ាកុស ១០.១-១២ លូកា ១៦.១៨)

១៩ ១កាល ព្រះយេស៊ូមានព្រះបន្ទូលទាំងនេះចប់
សព្វគ្រប់ហើយ ទ្រង់ក៏ចាកចេញពីស្រុកកាលីឡេ
យាងឆ្ពោះទៅត្រើយខាងនាយទន្លេយ័រដាន់ ក្នុងស្រុក
យូដា។ ២មហាជនច្រើនកុះករនាំគ្នាមកតាមព្រះអង្គ

ព្រះអង្គក៏ប្រោសអ្នកជំងឺឲ្យបានជា នៅទីនោះ។ ៣
មានពួកខាងគណៈផារីស៊ី*ចូលមកជិត ហើយទូល
សួរ ក្នុងគោលបំណងល្បងលមើលព្រះអង្គថា៖ «តើ
ស្វាមីមានសិទ្ធិនឹងលែងភរិយា ដោយសំអាងលើមូល
ហេតុអ្វីក៏ដោយបានឬទេ?»។ ៤ព្រះអង្គមានព្រះ
បន្ទូលតបថា៖ «អ្នករាល់គ្នាធ្លាប់អានគម្ពីររួចមក
ហើយថា កាលដើមដំបូង ព្រះអាទិករ*បានបង្កើត
មនុស្សមកជាបុរស ជាស្ត្រី[ឃ] ៥រួចព្រះអង្គមានព្រះ
បន្ទូលថា៖ "ហេតុនេះហើយ បានជាបុរសត្រូវចាក
ចេញពីឪពុកម្ដាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន
ហើយអ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ"[ង]។ ៦
គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែ
មួយវិញ។ ដូច្នេះមនុស្សមិនត្រូវបំបាក់បំបែកគូស្រករ
ដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ»។ ៧ពួកគេ
ទូលសួរព្រះអង្គថា៖ «ចុះហេតុដូចម្ដេចបានជាលោក
ម៉ូសេបញ្ជា ឲ្យស្វាមីធ្វើលិខិតលែងលះភរិយា?»។ ៨
ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «លោកម៉ូសេ
អនុញ្ញាត ឲ្យអ្នករាល់គ្នាលែងភរិយាបាន ព្រោះអ្នក
រាល់គ្នាមានចិត្តរឹងរូស[ក]តែកាលដើមឡើយមិនមែន
ដូច្នោះទេ។ ៩ខ្ញុំសុំប្រាប់អ្នករាល់គ្នាថាបុរសណាលែង
ភរិយា (លើកលែងតែរួមរស់ជាមួយគ្នាដោយឥតបាន
រៀបការ)[ខ] ហើយទៅរៀបការនឹងស្ត្រីម្នាក់ទៀត បុរស
នោះឯងជាអ្នកប្រព្រឹត្តអំពើផិតក្បត់»។

១០សាវ័ក*នាំគ្នាទូលព្រះអង្គថា៖ «បើមានល័ក្ខ
ខ័ណ្ឌរវាងប្ដីប្រពន្ធបែបនេះ គួរកុំរៀបការប្រសើរ
ជាង»។ ១១ព្រះអង្គមានព្រះបន្ទូលទៅគេវិញថា៖ «
មនុស្សគ្រប់រូបពុំអាចយល់សេចក្ដីនេះ បានឡើយគឺ
មានតែអ្នក ដែលព្រះជាម្ចាស់ប្រោសប្រទានឲ្យយល់
ប៉ុណ្ណោះ ទើបអាចយល់បាន។ ១២អ្នកខ្លះមិនអាច
រៀបការបាន[គ] តាំងពីកំណើតមក[ឃ]។ អ្នកខ្លះទៀតមិន
អាចរៀបការបាន មកពីត្រូវគេក្រៀវ។ រីឯអ្នកខ្លះទៀត
មិនរៀបការ មកពីយល់ដល់ព្រះរាជ្យនៃស្ថានបរមសុ
ខ។ អ្នកណាមានប្រាជ្ញា ចូរយកពាក្យនេះទៅរិះគិត
ឲ្យយល់ចុះ!»។

## ព្រះយេស៊ូប្រទានពរដល់ក្មេងៗ

(ម៉ាកុស ១០.១៣-១៦ លូកា ១៨.១៥-១៧)

១៣មានមនុស្សម្នានាំក្មេងតូចៗ មកឲ្យព្រះ
យេស៊ូដាក់ព្រះហស្ដលើវា និងអធិស្ឋាន*ឲ្យ។ ពួកសា
វ័ក*ស្ដីបន្ទោសអ្នកទាំងនោះ ១៤តែព្រះយេស៊ូមានព្រះ
បន្ទូលថា៖ «ទុកឲ្យក្មេងតូចៗមករកខ្ញុំចុះ កុំឃាត់វា
ឡើយ ដ្បិតមានតែអ្នកមានចិត្តដូចក្មេងៗទាំងនេះ
ប៉ុណ្ណោះ ដែលចូលក្នុងព្រះរាជ្យ*នៃស្ថានបរមសុខ
បាន»។ ១៥បន្ទាប់មកព្រះអង្គដាក់ព្រះហស្ដលើក្មេង
ទាំងនោះ រួចទ្រង់យាងចាកចេញពីទីនោះទៅ។

## អ្នកមានម្នាក់ចង់បានជីវិតអស់កល្បជានិច្ច

(ម៉ាកុស ១០.១៧-៣១ លូកា ១៨.១៨-៣០)

១៦ពេលនោះ មានបុរសម្នាក់ចូលមកគាល់ព្រះ
អង្គ ហើយទូលថា៖ «លោកគ្រូ! តើខ្ញុំត្រូវប្រព្រឹត្តអំពើ
ល្អអ្វីខ្លះ ដើម្បីឲ្យមានជីវិតអស់កល្បជានិច្ច?»។ ១៧
ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ហេតុដូច
ម្ដេចបានជាអ្នកសួរខ្ញុំអំពីអ្វីដែលល្អដូច្នេះ? មានតែ
ព្រះជាម្ចាស់មួយព្រះអង្គប៉ុណ្ណោះ ដែលល្អសប្បុរស។
បើអ្នកចង់ចូលទៅក្នុងជីវិត ត្រូវប្រតិបត្តិតាមវិន័យ*
ទៅ»។ ១៨គាត់ទូលសួរព្រះអង្គថា៖ «វិន័យអ្វីខ្លះ?»
។ ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា៖ «កុំសម្លាប់
មនុស្ស កុំប្រព្រឹត្តអំពើផិតក្បត់ កុំលួចទ្រព្យសម្បត្តិគេ
កុំនិយាយកុហកធ្វើឲ្យគេមានទោស១៩ចូរគោរពមាតា
បិតា[ង] ចូរស្រឡាញ់បងប្អូនឯទៀតៗឲ្យបានដូច
ស្រឡាញ់ខ្លួនឯងដែរ[ច]»។ ២០យុវបុរសនោះទូលព្រះ
អង្គថា៖ «ខ្ញុំបានប្រតិបត្តិតាមវិន័យទាំងនេះហើយ
តើនៅខ្វះអ្វីទៀត?»។ ២១ព្រះយេស៊ូមានព្រះបន្ទូល

ទៅគាត់ថា៖ «បើអ្នកចង់បានល្អឥតខ្ចោះ ចូរយក
ទ្រព្យសម្បត្តិរបស់អ្នកទាំងប៉ុន្មានទៅលក់ហើយចែក
ឲ្យជនក្រីក្រទៅ ធ្វើដូច្នេះទើបអ្នកបានសម្បត្តិសួគ៌ រួច
សឹមអញ្ជើញមកតាមខ្ញុំ!»។ ២២កាលយុវបុរសនោះ
ឮដូច្នេះគាត់ត្រឡប់ទៅវិញ ទាំងព្រួយចិត្ត ដ្បិតគាត់
មានទ្រព្យសម្បត្តិស្ដុកស្ដម្ភណាស់។

២៣ព្រះយេស៊ូមានព្រះបន្ទូលទៅពួកសាវ័ក*ថា៖
«ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកមាន
ពិបាកចូលទៅ ក្នុងព្រះរាជ្យ*នៃស្ថានបរមសុខ*
ណាស់!។ ២៤ខ្ញុំសុំប្រាប់អ្នករាល់គ្នាទៀតថា សត្វអូដ្ឋ
ចូលតាមប្រហោងម្ជុល ងាយជាងអ្នកមានចូលទៅ
ក្នុងព្រះរាជ្យនៃស្ថានបរមសុខទៅទៀត»។ ២៥កាល
ពួកសាវ័កឮដូច្នោះ គេងឿងឆ្ងល់យ៉ាងខ្លាំង ហើយ
ពោលថា៖ «បើដូច្នេះ តើអ្នកណានឹងអាចទទួលការ
សង្គ្រោះ?»។ ២៦ព្រះយេស៊ូទតមើលគេ រួចមានព្រះ
បន្ទូលថា៖ «ការនេះមនុស្សធ្វើពុំកើតទេ រីឯព្រះជា
ម្ចាស់វិញ អ្វីក៏ដោយព្រះអង្គធ្វើកើតទាំងអស់»។ ២៧
ពេលនោះលោកសិលា*ទូលព្រះអង្គថា៖ «ព្រះអង្គ
ទតឃើញស្រាប់ហើយ យើងខ្ញុំបានលះបង់អ្វីៗទាំង
អស់ ដើម្បីមកតាមព្រះអង្គ។ តើយើងខ្ញុំនឹងទៅជា
យ៉ាងណា?»។ ២៨ព្រះយេស៊ូមានព្រះបន្ទូលទៅពួក
សាវ័កថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា
នៅក្នុងពិភពថ្មី ពេលបុត្រមនុស្ស*គង់លើបល្ល័ង្ក
ប្រកបដោយសិរីរុងរឿង អ្នករាល់គ្នាដែលមកតាមខ្ញុំ
នេះ ក៏នឹងអង្គុយលើបល្ល័ង្កទាំងដប់ពីរ ហើយគ្រប់
គ្រងលើកុលសម្ព័ន្ធទាំងដប់ពីរ នៃជនជាតិអ៊ីស្រាអែ
លទៀតផង។ ២៩អ្នកណាលះបង់ផ្ទះសំបែង បងប្អូន
ប្រុសស្រី ឪពុកម្ដាយ កូន ឬស្រែចម្ការ ព្រោះតែខ្ញុំ
អ្នកនោះនឹងបានទទួលវិញ មួយជាមួយរយ[a] ព្រម
ទាំងមានជីវិតអស់កល្បជានិច្ច។ ៣០មានមនុស្សជា
ច្រើនដែលនៅខាងមុខ នឹងត្រឡប់ទៅនៅខាង
ក្រោយ រីឯអ្នកដែលនៅខាងក្រោយ នឹងត្រឡប់ទៅ
នៅខាងមុខវិញ»។

## ប្រស្នាអំពីកម្មករចម្ការទំពាំងបាយជូរ

២០ ១«ព្រះរាជ្យ នៃស្ថានបរមសុខ* ប្រៀបបាន នឹង
ម្ចាស់ចម្ការម្នាក់ ដែលចាកចេញពីផ្ទះតាំងពីព្រលឹម
ដើម្បីរកជួលកម្មករមកធ្វើការ នៅក្នុងចម្ការទំពាំង
បាយជូររបស់គាត់។ ២គាត់ព្រមព្រៀងជាមួយពួកកម្ម
ករជាស្រេចថា នឹងឲ្យប្រាក់មួយដួង*ក្នុងមួយថ្ងៃ
ហើយចាត់គេឲ្យទៅធ្វើការក្នុងចម្ការ។ ៣ប្រមាណជា
ម៉ោងប្រាំបួនព្រឹក គាត់ចេញទៅឃើញអ្នកផ្សេងទៀត
កំពុងតែឈរនៅតាមទីផ្សារឥតធ្វើអ្វីសោះ។ ៤គាត់ក៏
និយាយទៅកាន់គេថា "ចូរអ្នករាល់គ្នាទៅធ្វើការនៅ
ចម្ការខ្ញុំដែរទៅ ខ្ញុំនឹងឲ្យប្រាក់ឈ្នួលត្រឹមត្រូវ"។ ៥អ្នក
ទាំងនោះក៏នាំគ្នាទៅធ្វើការនៅចម្ការ។ ម្ចាស់ចម្ការ
ចេញទៅសាជាថ្មីទៀតនៅម៉ោងដប់ពីរ និងម៉ោងបី
រសៀលហើយជួលអ្នកផ្សេងតាមរបៀបដដែល។ ៦
ប្រមាណជាម៉ោងប្រាំល្ងាច គាត់ចេញទៅសាជាថ្មី
ឃើញអ្នកខ្លះទៀតឈរនៅតាមទីផ្សារ។ គាត់សួរគេ
ថា"ហេតុដូចម្ដេចបានជាអ្នករាល់គ្នាឈរនៅទីនេះ
មួយថ្ងៃវាល់ល្ងាច ឥតធ្វើអ្វីសោះដូច្នេះ?" ៧ពួកគេ
ឆ្លើយថា "មកពីគ្មាននរណាជួលយើងខ្ញុំទៅធ្វើការ
ទេ!"។ គាត់ក៏ពោលទៅអ្នកទាំងនោះថា "ចូរអ្នករាល់
គ្នាទៅធ្វើការនៅចម្ការខ្ញុំដែរទៅ"។

៨លុះដល់ល្ងាចម្ចាស់ចម្ការ ប្រាប់ទៅអ្នកកាន់
ប្រាក់ថា "ចូរហៅពួកកម្មករមក ហើយបើកប្រាក់ឲ្យ
គេ គឺចាប់ផ្ដើមពីអ្នកដែលចូលធ្វើការក្រោយគេបង្អស់
រហូតដល់អ្នកមកមុនគេបង្អស់"។ ៩ពួកអ្នកដែលបាន
ចាប់ផ្ដើមធ្វើការ ម៉ោងប្រាំល្ងាច មកដល់ទទួលប្រាក់
ម្នាក់មួយដួង*ៗ។ ១០ពួកអ្នកដែលចាប់ផ្ដើមធ្វើការមុន
គេ ក៏មកដល់ដែរ ហើយគិតថានឹងបានប្រាក់ច្រើន
ជាង ប៉ុន្តែគេទទួលម្នាក់មួយដួងដូចៗគ្នា។ ១១គេ
ទទួលយកប្រាក់ទាំងរអ៊ូរទាំដាក់ម្ចាស់ចម្ការថា ១២"
ពួកអ្នកដែលមកដល់ក្រោយនេះបានធ្វើការតែមួយ

ម៉ោងប៉ុណ្ណោះ រីឯយើងខ្ញុំវិញ យើងខ្ញុំធ្វើការហាលថ្ងៃ
ហាលក្ដៅ ហើយលោកបែរជាបើកប្រាក់ឲ្យគេស្មើនឹង
យើងខ្ញុំដែរ!"។ ១៣ម្ចាស់ចម្ការនិយាយទៅកាន់ម្នាក់
ក្នុងចំណោមកម្មករទាំងនោះថា "សំឡាញ់អើយ!ខ្ញុំ
មិនបានបោកបញ្ឆោតអ្នកទេ។ អ្នកបានយល់ព្រមធ្វើ
ការឲ្យខ្ញុំមួយដួងក្នុងមួយថ្ងៃ មែនឬមិនមែន! ១៤ចូរ
យកប្រាក់ឈ្នួលរបស់អ្នក ហើយចេញទៅចុះ! ខ្ញុំចង់
ឲ្យអ្នកដែលមកដល់ក្រោយ ទទួលប្រាក់ស្មើនឹងអ្នក
ដែរ។ ១៥តើខ្ញុំគ្មានសិទ្ធិនឹងយកប្រាក់របស់ខ្ញុំ ទៅធ្វើអ្វី
តាមបំណងចិត្តខ្ញុំទេឬ? ឬមួយអ្នកច្រណែន មកពី
ឃើញខ្ញុំមានចិត្តសប្បុរស?"។ ១៦ហេតុនេះអ្នកដែល
នៅខាងក្រោយនឹងត្រឡប់ទៅនៅខាងមុខ រីឯអ្នក
ដែលនៅខាងមុខនឹងត្រឡប់ទៅនៅខាងក្រោយវិញ»
។

## ព្រះយេស៊ូប្រកាសអំពីព្រះអង្គចូលទិវង្គត

(ម៉ាកុស ១០.៣២-៣៤ លូកា ១៨.៣១-៣៤)

១៧កាលព្រះយេស៊ូកំពុងយាងឡើង ទៅក្រុង
យេរូសាឡឹម ព្រះអង្គនាំសាវ័ក*ទាំងដប់ពីររូបទៅដាច់
ឡែកពីគេ។ នៅតាមផ្លូវ ព្រះអង្គមានព្រះបន្ទូលទៅ
គេថា៖ ១៨«ឥឡូវនេះ យើងឡើងទៅក្រុងយេរូសាឡឹ
ម។ បុត្រមនុស្សនឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃ
របស់ពួកនាយកបូជាចារ្យ* និងពួកធម្មាចារ្យ* គេនឹង
កាត់ទោសប្រហារជីវិតលោក។ ១៩គេនឹងបញ្ជូន
លោកទៅក្នុងកណ្ដាប់ដៃរបស់សាសន៍ដទៃ ដើម្បីឲ្យ
ពួកនោះចំអកដាក់លោកយករំពាត់វាយលោក ព្រម
ទាំងឆ្កាងសម្លាប់លោកទៀតផង ប៉ុន្តែ បីថ្ងៃក្រោយ
មក លោកនឹងរស់ឡើងវិញ»។

## សំណូមពររបស់ម្ដាយលោកយ៉ាកុប និង លោកយ៉ូហាន

(ម៉ាកុស ១០.៣៥-៤៥ លូកា ២២.២៤-២៧)

២០ពេលនោះ ភរិយារបស់លោកសេបេដេបាន
នាំកូនទាំងពីរ ចូលមកគាត់ក្រាបទៀបព្រះបាទាព្រះ
យេស៊ូ ចង់ទូលសុំអ្វីមួយ។ ២១ព្រះអង្គមានព្រះបន្ទូល
សួរគាត់ថា៖ «អ្នកចង់បានអ្វី?»។ គាត់ទូលព្រះអង្គ
វិញថា៖ «ដល់ពេលព្រះអង្គគ្រងរាជ្យសូមឲ្យកូន
របស់ខ្ញុំម្ចាស់បានអង្គុយអមព្រះអង្គផង គឺម្នាក់នៅ
ខាងស្ដាំម្នាក់នៅខាងឆ្វេង»។ ២២ព្រះយេស៊ូមានព្រះ
បន្ទូលតបថា៖ «អ្នកមិនដឹងថាខ្លួនសុំអ្វីឡើយ តើអ្នក
ទាំងពីរអាចទទួលពែង[៨] ដែលខ្ញុំត្រូវទទួលនោះបាន
ឬទេ?»។ លោកយ៉ាកុបនិងលោកយ៉ូហានទូលថា៖
«យើងខ្ញុំអាចទទួលបាន»។ ២៣ព្រះអង្គមានព្រះ
បន្ទូលទៅអ្នកទាំងពីរថា៖ «អ្នកនឹងទទួលពែងរបស់
ខ្ញុំបានមែន ចំណែកឯអង្គុយនៅខាងស្ដាំឬខាងឆ្វេងខ្ញុំ
នោះ ខ្ញុំមិនអាចសម្រេចឲ្យឡើយ ព្រោះកន្លែងនោះ
បម្រុងទុកសម្រាប់ តែអស់អ្នកដែលព្រះបិតារបស់ខ្ញុំ
បានសម្រេចឲ្យប៉ុណ្ណោះ»។

២៤កាលសាវ័ក*ដប់រូបទៀតបានឮដូច្នោះ គេ
ទាស់ចិត្តនឹងបងប្អូនទាំងពីរនាក់នេះណាស់។២៥ព្រះ
យេស៊ូត្រាស់ហៅសាវ័កទាំងអស់មក ហើយមានព្រះ
បន្ទូលថា៖ «អ្នករាល់គ្នាដឹងស្រាប់ហើយ ពួកអ្នកគ្រប់
គ្រងស្រុក តែងតែជិះជាន់ប្រជារាស្ត្ររបស់ខ្លួន រីឯអ្នក
ធំក៏តែងតែប្រើអំណាច លើប្រជារាស្ត្ររបស់ខ្លួនដែរ។
២៦ក្នុងចំណោមអ្នករាល់គ្នាមិនមែនដូច្នោះទេ។ ផ្ទុយ
ទៅវិញ បើមានអ្នកណាម្នាក់ចង់ធ្វើធំជាងគេ ក្នុង
ចំណោមអ្នករាល់គ្នា ត្រូវឲ្យអ្នកនោះបម្រើអ្នករាល់គ្នាវិ
ញ។ ២៧បើមានអ្នកណាម្នាក់ចង់ធ្វើមេគេក្នុងចំណោម
អ្នករាល់គ្នា អ្នកនោះត្រូវធ្វើជាខ្ញុំបម្រើរបស់អ្នករាល់គ្នា
សិន។ ២៨បុត្រមនុស្សមកក្នុងពិភពលោកនេះ មិន
មែនដើម្បីឲ្យគេបម្រើលោកទេ គឺលោកមកបម្រើគេ
វិញ ព្រមទាំងបូជាជីវិតដើម្បីលោះមនុស្សទាំងអស់
ផង»។

## ព្រះយេស៊ូប្រោសមនុស្សខ្វាក់ពីរនាក់ឲ្យបានភ្លឺ

(ម៉ាកុស ១០.៤៦-៥២ លូកា ១៨.៣៥-៤៣)

២៩កាលព្រះយេស៊ូយាងចេញពីក្រុងយេរីខូ
មានបណ្ដាជនច្រើនកុះករនាំគ្នាដើរតាមព្រះអង្គ ៣០
ពេលនោះ មានមនុស្សខ្វាក់ពីរនាក់អង្គុយនៅក្បែរផ្លូ
វ។ អ្នកទាំងពីរឮថាព្រះយេស៊ូយាងមក ក៏ស្រែកឡើង
ថា៖ «ឱព្រះអម្ចាស់ជាព្រះរាជវង្សព្រះបាទដាវីឌ
អើយ! សូមអាណិតមេត្តាយើងខ្ញុំផង!»។ ៣១ បណ្ដា
ជនគំរាមអ្នកទាំងពីរ ឲ្យនៅស្ងៀមប៉ុន្តែ គេស្រែករឹត
តែខ្លាំងឡើងថា៖ «ឱព្រះអម្ចាស់ ជាព្រះរាជវង្ស
ព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាយើងខ្ញុំផង!»
។ ៣២ព្រះយេស៊ូក៏ឈប់ ហើយហៅគេមកសួរថា៖ «
តើអ្នកចង់ឲ្យខ្ញុំធ្វើអ្វី?»។ ៣៣គេទូលព្រះអង្គថា៖ «
បពិត្រព្រះអម្ចាស់! សូមប្រោសឲ្យភ្នែកយើងខ្ញុំបានភ្លឺ
ផង»។ ៣៤ ព្រះយេស៊ូមានព្រះហឫទ័យអាណិត
អាសូរអ្នកទាំងពីរពន់ពេកណាស់ ព្រះអង្គក៏ពាល់ភ្នែក
គេ។ រំពេចនោះ គេមើលឃើញភ្លាម ហើយនាំគ្នាដើរ
តាមព្រះយេស៊ូទៅ។

## ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

(មក.១១.១-១១ លក.១៩.២៨-៤០ យហ.១២.១២-១៩)

២១ ១ព្រះយេស៊ូយាងមក ជាមួយពួកសាវ័ក* ជិតដល់
ក្រុងយេរូសាឡឹមហើយ។ កាលមកដល់ភូមិបេតផា
សេ ដែលនៅចង្កេះភ្នំដើមអូលីវ ព្រះអង្គចាត់សាវ័កពីរ
នាក់ ឲ្យទៅមុន ២ទាំងមានព្រះបន្ទូលថា៖ «ចូរទៅ
ភូមិដែលនៅមុខអ្នករាល់គ្នា។ ពេលទៅដល់ភ្លាម អ្នក
នឹងឃើញមេលាមួយដែលគេចងនៅទីនោះ ហើយ
មានកូនវានៅជាមួយដែរ។ ចូរស្រាយវាដឹកមកឲ្យខ្ញុំ។
៣ប្រសិនបើមាននរណាសួរ ចូរប្រាប់គេថាព្រះអម្ចាស់
ត្រូវការវា តែព្រះអង្គនឹងឲ្យគេដឹកមកវិញភ្លាមជាមិន
ខាន»។ ៤ព្រឹត្តិការណ៍នេះកើតឡើងស្របនឹងសេចក្ដី
ដែលមានចែងទុកតាមរយៈព្យាការី*ថា៖

៥ *«ចូរប្រាប់ប្រជាជនក្រុងស៊ីយ៉ូនថា៖*
*មើលហ្ន៎ ព្រះមហាក្សត្ររបស់អ្នក*
*យាងមករកអ្នកហើយ។*
*ទ្រង់មានព្រះហឫទ័យស្លូតបូត*
*ទ្រង់គង់លើខ្នងលា*
*ហើយគង់លើខ្នងកូនលាផងដែរ»*[ឃ] ។

៦សាវ័កទាំងពីរនាំគ្នាចេញទៅធ្វើតាមបញ្ជា
របស់ព្រះយេស៊ូ ៧ដឹកមេលានិងកូនវាមក។ គេយក
អាវក្រាលពីលើខ្នងលា និងលើខ្នងកូនលាផងហើយ
ព្រះយេស៊ូឡើងគង់លើខ្នងវា។ ៨នៅពេលនោះមាន
បណ្ដាជនជាច្រើននាំគ្នាយកអាវរបស់ខ្លួន ក្រាលតាម
ផ្លូវ ហើយអ្នកខ្លះទៀតកាច់ធាងទន្សែយកមកក្រាល
លើផ្លូវដែរ។ ៩មហាជនដែលដើរហែហមព្រះយេស៊ូពី
មុខពីក្រោយ នាំគ្នាស្រែកឡើងថា៖«ជយោ![ង] ព្រះ
រាជវង្សរបស់ព្រះបាទដាវីឌ! សូមព្រះជាម្ចាស់ប្រទាន
ពរដល់ព្រះអង្គ ដែលយាងមកក្នុងព្រះនាមព្រះ
អម្ចាស់![ច] ជយោ! ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់
បំផុត!»។

១០កាលព្រះយេស៊ូយាងទៅដល់ ក្រុងយេរូសា
ឡឹមប្រជាជន នៅក្នុងទីក្រុងទាំងមូលនាំគ្នាជ្រួល
ច្របល់សួរថា៖ «តើលោកនោះជានរណា?»។ ១១
មហាជនឆ្លើយថា៖ «លោកជាព្យាការី*យេស៊ូមកពី
ភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ»។

## ព្រះយេស៊ូដេញពួកអ្នកលក់ដូរចេញពីព្រះវិហារ

(មក.១១.១៥-១៩ លក.១៩.៤៥-៤៨ យហ.២.១៣-២២)

១២បន្ទាប់មក ព្រះយេស៊ូចូលព្រះវិហារ ហើយ
ព្រះអង្គដេញអ្នកលក់ដូរចេញពីទីនោះ។ ព្រះអង្គផ្ដួល
តុអ្នកដូរប្រាក់ ផ្ដួលកៅអីរបស់អ្នកលក់ព្រាប។ ១៣ព្រះ
អង្គមានព្រះបន្ទូលទៅគេថា៖ «ក្នុងគម្ពីរមានចែងថា

"ដំណាក់របស់យើងត្រូវធ្វើជាកន្លែងសម្រាប់
អធិស្ឋាន*[ឋ] តែអ្នករាល់គ្នាបែរជាយកធ្វើជាសំបុកចោរ
[ឱ]ទៅវិញ!"»។

១៤មានមនុស្សខ្វាក់ និងមនុស្សខ្វិននាំគ្នាមករក
ព្រះអង្គនៅក្នុងព្រះវិហារ ព្រះអង្គក៏ប្រោសគេឲ្យជា
ទាំងអស់គ្នា។

១៥កាលក្រុមនាយកបូជាចារ្យ* និងពួកធម្មាចា
រ្យ* ឃើញការអស្ចារ្យដែលព្រះអង្គបានធ្វើនិងឮក្មេងៗ
ស្រែកនៅក្នុងព្រះវិហារថា «ជយោព្រះរាជវង្ស
ព្រះបាទដាវីឌ!» គេទាស់ចិត្តណាស់ ១៦គេទូលព្រះ
អង្គថា៖ «តើលោកឮក្មេងៗស្រែកថាដូចម្ដេចទេ?»
។ ព្រះយេស៊ូមានព្រះបន្ទូលទៅ គេវិញថា៖ «ខ្ញុំឮ
ហើយ! ក្នុងគម្ពីរមានចែងថា "ព្រះអង្គបានធ្វើឲ្យពាក្យ
សរសើរតម្កើង ហូរចេញពីបបូរមាត់ក្មេងតូចៗ និង
ទារកដែលនៅបៅ"[ឃ]តើអស់លោកមិនដែលអានទេ
ឬ?»។ ១៧ព្រះអង្គទុកគេចោល ទ្រង់យាងចេញពីទី
ក្រុង ឆ្ពោះទៅភូមិបេតថានី ហើយស្នាក់នៅទីនោះ។

## ដើមឧទុម្ពរត្រូវបណ្ដាសា

(ម៉ាកុស ១១.១២-១៤, ២០-២៤)

១៨ព្រលឹមឡើង ព្រះយេស៊ូយាងត្រឡប់ទៅទី
ក្រុងវិញ ពេលនោះ ព្រះអង្គឃ្លាន។ ១៩ព្រះអង្គទត
ឃើញឧទុម្ពរមួយដើមនៅតាមផ្លូវ ទ្រង់យាងចូលទៅ
ជិត មិនឃើញមានផ្លែសោះ មានសុទ្ធតែស្លឹក។ ទ្រង់
មានព្រះបន្ទូលទៅកាន់ដើមឧទុម្ពរនោះថា៖ «ចាប់ពី
ពេលនេះតទៅ កុំឲ្យឯងមានផ្លែសោះឡើយ!»។
ពេលនោះ ស្រាប់តែដើមឧទុម្ពរក្រៀមស្វិតមួយរំពេ
ច។ ២០ឃើញដូច្នោះពួកសាវ័ក*ងឿងឆ្ងល់ជាខ្លាំង គេ
ពោលថា៖ «ហេតុដូចម្ដេចបានជាដើមឧទុម្ពរក្រៀម
ស្វិតមួយរំពេចដូច្នេះ?»។ ២១ព្រះយេស៊ូមានព្រះ
បន្ទូលឆ្លើយទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹង
ច្បាស់ថា ប្រសិនបើអ្នករាល់គ្នាមានជំនឿ ឥត
សង្ស័យសោះ អ្នករាល់គ្នាមិនត្រឹមតែអាចធ្វើឲ្យដើម
ឧទុម្ពរនេះក្រៀមស្វិតប៉ុណ្ណោះទេ គឺបើអ្នករាល់គ្នា
ពោលទៅកាន់ភ្នំនេះថា៖ "ចូរចេញពីទីនេះធ្លាក់ក្នុងស
មុទ្រទៅ!" នោះនឹងសម្រេចដូច្នោះជាមិនខាន។ ២២អ្វី
ក៏ដោយឲ្យតែអ្នករាល់គ្នាអធិស្ឋាន*សុំទាំងមានជំនឿ
អ្នករាល់គ្នាមុខជាបានទទួលមែន»។

## អំណាចរបស់ព្រះយេស៊ូ

(ម៉ាកុស ១១.២៧-៣៣ លូកា ២០.១-៨)

២៣ព្រះយេស៊ូយាងចូលក្នុងព្រះវិហារ* ហើយ
នៅពេលព្រះអង្គកំពុងតែបង្រៀនគេ ពួកនាយកបូជា
ចារ្យ* និងពួកព្រឹទ្ធាចារ្យ*របស់ប្រជាជននាំគ្នាចូលមក
សួរព្រះអង្គថា៖ «តើលោកធ្វើការទាំងនេះដោយអាង
អំណាចអ្វី? អ្នកណាប្រគល់អំណាចនេះឲ្យលោក?»
។ ២៤ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ខ្ញុំក៏សុំសួរ
សំណួរតែមួយ ដល់អស់លោកដែរ បើអស់លោក
ប្រាប់ខ្ញុំ ខ្ញុំនឹងប្រាប់អស់លោកវិញថា ខ្ញុំធ្វើការទាំង
នេះ ដោយអាងលើអំណាចអ្វី។ ២៥តើនរណាចាត់
លោកយ៉ូហាន ឲ្យមកធ្វើពិធីជ្រមុជទឹក*? ព្រះជា
ម្ចាស់ ឬមនុស្ស?»។ គេពិគ្រោះគ្នាថា៖ «បើយើង
ឆ្លើយថា "ព្រះជាម្ចាស់ចាត់លោកយ៉ូហានឲ្យមក"
គាត់មុខជាសួរយើងថា "ហេតុអ្វីបានជាអ្នករាល់គ្នា
មិនជឿលោកយ៉ូហាន?" ២៦បើយើងឆ្លើយថា
"មនុស្សចាត់លោកយ៉ូហានឲ្យមក" នោះយើងខ្លាច
ប្រជាជនរករឿង ដ្បិតមនុស្សគ្រប់ៗគ្នាចាត់ទុកលោក
យ៉ូហានជាព្យាការី*»។ ២៧ដូច្នេះ គេទូលឆ្លើយព្រះ
យេស៊ូថា៖ «យើងមិនដឹងទេ!»។ ព្រះអង្គមានព្រះ
បន្ទូលទៅវិញថា៖ «រីឯខ្ញុំវិញ ខ្ញុំក៏មិនប្រាប់អស់លោក
ថា ខ្ញុំធ្វើការទាំងនេះដោយអាងលើអំណាចអ្វីដែរ»។

## ប្រស្នាអំពីកូនប្រុសពីរនាក់

២៨«អ្នករាល់គ្នាយល់យ៉ាងណាដែរ ប្រសិនបើ
បុរសម្នាក់មានកូនប្រុសពីរ ហើយគាត់និយាយទៅ

កាន់កូនច្បងថា "កូនអើយ! ថ្ងៃនេះចូរកូនទៅធ្វើការ
នៅចម្ការទំពាំងបាយជូររបស់ពុកទៅ!"។ ២៩កូនតប
មកវិញថា"ខ្ញុំមិនចង់ទៅទេ!" ប៉ុន្តែក្រោយមក កូន
នោះដូរគំនិត ហើយក៏ទៅចម្ការ។ ៣០បន្ទាប់មក ឪពុក
និយាយពាក្យដដែលទៅកាន់កូនពៅ កូនពៅឆ្លើយថា
៖ "បាទកូនទៅ!" តែអត់ទៅទេ។ ៣១ក្នុងចំណោមកូន
ទាំងពីរនាក់ តើកូនណាបានធ្វើតាមបំណងឪពុក?»
។ គេទូលព្រះអង្គថា៖ «កូនច្បង»។ព្រះយេស៊ូមាន
ព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹង
ច្បាស់ថា ពួកអ្នកទារពន្ធ* និងពួកស្ត្រីពេស្យា នឹង
ចូលទៅក្នុងព្រះរាជ្យ*របស់ព្រះជាម្ចាស់ មុនអ្នករាល់
គ្នា ៣២ដ្បិតលោកយ៉ូហានបានមកណែនាំអ្នករាល់គ្នា
ឲ្យដើរតាមមាគ៌ាសុចរិត តែអ្នករាល់គ្នាមិនព្រមជឿ
លោកទេ។ ពួកអ្នកទារពន្ធនិងស្ត្រីពេស្យាបានជឿ
លោក រីឯអ្នករាល់គ្នាវិញ ទោះបីអ្នករាល់គ្នាបាន
ឃើញហេតុការណ៍ទាំងនោះ ក៏ដោយ ក៏អ្នករាល់គ្នា
មិនបានដូរចិត្តគំនិត ហើយជឿលោកដែរ»។

## ប្រស្នាអំពីអ្នកថែរក្សាចម្ការទំពាំងបាយជូរ

(ម៉ាកុស ១២.១-១២ លូកា ២០.៩-១៩)

៣៣«សុំស្ដាប់ប្រស្នាមួយទៀត៖ មានបុរសម្នាក់
ជាម្ចាស់ចម្ការ គាត់បានដាំទំពាំងបាយជូរ ហើយធ្វើ
របងព័ទ្ធជុំវិញ គាត់រៀបចំកន្លែងមួយ ដើម្បីបញ្ចាន់ផ្លែ
ទំពាំងបាយជូរ ព្រមទាំងសង់ខ្ទមមួយផង។ បន្ទាប់
មក គាត់ប្រវាស់ឲ្យពួកកសិករ មើលថែទាំ រួចចេញ
ដំណើរពីស្រុកនោះទៅ។ ៣៤លុះដល់រដូវទំពាំងបាយ
ជូរទុំ គាត់ក៏ចាត់ពួកអ្នកបម្រើ ឲ្យមកជួបអ្នកថែចម្ការ
ទាំងនោះ ដើម្បីទទួលយកផលដែលជាចំណែករបស់
គាត់។ ៣៥ពួកកសិករនាំគ្នាចាប់ពួកអ្នកបម្រើមកវាយ
ដំម្នាក់ ប្រហារជីវិតម្នាក់ និងយកដុំថ្មគប់សម្លាប់ម្នាក់
ទៀត។ ៣៦ម្ចាស់ចម្ការក៏ចាត់អ្នកបម្រើផ្សេងទៀត
ដែលមានគ្នាច្រើនជាងមុន ឲ្យមក។ប៉ុន្តែ ពួកអ្នកថែ
ចម្ការបានធ្វើបាបអ្នកបម្រើទាំងនោះ ដូចពួកមុនៗដែ
រ។ ៣៧នៅទីបំផុត ម្ចាស់ចម្ការចាត់កូនប្រុសរបស់គាត់
ឲ្យមកជួបគេ ដោយគិតថា "គេមុខជាគោរពកោត
ខ្លាចកូនប្រុសខ្ញុំ មិនខាន"។ ៣៨ប៉ុន្តែ ពេលពួកកសិករ
ឃើញកូនប្រុសម្ចាស់ចម្ការមកដល់ គេពិគ្រោះគ្នាថា៖
"អ្នកនេះជាអ្នកទទួលកេរមត៌កពីម្ចាស់ចម្ការទៅថ្ងៃ
ក្រោយ បើយើងនាំគ្នាសម្លាប់វា មត៌កនេះនឹងត្រូវបាន
មកយើងមិនខាន"។ ៣៩គេក៏ចាប់កូនប្រុសម្ចាស់
ចម្ការ បោះទៅខាងក្រៅ ហើយសម្លាប់ចោលទៅ។
៤០ដល់ពេលម្ចាស់ចម្ការមក តើគាត់នឹងធ្វើយ៉ាងណា
ចំពោះកសិករទាំងនោះ?»។ ៤១គេទូលព្រះអង្គថា៖
«គាត់មុខជាសម្លាប់ជនពាលទាំងនោះ ឥតត្រាប្រណី
ឡើយ រួចប្រវាស់ចម្ការ ឲ្យអ្នកផ្សេងទៀត ដែលនឹង
ប្រគល់ផលជាចំណែករបស់គាត់ជូនគាត់ នៅរដូវ
ទំពាំងបាយជូរទុំ»។ ៤២ព្រះយេស៊ូមានព្រះបន្ទូលទៅ
គេថា៖ «ក្នុងគម្ពីរមានចែងថា៖

*"ថ្មដែលពួកជាងសង់ផ្ទះបោះចោល*
*បានត្រឡប់មកជាថ្មគ្រឹះដ៏សំខាន់បំផុត។*
*ព្រះអម្ចាស់បានសម្រេចការអស្ចារ្យនេះ*
*យើងបានឃើញ ហើយស្ងើចសរសើរផង"[ណ]។*
*តើអ្នករាល់គ្នាដែលអានអត្ថបទនេះឬទេ?។*

៤៣ហេតុនេះហើយបានជា ខ្ញុំសុំប្រាប់អ្នករាល់
គ្នាថា ព្រះជាម្ចាស់នឹងដកព្រះរាជ្យចេញពីអ្នករាល់គ្នា
ប្រគល់ទៅឲ្យសាសន៍មួយទៀត ដែលចេះបង្កើតផល
សមស្របនឹងព្រះរាជ្យ។ ៤៤អ្នកណាដួលលើថ្មនេះ
អ្នកនោះមុខជាត្រូវបាក់បែកខ្ទេចខ្ទាំមិនខាន ហើយបើ
ថ្មនេះសង្កត់លើអ្នកណា មុខជាកិនកម្ទេចអ្នកនោះ ឲ្យ
ស្លាប់ជាប្រាកដដែរ»។

៤៥ពួកនាយកបូជាចារ្យ* និងពួកខាងគណៈផារី
ស៊ី*ឮដូច្នោះក៏ដឹងថា ព្រះអង្គមានព្រះបន្ទូលសំដៅ
ទៅលើពួកគេ។ ៤៦គេនាំគ្នារកមធ្យោបាយចាប់ព្រះ
អង្គ ប៉ុន្តែ គេខ្លាចមហាជន ព្រោះមហាជនចាត់ទុក

ព្រះយេស៊ូជាព្យាការី*មួយរូប។

## ប្រស្នាអំពីមង្គលការ

(លូកា ១៤.១៦-២៤)

២២ ១ព្រះយេស៊ូមានព្រះបន្ទូល ជាប្រស្នា ទៅពួកគេ
ម្ដងទៀតថា៖ ២«ព្រះរាជ្យ*នៃស្ថានបរមសុខ* ប្រៀប
បាននឹងស្ដេចមួយអង្គ ដែលរៀបវិវាហមង្គលការព្រះ
រាជបុត្រ។ ៣ព្រះរាជាចាត់រាជបម្រើ ឲ្យទៅអញ្ជើញ
ភ្ញៀវមកជប់លៀង ក្នុងឱកាសមង្គលការនោះ តែគ្មាន
នរណាមកសោះ។ ៤ព្រះអង្គចាត់រាជបម្រើផ្សេងទៀត
ឲ្យទៅជម្រាបភ្ញៀវថា៖ "យើងបានរៀបចំភោជនា
ហារសម្រាប់ជប់លៀង គឺបានសម្លាប់គោ និងសម្លាប់
សត្វដែលបានបំប៉ននោះរួចរាល់អស់ហើយ សូម
អញ្ជើញមកពិសាការ!"។ ៥ប៉ុន្តែភ្ញៀវមិនរវីរវល់អើពើ
ឡើយ អ្នកខ្លះទៅចម្ការ អ្នកខ្លះទៅធ្វើជំនួញ ៦អ្នកខ្លះ
ទៀតចាប់ពួករាជបម្រើ វាយធ្វើបាប ព្រមទាំងសម្លាប់
ចោលថែមទៀត។ ៧ព្រះរាជាទ្រង់ព្រះពិរោធយ៉ាង
ខ្លាំង ក៏ចាត់ទាហានឲ្យទៅប្រហារជីវិតឃាតករទាំង
នោះ ហើយដុតកម្ទេចស្រុកភូមិរបស់គេផង។ ៨
បន្ទាប់មក ទ្រង់មានរាជឱង្ការទៅពួករាជបម្រើថា៖
"យើងបានរៀបចំពិធីមង្គលការរួចស្រេចហើយ ប៉ុន្តែ
ភ្ញៀវទាំងនោះមិនសមនឹងមកចូលរួមទេ។ ៩ហេតុនេះ
ចូរនាំគ្នាចេញទៅតាមផ្លូវកែង ហើយអញ្ជើញមនុស្ស
ទាំងអស់ ដែលអ្នករាល់គ្នាជួបឲ្យមកជប់លៀង"។ ១០
ពួករាជបម្រើក៏ចេញទៅតាមផ្លូវ ប្រមូលមនុស្សម្នា
ដែលគេបានជួបទាំងប៉ុន្មានមក ទាំងអាក្រក់ ទាំង
ល្អ។ ពេលនោះមានភ្ញៀវពេញរោងការ។
១១ព្រះរាជាយាងចូលមកមើលភ្ញៀវ នៅក្នុងរោង
ការ ទតឃើញបុរសម្នាក់ស្លៀកពាក់មិនត្រូវនឹងរបៀប
ពិធីការ ១២ទ្រង់ក៏មានរាជឱង្ការទៅអ្នកនោះថា "សំ
ឡាញ់អើយ! ហេតុអ្វីបានជាអ្នកចូលមកទីនេះដោយ
មិនស្លៀកសម្លៀកបំពាក់ សម្រាប់មង្គលការដូច្នេះ?"
បុរសនោះរកនិយាយអ្វីមិនចេញឡើយ។ ១៣ព្រះរាជា
បង្គាប់ទៅពួករាជបម្រើថា "ចូរចងដៃចងជើងអ្នកនេះ
សែងយកទៅចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំ
សោកខឹងសង្កៀតធ្មេញនោះទៅ!"»។ ១៤ព្រះយេស៊ូ
មានព្រះបន្ទូលទៀតថា៖ «ព្រះជាម្ចាស់ត្រាស់ហៅ
មនុស្សទាំងអស់ តែព្រះអង្គជ្រើសរើសយកបានចំនួន
តិចទេ»។

## អំពីពន្ធដារ

(ម៉ាកុស ១២.១៣-១៧ លូកា ២០.២០-២៦)

១៥ពួកខាងគណៈផារីស៊ី* ចេញទៅពិគ្រោះគ្នារិះ
រកមធ្យោបាយចាប់កំហុសព្រះយេស៊ូ នៅពេលព្រះ
អង្គមានព្រះបន្ទូល។ គេក៏ចាត់សិស្សរបស់គេនិងពួក
ខាងស្ដេចហេរ៉ូដ ឲ្យទៅជួបព្រះអង្គ ហើយទូលថា៖
«លោកគ្រូ! យើងខ្ញុំដឹងថាពាក្យដែលលោកមាន
ប្រសាសន៍ សុទ្ធតែពិតទាំងអស់។ លោកគ្រូប្រៀន
ប្រដៅអំពីរបៀបរស់នៅ ដែលគាប់ព្រះហឫទ័យព្រះ
ជាម្ចាស់តាមសេចក្ដីពិត គឺលោកគ្រូពុំយោគយល់
ហើយក៏ពុំរើសមុខនរណាឡើយ។ ១៧ហេតុនេះ សូម
លោកគ្រូឲ្យយោបល់យើងខ្ញុំមើល៍ តើវិន័យរបស់
យើងអនុញ្ញាត ឲ្យបង់ពន្ធដារថ្វាយព្រះចៅអធិរាជរ៉ូ
ម៉ាំងឬទេ?»។ ១៨ព្រះយេស៊ូឈ្វេងយល់គំនិតអាក្រក់
របស់ពួកគេ ទើបមានព្រះបន្ទូលថា៖ «មនុស្សមាន
ពុតអើយ! ហេតុអ្វីបានជាអ្នករាល់គ្នាចង់ចាប់កំហុស
ខ្ញុំដូច្នេះ? ១៩ចូរបង្ហាញប្រាក់សម្រាប់បង់ពន្ធនោះឲ្យខ្ញុំ
មើលមើល៍!»។ គេក៏យកប្រាក់មួយកាក់មកថ្វាយព្រះ
អង្គ។ ២០ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «តើលើ
កាក់នេះមានរូបនរណា ឈ្មោះនរណា?»។ ២១គេ
ទូលថា៖ «រូបនិងឈ្មោះព្រះចៅអធិរាជ»។ ព្រះអង្គ
ក៏មានព្រះបន្ទូលទៅគេថា៖«អ្វីៗដែលជារបស់ព្រះ
ចៅអធិរាជ ចូរថ្វាយទៅព្រះចៅអធិរាជវិញទៅ ហើយ
អ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅព្រះជា
ម្ចាស់វិញដែរ»។ ២២ពួកគេងឿងឆ្ងល់នឹងចម្លើយរបស់

ព្រះអង្គហើយនាំគ្នាចាកចេញពីព្រះអង្គទៅ។

## អំពីមនុស្សស្លាប់នឹងរស់ឡើងវិញ

(ម៉ាកុស១២.១៨-២៧ លូកា២០.២៧-៤០)

២៣នៅថ្ងៃនោះ មានពួកខាងគណៈសាឌូស៊ី*
ចូលមកគាល់ព្រះអង្គ។ ពួកសាឌូស៊ីមិនជឿថា
មនុស្សស្លាប់នឹងរស់ឡើងវិញទេ។ គេទូលសួរព្រះ
យេស៊ូថា៖ ២៤«លោកគ្រូ! លោកម៉ូសេ*មាន
ប្រសាសន៍ថា៖ "បើបុរសណាស្លាប់ទៅ តែគ្មានកូន
សោះ ត្រូវឲ្យប្អូនប្រុសរបស់បុរសនោះរៀបការនឹង
បងថ្លៃ ដើម្បីបន្តពូជឲ្យបងប្រុសរបស់ខ្លួន"ត។ ២៥
ឧបមាថា នៅក្នុងចំណោមយើង មានបងប្អូនប្រុស
ប្រាំពីរនាក់។ បងបង្អស់រៀបការ ហើយស្លាប់ទៅ តែ
គ្មានកូនសោះ ទុកប្រពន្ធឲ្យប្អូន។ ២៦ប្អូនទីពីរប្អូនទីបី
រហូតដល់ប្អូនទីប្រាំពីរ សុទ្ធតែបានរៀបការជាមួយ
នាង ហើយស្លាប់ទៅគ្មានកូនដូចគ្នា។ ២៧នៅទីបំផុត
ស្ត្រីនោះក៏ស្លាប់ទៅដែរ។ ២៨លុះដល់ពេលមនុស្ស
ស្លាប់នឹងរស់ឡើងវិញ តើនាងបានទៅជាប្រពន្ធ
នរណា បើបងប្អូនទាំងប្រាំពីរនាក់សុទ្ធតែបានរៀប
ការជាមួយនាងគ្រប់គ្នាដូច្នេះ?»។ ២៩ព្រះយេស៊ូមាន
ព្រះបន្ទូលតបទៅគេថា៖ «អ្នករាល់គ្នាយល់ខុស
ហើយ! ដ្បិតអ្នករាល់គ្នាមិនយល់គម្ពីរទាំងមិនស្គាល់
ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ផង។ ៣០ពេលមនុស្ស
ស្លាប់នឹងរស់ឡើងវិញ គេមិនរៀបការប្ដីប្រពន្ធទៀត
ឡើយ គឺគេនឹងបានដូចទេវទូត* នៅស្ថានបរមសុខ*
។ ៣១ព្រះជាម្ចាស់មានព្រះបន្ទូលអំពីមនុស្សស្លាប់នឹង
រស់ឡើងវិញថា៖ ៣២"យើងជាព្រះរបស់អប្រាហាំជា
ព្រះរបស់អ៊ីសាក និងជាព្រះរបស់យ៉ាកុប"ថ តើអ្នក
រាល់គ្នាធ្លាប់អានឬទេ? ព្រះជាម្ចាស់មិនមែនជាព្រះ
របស់មនុស្សស្លាប់ទេ គឺជាព្រះរបស់មនុស្សដែលមាន
ជីវិត»។ ៣៣កាលមហាជនបានឮសេចក្ដីដែលព្រះ
អង្គបង្រៀន គេងឿងឆ្ងល់ជាខ្លាំង។

## វិន័យសំខាន់ជាងគេ

(ម៉ាកុស១២.២៨-៣៤ លូកា១០.២៥-២៨)

៣៤ពេលនោះ ពួកខាងគណៈផារីស៊ី*ប្រជុំគ្នា
ព្រោះគេឮថា ព្រះយេស៊ូបានធ្វើឲ្យពួកខាងគណៈសា
ឌូស៊ី*ទ័លប្រាជ្ញ រកនិយាយអ្វីទៀតមិនកើត។ ៣៥ក្នុង
ចំណោមពួកគេ មានម្នាក់ជាធម្មាចារ្យទូលសួរព្រះ
យេស៊ូ ក្នុងគោលបំណងល្បងលមើលព្រះអង្គថា៖
៣៦«លោកគ្រូ! ក្នុងគម្ពីរវិន័យ* តើមានវិន័យណា
សំខាន់ជាងគេ?»។ ៣៧ព្រះយេស៊ូមានព្រះបន្ទូលថា
៖ «"ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យ
អស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា"ទ ៣៨
ហ្នឹងហើយជាវិន័យទីមួយដែលសំខាន់ជាងគេបំផុត។
៣៩រីឯ វិន័យទីពីរក៏សំខាន់ដូចគ្នាដែរ គឺត្រូវស្រឡាញ់
បងប្អូនឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯង"ធ។ ៤០
វិន័យទាំងពីរនេះជាឫសគល់របស់គម្ពីរវិន័យ និងគម្ពីរ
ព្យាការី*ទាំងអស់»។

## ព្រះគ្រីស្ដជាព្រះអម្ចាស់លើស្ដេចដាវីឌ

(ម៉ាកុស១២.៣៥-៣៧ លូកា២០.៤១-៤៤)

៤១ពេលនោះ ពួកខាងគណៈផារីស៊ី*នៅជុំគ្នា
ព្រះយេស៊ូក៏មានព្រះបន្ទូលសួរគេថា៖ ៤២«តើអ្នក
រាល់គ្នាយល់ថា ព្រះគ្រីស្ដជាព្រះរាជវង្សរបស់អ្នក
ណា?»។ គេទូលថា៖ «ព្រះអង្គជាព្រះរាជវង្សរបស់
ព្រះបាទដាវីឌ»។ ៤៣ព្រះអង្គមានព្រះបន្ទូលទៅគេថា
៖ «ប្រសិនបើព្រះគ្រីស្ដជាព្រះរាជវង្សរបស់ព្រះបាទ
ដាវីឌមែន ចុះហេតុដូចម្ដេចបានជាព្រះបាទដាវីឌ
ដែលមានព្រះវិញ្ញាណបំភ្លឺ ហៅព្រះគ្រីស្ដថា"ព្រះ
អម្ចាស់"ទៅវិញដូច្នេះ គឺទ្រង់មានរាជឱង្ការថា៖

៤៤ *"ព្រះអម្ចាស់មានព្រះបន្ទូល*
*ទៅកាន់ព្រះអម្ចាស់របស់ខ្ញុំថា*
*សូមគង់ខាងស្ដាំយើង ទំរាំដល់យើងបង្ក្រាប*
*ខ្មាំងសត្រូវរបស់ព្រះអង្គ*

*មកដាក់ក្រោមព្រះបាទារបស់ព្រះអង្គ*[ន]*។*
៤៥បើព្រះបាទដាវីឌហៅព្រះគ្រីស្តថា "ព្រះ
អម្ចាស់"ដូច្នេះ តើឲ្យព្រះគ្រីស្តត្រូវជាព្រះរាជវង្សរបស់
ព្រះអង្គដូចម្ដេចកើត!»។ ៤៦គ្មាននរណាម្នាក់អាច
ឆ្លើយទៅព្រះអង្គវិញ សូម្បីតែមួយម៉ាត់ក៏មិនបានផង
ហើយចាប់តាំងពីពេលនោះមក គ្មាននរណាហ៊ានសួរ
ដេញដោលព្រះអង្គទៀតឡើយ។

## ព្រះយេស៊ូមានព្រះបន្ទូលឲ្យប្រយ័ត្ន នឹងពុតត្បុតរបស់ពួកធម្មាចារ្យ និងពួកខាងគណៈផារីស៊ី

(ម៉ាកុស១២.៣៨-៤០ លូកា២០.៤៥-៤៧,១១.៣៩-៥២)

២៣ ១ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់
មហាជន និងពួកសាវ័ក*ថា៖ ២«ពួកធម្មាចារ្យ*និង
ពួកខាងគណៈផារីស៊ី* មានភារកិច្ចបង្រៀនធម្មវិន័យ
របស់លោកម៉ូសេ*។ ៣អ្វីៗដែលគេបង្រៀនអ្នករាល់
គ្នា ចូរស្ដាប់ហើយយកទៅប្រតិបត្តិតាមទៅ តែកុំយក
តម្រាប់តាមអំពើដែលគេប្រព្រឹត្តឡើយ ដ្បិតគេមិន
ប្រតិបត្តិតាមសេចក្ដី ដែលគេបង្រៀននោះទេ។ ៤អ្នក
ទាំងនោះបានបង្កើតវិន័យយ៉ាងតឹងរ៉ឹង យកមកផ្ទុក
លើមនុស្ស ហើយមិនជួយសម្រាលបន្ទុកនោះទេ សូ
ម្បីតែបន្តិចបន្តួចក៏មិនជួយផង។ ៥គេធ្វើកិច្ចការផ្សេ
ងៗ ដើម្បីឲ្យមនុស្សម្នាកោតសរសើរគឺគេធ្វើក្លាក់[ប]
កាន់តែធំឡើងៗ និងធ្វើខ្សែរំយោល[ផ]នៅជាយអាវ
កាន់តែវែងទៅៗ។ ៦ពួកគេចូលចិត្តកន្លែងកិត្តិយស
ក្នុងពិធីជប់លៀង ហើយរើសកន្លែងអង្គុយនៅមុខគេ
ក្នុងធម្មសាលា*។ ៧ពួកនេះចូលចិត្តឲ្យគេអោនកាយ
គោរពនៅតាមផ្សារ និងឲ្យគេហៅខ្លួនថា "ព្រះគ្រូ"។
៨រីឯអ្នករាល់គ្នាវិញ កុំបង្គាប់គេឲ្យហៅខ្លួនថា "ព្រះ
គ្រូ" សោះឡើយ ដ្បិតអ្នករាល់គ្នាមាន"ព្រះគ្រូ"តែមួយ
គត់ ហើយអ្នករាល់គ្នាសុទ្ធតែជាបងប្អូននឹងគ្នា។ ៩កុំ
ហៅនរណាម្នាក់នៅលើផែនដីនេះថា "ព្រះបិតា"ឲ្យ
សោះ ដ្បិតអ្នករាល់គ្នាមាន"ព្រះបិតា"តែមួយគត់
ដែលគង់នៅស្ថានបរមសុខ។ ១០កុំឲ្យគេហៅអ្នករាល់
គ្នាថា "មគ្គុទេសក៍"ឡើយ ដ្បិតមានតែព្រះគ្រីស្តមួយ
ព្រះអង្គប៉ុណ្ណោះ ដែលជាមគ្គុទេសក៍របស់អ្នករាល់
គ្នា។ ១១ក្នុងចំណោមអ្នករាល់គ្នា អ្នកណាមានឋានៈធំ
ជាងគេ ត្រូវឲ្យអ្នកនោះបម្រើអ្នករាល់គ្នា។ ១២អ្នកណា
លើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ។ រីឯ
អ្នកដែលបន្ទាបខ្លួន នឹងត្រូវគេលើកតម្កើងវិញ។
១៣នែ៎! ពួកធម្មាចារ្យ* និងពួកផារីស៊ី*ដ៏មានពុត
អើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់
គ្នាបិទទ្វារ មិនឲ្យមនុស្សចូលទៅក្នុងព្រះរាជ្យ*នៃ
ស្ថានបរមសុខ* អ្នករាល់គ្នាមិនត្រឹមតែមិនបានចូល
ខ្លួនឯងប៉ុណ្ណោះទេ គឺថែមទាំងរារាំងអ្នកដែលចង់ចូល
មិនឲ្យគេចូលទៀតផង។
{១៤ ពួកធម្មាចារ្យ និងពួកផារីស៊ីដ៏មានពុត
អើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់
គ្នា [ឆ] បោកយកទ្រព្យសម្បត្តិរបស់ស្ត្រីមេម៉ាយដោយ
ធ្វើឫកជាសូត្រធម៌យ៉ាងយូរ។ ហេតុនេះហើយបានជា
អ្នករាល់គ្នាត្រូវទទួលទោសយ៉ាងធ្ងន់មិនខាន}។
១៥ពួកធម្មាចារ្យនិងពួកផារីស៊ី ដ៏មានពុតអើយ!
អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាធ្វើ
ដំណើរតាមផ្លូវទឹក និងតាមផ្លូវគោកស្វែងរកបញ្ចុះ
បញ្ចូលគេ ឲ្យចូលសាសនារបស់អ្នករាល់គ្នា យ៉ាង
ហោចណាស់ឲ្យបានមនុស្សម្នាក់ដែរ។ លុះគេចូល
សាសនាហើយ អ្នករាល់គ្នាធ្វើឲ្យគេរឹតតែអាក្រក់ជួ
ជាតិ[ព] ជាងអ្នករាល់គ្នាមួយទ្វេជាពីរ។
១៦ពួកអ្នកដឹកនាំកង្វាក់អើយ! អ្នករាល់គ្នាត្រូវ
វេទនាជាពុំខាន ព្រោះអ្នករាល់គ្នានិយាយថា "បើអ្នក
ណាស្បថដោយយកព្រះវិហារ*ធ្វើជាសាក្សី ពាក្យ
សម្បថនោះយកជាការពុំបានទេ។ ផ្ទុយទៅវិញ បើ
ស្បថដោយយកមាសរបស់ព្រះវិហារ ធ្វើជាសាក្សី
ទើបយកជាការបាន"។

១៧មនុស្សលេលាកង្វាក់អើយ! មាសនិងព្រះ
វិហារដែលធ្វើឲ្យមាសទៅជាវត្ថុពិសិដ្ឋ តើមួយណា
សំខាន់ជាង?។ ១៨អ្នករាល់គ្នានិយាយទៀតថា"អ្នក
ណាស្បថដោយយកអាសនៈធ្វើជាសាក្សី ពាក្យ
សម្បថនោះយកជាការពុំបានទេ។ ផ្ទុយទៅវិញ បើ
ស្បថ ដោយយកតង្វាយលើអាសនៈធ្វើជាសាក្សី
ទើបយកជាការបាន"។ ១៩មនុស្សកង្វាក់អើយ!
តង្វាយដែលគេថ្វាយលើអាសនៈ និងអាសនៈដែល
ធ្វើឲ្យតង្វាយទៅជាតង្វាយពិសិដ្ឋ តើមួយណាសំខាន់
ជាង?។ ២០ដូច្នេះអ្នកណាស្បថដោយយកអាសនៈជា
សាក្សី អ្នកនោះមានទាំងអាសនៈ មានទាំងអ្វីៗនៅ
លើអាសនៈជាសាក្សីមែន។ ២១អ្នកណាស្បថដោយ
យកព្រះវិហារជាសាក្សី អ្នកនោះមានទាំងព្រះវិហារ
មានទាំងព្រះជាម្ចាស់ដែលគង់នៅក្នុងព្រះវិហារ ជា
សាក្សីដែរ។ ២២អ្នកណាស្បថដោយយកស្ថានបរម
សុខជាសាក្សី អ្នកនោះមានទាំងបល្ល័ង្ករបស់ព្រះជា
ម្ចាស់មានទាំងព្រះជាម្ចាស់ ដែលគង់នៅលើបល្ល័ង្កជា
សាក្សី។

២៣ពួកធម្មាចារ្យនិងពួកផារីស៊ី ដ៏មានពុតអើយ!
អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាយក
ជីរអង្គាម ជីរនាងវង និងម្អមមួយភាគដប់មកថ្វាយ
ព្រះជាម្ចាស់ ប៉ុន្តែ អ្នករាល់គ្នាលះបង់វិន័យ*សំខាន់ៗ
ចោល មានសេចក្ដីសុចរិត មេត្តាករុណាធម៌ និង
ជំនឿស្មោះត្រង់ជាដើម។ វិន័យទាំងប៉ុន្មានប្រការនេះ
ហើយ ដែលអ្នករាល់គ្នាត្រូវប្រតិបត្តិតាមដោយឥត
លះបង់ចោលប្រការឯទៀតៗ។ ២៤អ្នកដឹកនាំកង្វាក់
អើយ! អ្នករាល់គ្នាត្រងយកមូសចេញពីទឹកផឹក តែអ្នក
រាល់គ្នាលេបដំរីមួយទាំងមូលទៅវិញ!។

២៥ពួកធម្មាចារ្យនិងពួកផារីស៊ី ដ៏មានពុតអើយ!
អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នា
សម្អាតពែងនិងចាន តែខាងក្រៅប៉ុណ្ណោះ ប៉ុន្តែផ្ទៃក
ខាងក្នុងពោរពេញទៅដោយផលដែលកើតមកពីការ
កេងប្រវ័ញ្ច និងការលោភលន់។ ២៦ពួកផារីស៊ីដ៏
កង្វាក់អើយ! ចូរសម្អាតផ្ទៃកខាងក្នុងពែងជាមុនសិន
ទើបអ្វីៗនៅខាងក្រៅបានស្អាតបរិសុទ្ធ*ដែរ។

២៧ពួកធម្មាចារ្យនិងពួកផារីស៊ី ដ៏មានពុតអើយ!
អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នា
ប្រៀបបាននឹងផ្នូរ ដែលគេលាបកំបោរស មើលពី
ក្រៅឃើញហាក់ដូចជាស្អាត តែខាងក្នុងពោរពេញ
ទៅដោយឆ្អឹងសាកសព និងធាតុរលួយសព្វបែបយ៉ា
ង។ ២៨អ្នករាល់គ្នាក៏ដូច្នោះដែរអ្នករាល់គ្នាសម្ដែងឫក
ពារខាងក្រៅ ឲ្យមនុស្សម្នាឃើញថាអ្នករាល់គ្នា
សុចរិតតែចិត្តអ្នករាល់គ្នាពោរពេញដោយគំនិតលាក់
ពុតនិងគំនិតទុច្ចរិតទៅវិញ។

២៩ពួកធម្មាចារ្យនិងពួកផារីស ដ៏មានពុតអើយ!
អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាបាន
សង់ផ្នូរឲ្យពួកព្យាការី ព្រមទាំងតុបតែងផ្នូររបស់
មនុស្សសុចរិត ៣០ដោយពោលថា៖ "ប្រសិនបើយើង
បានរស់នៅជំនាន់បុព្វបុរស* នោះយើងមុខជាមិន
សមគំនិតជាមួយគេ ក្នុងការសម្លាប់ពួកព្យាការី
ឡើយ"។ ៣១អ្នករាល់គ្នាពោលដូច្នេះបានសេចក្ដីថា
អ្នករាល់គ្នាចោទខ្លួនឯងថា ជាពូជពង្សរបស់ពួកអ្នក
ដែលបានសម្លាប់ព្យាការី។ ៣២ដូច្នេះចូរបន្តកិច្ចការ
របស់បុព្វបុរស អ្នករាល់គ្នាឲ្យបានសម្រេចទៅ! ៣៣នែ៎
ពួកពស់ពូជពស់វែកអើយ! ធ្វើម្ដេចឲ្យអ្នករាល់គ្នាគេច
ផុតពីទោសធ្លាក់នរកបាន?។ ៣៤ហេតុនេះខ្ញុំចាត់ព្យា
ការី អ្នកប្រាជ្ញនិងបណ្ឌិតខាងវិន័យឲ្យមករកអ្នករាល់
គ្នា តែអ្នករាល់គ្នានឹងសម្លាប់ពួកគេខ្លះឆ្កាងខ្លះនិង
វាយធ្វើបាបខ្លះក្នុងធម្មសាលា* ព្រមទាំងតាមបៀត
បៀនគេ ពីក្រុងមួយទៅក្រុងមួយផង។ ៣៥ដូច្នេះអ្នក
រាល់គ្នាត្រូវទទួលទោស ព្រោះអ្នករាល់គ្នាបានបង្ហូរ
ឈាមជនសុចរិតចាប់ពីលោកអបិល ជាមនុស្ស
សុចរិត រហូតដល់លោកសាការីជាបុត្ររបស់លោក
បារ៉ាគី ដែលអ្នករាល់គ្នាបានសម្លាប់នៅត្រង់ចន្លោះទី

សក្ការៈ*និងអាសនៈ*។ ៣៦ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នា
បានដឹងថា ទោសទាំងនោះនឹងត្រូវធ្លាក់មកលើ
មនុស្សជំនាន់នេះជាមិនខាន។

## អ្នកក្រុងយេរូសាឡឹមបដិសេធមិនទទួលព្រះយេស៊ូ

(លូកា ១៣.៣៤-៣៥)

៣៧«អ្នកក្រុងយេរូសាឡឹម អ្នកក្រុងយេរូសា
ឡឹមអើយ! អ្នករាល់គ្នាបានសម្លាប់ពួកព្យាការី* និង
យកដុំថ្មគប់សម្លាប់អស់អ្នក ដែលព្រះជាម្ចាស់បាន
ចាត់ឲ្យមករកអ្នករាល់គ្នា។ ច្រើនលើកច្រើនសាមក
ហើយ ដែលខ្ញុំចង់ប្រមូលផ្ដុំអ្នករាល់គ្នា ដូចមេមាន់
ក្រុងកូនវា នៅក្រោមស្លាប តែអ្នករាល់គ្នាពុំព្រម
សោះ។ ៣៨ហេតុនេះផ្ទះរបស់អ្នករាល់គ្នានឹងត្រូវបោះ
បង់ចោល ឲ្យនៅស្ងាត់ជ្រងំ។ ៣៩ខ្ញុំសុំប្រាប់អ្នករាល់
គ្នាថា ពីពេលនេះទៅមុខ អ្នករាល់គ្នានឹងលែងឃើញ
ខ្ញុំទៀតហើយ រហូតដល់ពេលអ្នករាល់គ្នាពោលថា៖

*"សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះអង្គ*
*ដែលយាងមកក្នុងនាមព្រះអម្ចាស់!"*»។

## ព្រះយេស៊ូប្រកាសអំពីការបំផ្លាញព្រះវិហារ*

(ម៉ាកុស ១៣.១-២ លូកា ២១.៥-៦)

២៤ ១ពេលនោះ ព្រះយេស៊ូកំពុងយាងចេញពីព្រះ
វិហារ ពួកសាវ័កចូលមកជិតចង្អុលបង្ហាញវិមានផ្សេ
ងៗ ក្នុងព្រះវិហារថ្វាយព្រះអង្គទត។ ២ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នា
ដឹងច្បាស់ថា អ្វីៗដែលអ្នករាល់គ្នាឃើញនៅពេលនេះ
នឹងត្រូវរលំបាក់បែកអស់ លែងមានថ្មត្រួតពីលើថ្ម
ទៀតហើយ!»។

## ហេតុការណ៍នៅគ្រាចុងក្រោយ

(ម៉ាកុស ១៣.៣-១៣ លូកា ២១.៧-១៩)

៣កាលព្រះយេស៊ូគង់នៅលើភ្នំដើមអូលីវ ពួក
សាវ័ក*នាំគ្នាចូល ទៅគាល់ព្រះអង្គដាច់ឡែកពីគេ
ហើយទូលថា៖ «សូមប្រាប់ឲ្យយើងខ្ញុំដឹងផង ហេតុ
ការណ៍ទាំងនេះនឹងកើតឡើង នៅពេលណា? តើ
មានអ្វីជាសម្គាល់ឲ្យយើងខ្ញុំដឹងថាដល់ពេលព្រះអង្គ
យាងមក និងដល់អវសានកាលនៃពិភពលោក?»។
៤ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេថា៖ «ចូរប្រុង
ប្រយ័ត្ន កុំបណ្ដោយនរណាមកបញ្ឆោតអ្នករាល់គ្នា
ឲ្យវង្វេងបានឡើយ ៥ដ្បិតនឹងមានមនុស្សជាច្រើន
យកឈ្មោះខ្ញុំទៅប្រើដោយពោលថា៖ "ខ្ញុំនេះហើយ
ជាព្រះគ្រិស្ត*"។ គេនឹងនាំមនុស្សជាច្រើនឲ្យវង្វេង។
៦អ្នករាល់គ្នានឹងឮគេនិយាយអំពីសង្គ្រាមនិងឮដំណឹង
ថា មានសង្គ្រាមផ្ទុះឡើងហើយ។ កុំជ្រួលច្របល់
ឡើយ ដ្បិតហេតុការណ៍ទាំងនេះត្រូវតែកើតឡើង តែ
មិនទាន់ដល់អវសានកាលនៃពិភពលោកនៅឡើយ
ទេ។ ៧ប្រជាជាតិមួយនឹងធ្វើសង្គ្រាមតទល់នឹងប្រជា
ជាតិមួយទៀត ប្រទេសមួយតទល់នឹងប្រទេសមួយ
ទៀត។ នៅតាមតំបន់ផ្សេងៗ នឹងមានកើតទុរ្ភិក្សនិង
រញ្ជួយផែនដី។ ៨ប៉ុន្តែហេតុការណ៍ទាំងនេះ ប្រៀប
បានទៅនឹងការឈឺចាប់ដើមដំបូងរបស់ស្ត្រី ដែល
ហៀបនឹងសម្រាលកូន។

៩គេនឹងបញ្ជូនអ្នករាល់គ្នា ទៅធ្វើទុក្ខទោស
ព្រមទាំងឲ្យគេសម្លាប់អ្នករាល់គ្នា ថែមទៀតផង។
ជាតិសាសន៍ទាំងអស់នឹងស្អប់អ្នករាល់គ្នា ព្រោះតែ
នាមខ្ញុំ។ ១០នៅពេលនោះ នឹងមានមនុស្សជាច្រើន
បែកចិត្ត ឃ្លាតចេញពីជំនឿ ក្បត់គ្នាទៅវិញទៅមក
និងស្អប់គ្នាផង។ ១១ព្យាការី*ក្លែងក្លាយជាច្រើននឹង
មកដល់ ហើយបញ្ឆោតមនុស្សជាច្រើនឲ្យវង្វេង។ ១២
អំពើទុច្ចរិតនឹងរីកចម្រើនឡើងជាខ្លាំងបណ្ដាលឲ្យ
សេចក្ដីស្រឡាញ់របស់មនុស្សមួយចំនួនធំ ត្រូវធ្លាក់
ចុះ អន់ថយ។ ១៣ប៉ុន្តែ អ្នកណាស៊ូទ្រាំរហូតដល់ទី
បញ្ចប់ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ។ ១៤គេនឹង

ប្រកាសដំណឹងល្អ* អំពីព្រះរាជ្យ*នេះពាសពេញ
សកលលោកទាំងមូល ទុកជាសក្ខីភាពដល់ជាតិ
សាសន៍ទាំងអស់។ ពេលនោះទើបដល់អវសានកាល
នៃពិភពលោក»។

## គ្រាមានទុក្ខលំបាក

(ម៉ាកុស ១៣.១៤-២៣ លូកា ២១.២០-២៤)

១៥«ពេលណាអ្នករាល់គ្នាឃើញវត្ថុចង្រៃ ដ៏គួរ
ស្អប់ខ្ពើម[យ]តាំងនៅក្នុងទីសក្ការៈ ដូចព្យាការីដានីអែ
ល[រ]បានថ្លែងទុក {សូមឲ្យអ្នកអានយល់ពាក្យនេះ
ចុះ!} ១៦ពេលនោះ អ្នកដែលរស់ក្នុងស្រុកយូដា ត្រូវ
នាំគ្នារត់ទៅជ្រកនៅតាមភ្នំ។ ១៧រីឯអ្នកនៅលើដំបូល
ផ្ទះ មិនត្រូវចុះមកយកអ្វីៗនៅក្នុងផ្ទះឡើយ១៨ហើយ
អ្នកដែលនៅឯចម្ការ ក៏មិនត្រូវវិលទៅផ្ទះយកអាវធំ
របស់ខ្លួនដែរ។ ១៩គ្រានោះ ស្ត្រីមានផ្ទៃពោះនិងស្ត្រី
បំបៅកូន មុខជាត្រូវវេទនាពុំខាន។ ២០ចូរទូលអង្វរ
ព្រះជាម្ចាស់ សូមកុំឲ្យអ្នករាល់គ្នាត្រូវរត់ភៀសខ្លួន
នៅរដូវត្រជាក់ឬនៅថ្ងៃសប្ប័ទ*ឡើយ ២១ដ្បិតពេល
នោះជាពេលមានទុក្ខលំបាកយ៉ាងខ្លាំង តាំងពីដើម
កំណើតពិភពលោក មកទល់សព្វថ្ងៃ ហើយទោះជា
ទៅថ្ងៃមុខទៀត ក៏ពុំដែលមានទុក្ខលំបាកខ្លាំងយ៉ាង
នេះដែរ[ល]។ ២២ប្រសិនបើព្រះជាម្ចាស់មិនបន្ថយចំនួន
ថ្ងៃទាំងនោះទេ មុខជាគ្មាននរណាម្នាក់បានរួចជីវិត
ឡើយ ប៉ុន្តែព្រះអង្គបន្ថយចំនួនថ្ងៃទាំងនោះដោយ
យោគយល់ដល់ពួកអ្នក ដែលព្រះអង្គបានជ្រើសរើ
ស។

២៣ប្រសិនបើមានគេប្រាប់អ្នករាល់គ្នាថា "ព្រះ
គ្រិស្ត*គង់នៅទីនេះឬនៅទីនោះ" កុំជឿគេឡើយ២៤
ដ្បិតនឹងមានមនុស្សក្លែងខ្លួន ធ្វើជាព្រះគ្រិស្ត ព្រម
ទាំងមានព្យាការី*ក្លែងក្លាយ នាំគ្នាសម្ដែងទីសម្គាល់ធំ
អស្ចារ្យ និងឫទ្ធិបាដិហារិយ៍ផ្សេងៗ ដើម្បីបញ្ឆោត
មនុស្សរហូតដល់ទៅនាំពួកអ្នក ដែលព្រះជាម្ចាស់
បានជ្រើសរើស ឲ្យវង្វេងថែមទៀតផង ប្រសិនបើគេ
អាចធ្វើបាន។ ២៥ខ្ញុំនិយាយប្រាប់ឲ្យអ្នករាល់គ្នាដឹងជា
មុនឲ្យហើយ។

២៦បើមានគេប្រាប់អ្នករាល់គ្នាថា "ព្រះអង្គនៅ
វាលរហោស្ថានឯណោះ!" កុំចេញទៅតាមគេឡើយឬ
មួយបើគេថា "ព្រះអង្គនៅក្នុងបន្ទប់ឯណោះ!"ក៏កុំជឿ
ពាក្យគេដែរ ២៧ដ្បិតបុត្រមនុស្ស*នឹងយាងមកប្រៀប
បីដូចជាផ្លេកបន្ទោរ ភ្លឺឆ្វាច ឆូតកាត់ពីទិសខាងកើត
ទៅទិសខាងលិច។ ២៨សាកសពនៅទីណាត្មាតក៏មក
ប្រមូលផ្ដុំគ្នានៅទីនោះដែរ[វ]»។

## បុត្រមនុស្សនឹងយាងមក

(ម៉ាកុស ១៣.២៤-២៧ លូកា ២១.២៥-២៨)

២៩«លុះគ្រាដែលមានទុក្ខវេទនានេះ កន្លងផុត
ទៅ ភ្លាមនោះព្រះអាទិត្យនឹងបាត់រស្មីព្រះច័ន្ទលែង
មានពន្លឺទៀតហើយ។ រីឯផ្កាយទាំងឡាយនឹងធ្លាក់ចុះ
ពីលើមេឃ [ស] អំណាចនានានៅលើមេឃនឹងត្រូវ
កក្រើករំពើក[ហ]។ ៣០ពេលនោះទីសម្គាល់របស់បុត្រ
មនុស្ស*នឹងលេចចេញពីផ្ទៃមេឃមក។ កុលសម្ព័ន្ធ*
ទាំងប៉ុន្មាននៅលើផែនដី នឹងនាំគ្នាយំគក់ទ្រូងឡ គេ
នឹងឃើញបុត្រមនុស្សយាងមកលើពពក* ក្នុងផ្ទៃ
មេឃ[អ]ប្រកបដោយឫទ្ធានុភាព និងសិរីរុងរឿងដ៏អស្ចា
រ្យ។ ៣១ពេលនោះមានសំឡេងត្រែលាន់ឮរំពងឡើង
លោកក៏ចាត់ពួកទេវទូត*របស់លោកឲ្យទៅទិសទាំង
បួន ដើម្បីប្រមូលពួកអ្នកដែលព្រះជាម្ចាស់បានជ្រើស
រើស ចាប់ពីជើងមេឃម្ខាងទៅជើងមេឃម្ខាង»។

## ព្រះបន្ទូលអំពីដើមឧទុម្ពរ

(ម៉ាកុស ១៣.២៨-៣១ លូកា ២១.២៩-៣៣)

៣២«ចូរអ្នករាល់គ្នាយកប្រស្នា* ស្ដីអំពីដើម
ឧទុម្ពរ*ទៅរិះគិតចុះ។ កាលណាមែករបស់វាមាន
ស្លឹកលាស់ខៀវខ្ចី អ្នករាល់គ្នាដឹងថា រដូវប្រាំង[ក]ជិត
មកដល់ហើយ។ ៣៣ដូច្នេះកាលណាអ្នករាល់គ្នា

ឃើញព្រឹត្តការណ៍ទាំងអស់ នោះកើតឡើងត្រូវដឹងថា
បុត្រមនុស្សក៏ជិតមកដល់ហើយដែរ គឺលោកមកជិត
បង្កើយហើយ។ [៣៤]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់
ថា ហេតុការណ៍ទាំងនោះនឹងកើតឡើងក្នុងពេល
ដែលមនុស្សជំនាន់នេះ មានជីវិតនៅឡើយ។ [៣៥]ផ្ទៃ
មេឃនិងផែនដីនឹងរលាយបាត់ទៅ តែពាក្យដែលខ្ញុំ
និយាយមិនរលាយបាត់ទេ»។

## ការត្រៀមខ្លួនរង់ចាំទទួលព្រះគ្រីស្ត

(ម៉ាកុស ១៣.៣២-៣៧ លូកា ១៧.២៦-៣០,៣៤-៣៦)

[៣៦]រីឯថ្ងៃកំណត់ និងពេលវេលាគ្មាននរណាដឹង
ឡើយ ទោះបីទេវទូត*នៅស្ថានបរមសុខ*ឬព្រះបុត្រា
ក៏ពុំជ្រាបដែរ មានតែព្រះបិតាមួយព្រះអង្គប៉ុណ្ណោះ
ដែលជ្រាប។ [៣៧]នៅគ្រាបុត្រមនុស្សយាងមក ក៏ដូច
កាលនៅសម័យលោកណូអេដែរ [៣៨]គឺមុនពេលទឹក
ជំនន់ធំមនុស្សម្នាតែងតែនាំគ្នា ស៊ីផឹករៀបការប្ដី
ប្រពន្ធ រហូតដល់ថ្ងៃដែលលោកណូអេចូលក្នុងទូក
ធំ។ [៣៩]គេមិនបានចាប់អារម្មណ៍អ្វីសោះ ទាល់តែទឹក
ជំនន់ឡើងមកដល់បំផ្លាញគេអស់ទៅ។ នៅគ្រាដែល
បុត្រមនុស្សយាងមក ក៏កើតមានដូច្នោះដែរ។ [៤០]បើ
មានមនុស្សពីរនាក់ ធ្វើការក្នុងចម្ការជាមួយគ្នាព្រះជា
ម្ចាស់នឹងយកម្នាក់ទៅទុកម្នាក់ទៀតឲ្យនៅ។ [៤១]បើ
មានស្ត្រីពីរនាក់កិនស្រូវជាមួយគ្នា ព្រះជាម្ចាស់នឹង
យកម្នាក់ទៅទុកម្នាក់ទៀតឲ្យនៅ។ [៤២]ដូច្នេះចូរប្រុង
ស្មារតីឲ្យមែនទែន ដ្បិតអ្នករាល់គ្នាពុំដឹងថាព្រះ
អម្ចាស់របស់អ្នករាល់គ្នានឹងមកដល់ នៅពេលណា
ឡើយ។ [៤៣]អ្នករាល់គ្នាដឹងហើយថា បើម្ចាស់ផ្ទះដឹង
ចោរចូលមកប្លន់ថ្មើរណា គាត់មុខជាប្រុងស្មារតីពុំ
ខាន មិនបណ្ដោយឲ្យចោរចូលមកប្លន់ផ្ទះគាត់បាន
ឡើយ។ [៤៤]ដូច្នេះអ្នករាល់គ្នាត្រូវត្រៀមខ្លួនជានិច្ច
ដ្បិតបុត្រមនុស្សនឹងមកដល់នៅវេលា ដែលអ្នករាល់
គ្នាពុំបានគិត»។

## ប្រស្នាអំពីអ្នកបម្រើស្មោះត្រង់ និងអ្នកបម្រើមិនស្មោះត្រង់

(លូកា ១២.៤១-៤៨)

[៤៥]«បើអ្នកបម្រើណាមានចិត្តស្មោះត្រង់ ហើយ
ឈ្លាសវៃ ម្ចាស់មុខជាផ្ទុកផ្ដាក់ឲ្យអ្នកបម្រើនោះមើល
ខុសត្រូវលើអ្នកបម្រើឯទៀតៗ ក្នុងការចែកម្ហូប
អាហារឲ្យគេតាមពេលកំណត់ពុំខាន។ [៤៦]ពេលម្ចាស់
ត្រឡប់មកដល់ផ្ទះវិញ ឃើញអ្នកបម្រើកំពុងបំពេញ
កិច្ចការរបស់ខ្លួនដូច្នេះ អ្នកបម្រើនោះប្រាកដជាមាន
សុភមង្គលហើយ។ [៤៧]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹង
ច្បាស់ថា ម្ចាស់មុខជាផ្ទុកផ្ដាក់ឲ្យគាត់មើលខុសត្រូវ
លើទ្រព្យសម្បត្តិទាំងប៉ុន្មានរបស់លោកថែមទៀតផ
ង។ [៤៨]ផ្ទុយទៅវិញ បើអ្នកបម្រើនោះមានចិត្តអាក្រក់
ហើយគិតថា "ម្ចាស់អញក្រមកដល់ណាស់" [៤៩]គាត់
វាយអ្នកបម្រើឯទៀតៗ ព្រមទាំងទៅស៊ីផឹកជាមួយ
អ្នកប្រមឹក។ [៥០]ពេលម្ចាស់វិលត្រឡប់មកផ្ទះវិញនៅ
ថ្ងៃដែលអ្នកបម្រើនោះមិនបានរង់ចាំ ឬនៅពេលដែល
គាត់មិនដឹង [៥១]លោកនឹងធ្វើទោសគាត់ជាទម្ងន់
ហើយឲ្យគាត់ទទួលទោសរួមជាមួយពួកមានពុតត្បុត
ដែរ គឺឲ្យទៅនៅកន្លែងយំសោកខឹងសង្កៀតធ្មេញ»។

## ប្រស្នាអំពីស្ត្រីក្រមុំដប់នាក់

២៥ [១]«ព្រះរាជ្យ នៃស្ថានបរមសុខ* ប្រៀបបានទៅ
នឹងស្ត្រីក្រមុំ ដប់នាក់ ដែលយកចង្កៀងចេញទៅ
ទទួលស្វាមី។ [២]ក្នុងចំណោមពួកនាង មានប្រាំនាក់ជា
ស្ត្រីឥតគំនិតប្រាំនាក់ទៀតជាស្ត្រីឈ្លាសវៃ។ [៣]ស្ត្រី
ឥតគំនិតយកចង្កៀងទៅ តែមិនយកប្រេងទៅបង្ការ
ជាមួយទេ។ [៤]រីឯស្ត្រីឈ្លាសវៃវិញ នាងបានយក
ចង្កៀងទៅមានទាំងប្រេងបង្ការផង។ [៥]ដោយស្វាមីក្រ
មកដល់ នាងទាំងដប់នាក់ងោកងុយពេក ក៏ដេកលក់
ទាំងអស់គ្នាទៅ។ [៦]លុះដល់ពាក់កណ្ដាលអធ្រាត្រ
មានគេស្រែកឡើងថា "ស្វាមីមកដល់ហើយ! ចូរនាំ

គ្នារត់ទៅទទួលលោក!"។ ៧ស្ត្រីក្រមុំទាំងនោះក៏
ក្រោកឡើងរៀបចំអុជចង្កៀង។ ៨ស្ត្រីឥតគំនិត
និយាយទៅកាន់ស្ត្រីឈ្លាសវៃថា "សុំចែកប្រេងឲ្យ
យើងខ្លះផង ព្រោះចង្កៀងយើងចង់រលត់អស់ហើយ"
។ ៩ស្ត្រីឈ្លាសវៃឆ្លើយទៅវិញថា"ទេមិនបានទេ! បើ
យើងចែកឲ្យពួកនាង ក្រែងមិនគ្រាន់សម្រាប់យើង
ផង សម្រាប់ពួកនាងផង។ ចូរនាំគ្នាទៅទិញនៅផ្ទះ
លក់ប្រេងទៅ!"។

១០នៅពេលដែលស្ត្រីឥតគំនិតទាំងប្រាំ ចេញ
ទៅរកទិញប្រេងផុតទៅ ស្រាប់តែស្វាមីមកដល់ឯស្ត្រី
ប្រាំនាក់ដែលត្រៀមខ្លួនជាស្រេច នាំគ្នាចូលទៅក្នុង
រោងការជាមួយលោក ហើយគេបិទទ្វារជិត។ ១១
ក្រោយមក ស្ត្រីប្រាំនាក់ទៀតមកដល់ស្រែកហៅថា៖
"លោកម្ចាស់ លោកម្ចាស់! សូមបើកទ្វារឲ្យយើងខ្ញុំ
ចូលផង!"។ ១២ស្វាមីឆ្លើយទៅវិញថា៖ "ខ្ញុំសុំប្រាប់ឲ្យ
នាងទាំងអស់គ្នាដឹងច្បាស់ថា ខ្ញុំមិនស្គាល់ពួកនាង
ទេ!"។

១៣ដូច្នេះ ចូរអ្នករាល់គ្នាប្រុងស្មារតី ដ្បិតអ្នក
រាល់គ្នាពុំដឹងថា បុត្រមនុស្ស*នឹងមកដល់ថ្ងៃណា
ពេលណាឡើយ»។

## ប្រស្នាស្ដីអំពីប្រាក់ណែន

(លូកា ១៩.១១-២៧)

១៤«ព្រះរាជ្យ*នៃស្ថានបរមសុខ* ប្រៀបបាន
នឹងបុរសម្នាក់ ដែលហៀបចេញដំណើរទៅស្រុកឆ្ងា
យ។ គាត់ហៅពួកអ្នកបម្រើ មកប្រគល់ទ្រព្យសម្បត្តិ
ឲ្យ។ ១៥គាត់ប្រគល់ប្រាក់ឲ្យអ្នកបម្រើម្នាក់ៗ តាម
សមត្ថភាពរៀងៗខ្លួន គឺឲ្យប្រាំណែន[ខ]ទៅអ្នកទីមួយ
ពីរណែនទៅអ្នកទីពីរ និងមួយណែនទៅអ្នកទីបី រួច
គាត់ចេញដំណើរទៅ។ ១៦អ្នកបម្រើដែលបានទទួល
ប្រាក់ប្រាំណែន យកប្រាក់ចេញទៅរកស៊ីភ្លាម ហើយ
ចំណេញបានប្រាំណែនទៀត។ ១៧អ្នកទីពីរក៏ដូច្នោះ
ដែរ គាត់យកប្រាក់ពីរណែននោះទៅរកស៊ី ចំណេញ
បានពីរណែនទៀត។ ១៨រីឯអ្នកដែលទទួលប្រាក់មួយ
ណែន បានចេញទៅជីកដីកប់ប្រាក់ម្ចាស់របស់ខ្លួនទុ
ក។

១៩លុះយូរក្រោយមក ម្ចាស់វិលត្រឡប់មកវិញ
ហើយគិតបញ្ជីជាមួយអ្នកទាំងបីនោះ។ ២០អ្នកទទួល
ប្រាក់ប្រាំណែន យកប្រាក់ដែលចំណេញបានប្រាំ
ណែនចូលមកជូនម្ចាស់ដោយពោលថា៖ "លោក
ម្ចាស់! លោកបានប្រគល់ប្រាក់ប្រាំណែនឲ្យខ្ញុំប្របាទ
ឥឡូវនេះ ខ្ញុំប្របាទចំណេញបានប្រាំណែនទៀត"។
២១ម្ចាស់ក៏ពោលទៅគាត់ថា៖ "ល្អហើយ! អ្នកបម្រើដ៏
ប្រសើរមានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់
នឹងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឲ្យមើលខុស
ត្រូវលើកិច្ចការធំៗ។ ចូរអ្នកចូលមកសប្បាយរួម
ជាមួយនឹងខ្ញុំចុះ"។ ២២អ្នកទទួលប្រាក់ពីរណែនក៏
យកប្រាក់ ដែលចំណេញបានពីរណែនទៀតនោះ
ចូលមកដែរ ហើយជម្រាបថា៖ "លោកម្ចាស់! លោក
បានប្រគល់ប្រាក់ពីរណែនឲ្យខ្ញុំប្របាទឥឡូវនេះ ខ្ញុំ
ប្របាទចំណេញបានពីរណែនទៀត"។២៣ម្ចាស់ក៏
ពោលទៅគាត់ថា៖ "ល្អហើយ!អ្នកបម្រើដ៏ប្រសើរ
មានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់នឹងកិច្ច
ការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឲ្យមើលខុសត្រូវលើ
កិច្ចការធំៗ។ ចូរអ្នកចូលមកសប្បាយ រួមជាមួយនឹង
ខ្ញុំចុះ"។ ២៤បន្ទាប់មក អ្នកដែលបានទទួលប្រាក់មួយ
ណែនក៏ចូលមក ហើយជម្រាបថា៖ "លោកម្ចាស់! ខ្ញុំ
ប្របាទដឹងថាលោកជាមនុស្សតឹងតែងណាស់។
លោកតែងច្រូតយកផលពីស្រែ ដែលលោកមិនបាន
សាបព្រោះ ហើយប្រមូលយកផលពីដំណាំ ដែល
លោកមិនបានដាំ។២៥ខ្ញុំប្របាទបានយកប្រាក់ ដែល
លោកប្រគល់ឲ្យទៅជីកដីកប់ ព្រោះខ្ញុំប្របាទភ័យ
ខ្លាចពេក។ ឥឡូវនេះ សូមលោកម្ចាស់យកប្រាក់
របស់លោកវិញចុះ"។ ២៦ម្ចាស់ក៏ពោលទៅអ្នកនោះ
ថា៖ "នែ៎អ្នកបម្រើអាក្រក់ខ្ជិលច្រអូសអើយ! អ្នកដឹង

ស្រាប់ហើយថា ខ្ញុំតែងច្រូតយកផលពីស្រែដែលខ្ញុំ
មិនបានសាបព្រោះ និងប្រមូលផលពីដំណាំ ដែលខ្ញុំ
មិនបានដាំ។ ២៧គួរតែអ្នកយកប្រាក់ខ្ញុំទៅចងការ
កាលណាខ្ញុំត្រឡប់មកវិញ ខ្ញុំនឹងទទួលប្រាក់ទាំង
ដើម ទាំងការ!។ ២៨ចូរយកប្រាក់ពីអ្នកនេះប្រគល់ឲ្យ
អ្នកដែលមានដប់ណែននោះទៅ ២៩ដ្បិតអ្នកណាមាន
ហើយអ្នកនោះនឹងទទួលបរិបូណ៌ ហូរហៀរ ថែមទៀ
ត។ រីឯអ្នកដែលគ្មានវិញ គេនឹងដកហូតនូវអ្វីៗដែល
អ្នកនោះមានផង។ ៣០ចំណែកឯអ្នកបម្រើឥតបានការ
នេះ ចូរយកគាត់ទៅចោលនៅទីងងឹតខាងក្រៅជា
កន្លែងយំសោក ខឹងសង្កៀតធ្មេញនោះទៅ!»។

## ការកាត់ទោសនៅគ្រាចុងក្រោយបង្អស់

៣១«នៅពេលបុត្រមនុស្សយាងមក ជាមួយពួក
ទេវទូត*ប្រកបដោយសិរីរុងរឿង លោកនឹងគង់នៅ
លើបល្ល័ង្កដ៏រុងរឿង។ ៣២ពេលនោះមនុស្សគ្រប់ជាតិ
សាសន៍នឹងមកផ្ដុំគ្នានៅមុខលោក លោកនឹងញែកគេ
ចេញពីគ្នា ដូចអ្នកគង្វាលញែកចៀមចេញពីពពែ ៣៣
គឺឲ្យចៀមនៅខាងស្ដាំ ពពែនៅខាងឆ្វេង។ ៣៤ពេល
នោះ ព្រះមហាក្សត្រនឹងមានព្រះបន្ទូលទៅកាន់អស់
អ្នកនៅខាងស្ដាំព្រះអង្គថា "អស់អ្នកដែលព្រះបិតាខ្ញុំ
បានប្រទានពរអើយ! ចូរនាំគ្នាមកទទួលព្រះរាជ្យ
ដែលទ្រង់បានរៀបទុកឲ្យអ្នករាល់គ្នាតាំងពីកំណើត
ពិភពលោកមក ៣៥ដ្បិតកាលយើងឃ្លាន អ្នករាល់គ្នា
បានឲ្យអាហារយើងបរិភោគ កាលយើងស្រេកអ្នក
រាល់គ្នាបានឲ្យទឹកយើងពិសា កាលយើងជាជន
បរទេស អ្នករាល់គ្នាបានទទួលយើង ឲ្យស្នាក់
អាស្រ័យ ៣៦កាលយើងគ្មានសម្លៀកបំពាក់ អ្នករាល់
គ្នាបានយកសម្លៀកបំពាក់មកឲ្យយើង កាលយើង
មានជំងឺអ្នករាល់គ្នាបានមកសួរសុខទុក្ខយើង ហើយ
កាលយើងជាប់ឃុំឃាំង អ្នករាល់គ្នាក៏បានមកសួរ
យើងដែរ"។ ៣៧ពួកអ្នកសុចរិតទូលព្រះអង្គវិញថា៖
"បពិត្រព្រះអម្ចាស់! តើយើងខ្ញុំដែលបានឃើញព្រះ
អង្គឃ្លានហើយយកម្ហូបអាហារមកថ្វាយព្រះអង្គ
សោយ ឬឃើញព្រះអង្គស្រេកហើយយកទឹកមក
ថ្វាយព្រះអង្គសោយពីអង្កាល់?។ ៣៨តើយើងខ្ញុំដែល
បានឃើញព្រះអង្គជាជនបរទេស ហើយទទួលព្រះ
អង្គឲ្យស្នាក់អាស្រ័យ ឬឃើញព្រះអង្គគ្មានសម្លៀកបំ
ពាក់ ហើយយកសម្លៀកបំពាក់មកថ្វាយព្រះអង្គពី
អង្កាល់?។ ៣៩តើយើងខ្ញុំដែលបានឃើញព្រះអង្គ
ប្រឈួន ឬជាប់ឃុំឃាំង ហើយមកសួរសុខទុក្ខព្រះ
អង្គពីអង្កាល់?"។ ៤០ព្រះមហាក្សត្រនឹងមានព្រះ
បន្ទូលតបទៅគេថា "យើងសុំប្រាប់ឲ្យអ្នករាល់គ្នាដឹង
ច្បាស់ថា គ្រប់ពេលដែលអ្នករាល់គ្នាប្រព្រឹត្តអំពើទាំង
នោះ ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ដែលជា
បងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏ដូចជាបាន
ប្រព្រឹត្តចំពោះយើងដែរ"។

៤១បន្ទាប់មក ព្រះអង្គនឹងមានព្រះបន្ទូលទៅពួក
អ្នកនៅខាងឆ្វេងថា៖ "ពួកត្រូវបណ្ដាសាអើយ! ចូរ
ថយចេញឲ្យឆ្ងាយពីយើង ហើយធ្លាក់ទៅក្នុងភ្លើង
ដែលឆេះអស់កល្បជានិច្ច ជាភ្លើងបម្រុងទុកសម្រាប់
ផ្ដន្ទាទោសមារ*សាតាំង និងបរិវាររបស់វានោះទៅ!៤២
ដ្បិតកាលយើងឃ្លាន អ្នករាល់គ្នាពុំបានឲ្យម្ហូបអាហារ
យើងបរិភោគទេ កាលយើងស្រេកអ្នករាល់គ្នាក៏ពុំ
បានឲ្យទឹកយើងពិសាដែរ ៤៣កាលយើងជាជន
បរទេស អ្នករាល់គ្នាពុំបានទទួលយើងឲ្យស្នាក់
អាស្រ័យឡើយ កាលយើងគ្មានសម្លៀកបំពាក់អ្នក
រាល់គ្នាក៏ពុំបានយកសម្លៀកបំពាក់ មកឲ្យយើងដែរ
កាលយើងមានជំងឺ និងជាប់ឃុំឃាំង អ្នករាល់គ្នាពុំ
បានមកសួរសុខទុក្ខយើងទាល់តែសោះ"។ ៤៤ពួក
នោះនាំគ្នាទូលព្រះអង្គថា "បពិត្រព្រះអម្ចាស់! តើ
យើងខ្ញុំមានដែលបានឃើញព្រះអង្គឃ្លាន ឃើញព្រះ
អង្គស្រេក ឃើញព្រះអង្គជាជនបរទេស ឃើញព្រះ
អង្គគ្មានសម្លៀកបំពាក់ ឃើញព្រះអង្គប្រឈួនឬជាប់
ឃុំឃាំង ហើយយើងខ្ញុំមិនដែលជួយព្រះអង្គសោះពី

អង្កាល់?"។ ៤៥ព្រះអង្គមានព្រះបន្ទូលទៅគេថា "
យើងសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា គ្រប់ពេល
អ្នករាល់គ្នាមិនបានប្រព្រឹត្តអំពើទាំងនោះចំពោះអ្នក
តូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់យើង
នេះ អ្នករាល់គ្នាក៏ដូចជាមិនបានប្រព្រឹត្តចំពោះយើង
ដែរ"។ ៤៦អ្នកទាំងនេះនឹងត្រូវទទួលទោសអស់កល្ប
ជានិច្ច រីឯអ្នកសុចរិតវិញនឹងទទួលជីវិតអស់កល្បជា
និច្ច»។

## ការឃុបឃិតចាប់ព្រះយេស៊ូ

(ម៉ាកុស ១៤.១-២ លូកា ២២.១-២ យ៉ូហាន ១១.៤៥-៥៣)

២៦ ១កាល ព្រះយេស៊ូមានព្រះបន្ទូលទាំងនេះចប់
សព្វគ្រប់ហើយ ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួក
សាវ័កថា៖ ២«អ្នករាល់គ្នាដឹងហើយថា ពីរថ្ងៃទៀត
ដល់បុណ្យចម្លង*គេនឹងចាប់បុត្រមនុស្ស*បញ្ជូនទៅ
ឆ្កាង»។

៣ពេលនោះ ពួកនាយកបូជាចារ្យ*និងពួកព្រឹទ្ធា
ចារ្យ*របស់ប្រជាជនជួបជុំគ្នា នៅក្នុងដំណាក់របស់
លោកមហាបូជាចារ្យ ឈ្មោះកៃផាស ៤ហើយបាន
សម្រេចចិត្តជាមួយគ្នា រកកលល្បិចចាប់ព្រះយេស៊ូ
យកទៅធ្វើគុត។ ៥ប៉ុន្តែ គេនិយាយគ្នាថា៖ «កុំចាប់
ក្នុងពេលបុណ្យឡើយ ក្រែងកើតចលាចលក្នុង
ចំណោមប្រជាជន»។

## ស្ត្រីម្នាក់ចាក់ប្រេងលើសិរសាព្រះយេស៊ូ

(ម៉ាកុស ១៤.៣-៩ យ៉ូហាន ១២.១-៨)

៦ព្រះយេស៊ូគង់នៅភូមិបេថានី ក្នុងផ្ទះបុរសម្នាក់
ឈ្មោះស៊ីម៉ូនជាមនុស្សឃ្លង់។ ៧មានស្ត្រីម្នាក់ចូលមក
រកព្រះអង្គ ទាំងកាន់ដបថ្មកែវផង។ នៅក្នុងដបនោះ
មានប្រេងក្រអូបដ៏មានតម្លៃលើសលប់។ ពេលព្រះ
យេស៊ូកំពុងសោយព្រះស្ងោយ នាងយកប្រេងក្រអូប
នោះចាក់លើព្រះសិរសាព្រះអង្គ។ ៨ពួកសាវ័ក*
ឃើញដូច្នេះទាស់ចិត្តជាខ្លាំង ហើយពោលថា៖ «
ម្ដេចក៏ខ្ជះខ្ជាយអ៊ីចឹង! ៩បើយកប្រេងក្រអូបនេះទៅ
លក់ មុខជាបានប្រាក់ច្រើនសម្រាប់ចែកទានដល់ជន
ក្រីក្រវិញ!»។ ១០ព្រះយេស៊ូជ្រាបគំនិតរបស់គេ ទ្រង់
មានព្រះបន្ទូលថា៖ «ហេតុអ្វីបានជារករឿងនាង
ដូច្នេះ! នាងបានធ្វើអំពើដ៏ល្អចំពោះខ្ញុំ។ ១១អ្នករាល់គ្នា
មានជនក្រីក្រនៅជាមួយរហូត រីឯខ្ញុំវិញ ខ្ញុំមិននៅ
ជាមួយអ្នករាល់គ្នារហូតទេ។ ១២នាងបានចាក់ប្រេង
លាបរូបកាយខ្ញុំដូច្នេះ ដើម្បីធ្វើពិធីបញ្ចុះសពខ្ញុំទុកជា
មុន។ ១៣ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា គ្រប់ទី
កន្លែងក្នុងពិភពលោកទាំងមូលកាលណាគេប្រកាស
ដំណឹងល្អ*នេះ គេក៏នឹងតំណាលអំពីកិច្ចការដែល
នាងបានធ្វើនេះដែរ ដើម្បីរំលឹកអំពីនាង»។

## យូដាសអ៊ីស្ការីយ៉ុតក្បត់ព្រះយេស៊ូ

(ម៉ាកុស ១៤.១០-១១ លូកា ២២.៣-៦)

១៤ពេលនោះ សាវ័ក*ម្នាក់ក្នុងក្រុមសាវ័កទាំង
ដប់ពីរ ឈ្មោះយូដាសអ៊ីស្ការីយ៉ុតបានទៅជួបក្រុម
នាយកបូជាចារ្យ* ១៥ជម្រាបថា៖ «បើខ្ញុំប្រគល់លោក
យេស៊ូជូនអស់លោក តើអស់លោកឲ្យអ្វីខ្ញុំ?»។ ពួក
នាយកបូជាចារ្យក៏រាប់ប្រាក់ ឲ្យគាត់សាមសិបស្លឹង[៣០]។
១៦ចាប់ពីពេលនោះមក យូដាសរកឱកាសល្អ ដើម្បី
នាំគេទៅចាប់ព្រះយេស៊ូ។

## ព្រះយេស៊ូធ្វើពិធីបុណ្យចម្លងជាមួយពួកសាវ័ក

(ម៉ាកុស ១៤.១២-២១ លូកា ២២.៧-១៤, ២១-២៣
យ៉ូហាន ១៣.២១-៣០)

១៧នៅថ្ងៃដំបូង នៃពិធីបុណ្យនំបុ័ងឥតមេ* សាវ័
ក*នាំគ្នាមកគាល់ព្រះយេស៊ូទូលថា៖ «តើព្រះគ្រូចង់
ឲ្យយើងខ្ញុំរៀបចំជប់លៀងជូន ក្នុងឱកាសបុណ្យ
ចម្លង* នៅកន្លែងណា?»។ ១៨ព្រះអង្គមានព្រះបន្ទូល
ថា៖ «ចូរនាំគ្នាទៅផ្ទះបុរសម្នាក់នៅទីក្រុងប្រាប់គាត់

ថា៖"លោកគ្រូមានប្រសាសន៍ថា ពេលកំណត់*របស់ខ្ញុំជិតមកដល់ហើយ ខ្ញុំនឹងធ្វើពិធីបុណ្យចម្លងជាមួយសិស្សខ្ញុំ នៅក្នុងផ្ទះអ្នក"»។ ១៩សាវ័កនាំគ្នាធ្វើតាមដូចព្រះយេស៊ូបង្គាប់ ហើយរៀបចំម្ហូបអាហារសម្រាប់បុណ្យចម្លង។

២០លុះដល់ល្ងាច ព្រះអង្គរួមតុជាមួយសាវ័កទាំងដប់ពីររូប។ ២១នៅពេលបរិភោគ ព្រះអង្គមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ក្នុងចំណោមអ្នករាល់គ្នា មានម្នាក់នឹងនាំគេមកចាប់ខ្ញុំ»។ ២២ពួកសាវ័កព្រួយចិត្តក្រៃលែង ម្នាក់ៗទូលសួរព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! តើទូលបង្គំឬ?»។ ២៣ព្រះអង្គមានព្រះបន្ទូលទៅគេវិញថា៖ «អ្នកណាជ្រលក់នំប៉័ងក្នុងចានជាមួយខ្ញុំ គឺអ្នកនោះហើយដែលនាំគេមកចាប់ខ្ញុំ[យ]។ ២៤បុត្រមនុស្ស*ត្រូវតែស្លាប់ដូចមានចែងទុកក្នុងគម្ពីរ អំពីលោកស្រាប់។ ប៉ុន្តែ អ្នកដែលនាំគេមកចាប់បុត្រមនុស្ស នឹងត្រូវវេទនាជាមិនខាន។ ចំពោះអ្នកនោះបើមិនបានកើតមកទេ ទើបប្រសើរជាង!»។ ២៥យូដាសជាអ្នកក្បត់ព្រះអង្គទូលសួរថា៖ «ព្រះគ្រូ! តើខ្ញុំឬ?»។ ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកនិយាយដូច្នេះ ត្រូវហើយ!»។

## ពិធីជប់លៀងចុងក្រោយបំផុត

(ម៉ាកុស ១៤.២២-២៦ លូកា ២២.១៥-២០ ១កូរិនថូស ១១.២៣-២៥)

២៦នៅពេលកំពុងបរិភោគ ព្រះយេស៊ូយកនំប៉័ងមកកាន់ ព្រះអង្គសរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានឲ្យពួកសាវ័ក* ដោយមានព្រះបន្ទូលថា៖ «នេះជារូបកាយខ្ញុំ សុំយកពិសាចុះ»។ ២៧បន្ទាប់មកព្រះអង្គយកពែងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទានឲ្យពួកសាវ័ក ទាំងមានព្រះបន្ទូលថា៖ «សុំយកពិសាទាំងអស់គ្នាចុះ ២៨នេះជាលោហិតរបស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រី*ដែលត្រូវបង្ហូរ ដើម្បីលើកលែងទោសមនុស្សទាំងអស់ ឲ្យរួចពីបាប។ ២៩ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អំណើះតទៅខ្ញុំនឹងមិនពិសាស្រាទំពាំងបាយជូរទៀតឡើយ រហូតដល់ថ្ងៃដែលខ្ញុំនឹងពិសាស្រាទំពាំងបាយជូរថ្មីជាមួយអ្នករាល់គ្នា នៅក្នុងព្រះរាជ្យ*នៃព្រះបិតាខ្ញុំ»។

៣០ក្រោយពី បានច្រៀងទំនុកតម្កើង* រួចហើយ ព្រះយេស៊ូយាងឆ្ពោះទៅភ្នំដើមអូលីវ ជាមួយពួកសាវ័ក។

## ព្រះយេស៊ូមានព្រះបន្ទូលអំពីលោកសិលាបដិសេធមិនទទួលស្គាល់ព្រះអង្គ

(ម៉ាកុស ១៤.២៧-៣១ លូកា ២២.៣១-៣៤ យ៉ូហាន ១៣.៣៦-៣៨)

៣១ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «យប់នេះ អ្នកទាំងអស់គ្នានឹងបោះបង់ខ្ញុំចោល[ង] ដ្បិតមានចែងទុកមកថា៖ "យើងនឹងវាយសម្លាប់អ្នកគង្វាល ហើយចៀមនៅក្នុងហ្វូងនឹងត្រូវខ្ចាត់ខ្ចាយ"[ច]។ ៣២ប៉ុន្តែ ក្រោយពេលខ្ញុំមានជីវិតរស់ឡើងវិញ ខ្ញុំនឹងទៅស្រុកកាលីឡេមុនអ្នករាល់គ្នា»។ ៣៣លោកសិលាទូលព្រះអង្គថា៖ «ទោះបីអ្នកឯទៀតបោះបង់ចោលព្រះអង្គទាំងអស់គ្នាក៏ដោយ ក៏ទូលបង្គំមិនសុខចិត្តបោះបង់ចោលព្រះអង្គ ជាដាច់ខាត!»។ ៣៤ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងច្បាស់ថា នៅយប់នេះឯងមុនមាន់រងាវ អ្នកនឹងបដិសេធបីដងថា មិនស្គាល់ខ្ញុំ»។ ៣៥លោកសិលាទូលព្រះអង្គថា៖ «ទោះបីទូលបង្គំត្រូវស្លាប់ជាមួយព្រះអង្គក៏ដោយ ក៏ទូលបង្គំមិនបដិសេធថា មិនស្គាល់ព្រះអង្គជាដាច់ខាត»។ សាវ័កឯទៀតៗក៏ទូលព្រះអង្គដូចលោកសិលាដែរ។

## ព្រះយេស៊ូអធិស្ឋាននៅក្នុងសួនគេតសេម៉ានី

(ម៉ាកុស ១៤.៣២-៤២ លូកា ២២.៣៩-៤៦)

៣៦ពេលនោះ ព្រះយេស៊ូយាងទៅជាមួយពួក
សាវ័ក*ដល់កន្លែងមួយឈ្មោះគេតសេម៉ានី ព្រះអង្គ
មានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នាអង្គុយនៅទី
នេះសិន ចាំខ្ញុំទៅអធិស្ឋាន*នៅត្រង់កន្លែងនោះ»។
៣៧ព្រះអង្គនាំលោកសិលា និងកូនរបស់លោកសេបេ
ដេទាំងពីរនាក់ ទៅជាមួយ។ ពេលនោះ ព្រះអង្គចាប់
ផ្ដើមព្រួយព្រះហឫទ័យ ហើយចុកចាប់អន្ទះសាពន់
ប្រមាណ ៣៨ទ្រង់មានព្រះបន្ទូលទៅកាន់អ្នកទាំងបីថា
៖ «ខ្ញុំព្រួយចិត្តយ៉ាងខ្លាំងស្ទើរតែស្លាប់ អ្នករាល់គ្នានៅ
ទីនេះសិនហើយ ចូរប្រុងស្មារតី*ជាមួយខ្ញុំ»។ ៣៩ព្រះ
អង្គយាងទៅមុខបន្តិច ក្រាបព្រះភក្ត្រដល់ដីទូលអង្វរ
ថា៖«ឱព្រះបិតាអើយ! ប្រសិនបើបាន សូមឲ្យពែង
នៃទុក្ខលំបាក*នេះ ចេញឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែ
សូមកុំធ្វើតាមបំណងទូលបង្គំឡើយ គឺសូមឲ្យបាន
សម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ»។ ៤០
ព្រះអង្គយាងមករកពួកសាវ័ក ឃើញគេកំពុងតែដេក
លក់ព្រះអង្គមានព្រះបន្ទូលទៅលោកសិលាថា៖ «
អ្នករាល់គ្នាមិនស៊ូទ្រាំប្រុងស្មារតីជាមួយខ្ញុំ សូម្បីតែ
មួយម៉ោងក៏មិនបានដែរឬ!»។ ៤១ចូរប្រុងស្មារតី
ហើយអធិស្ឋាន*កុំឲ្យចាញ់ការល្បួងឡើយ។ វិញ្ញាណ
របស់មនុស្សប្រុងប្រៀបជាស្រេចមែន តែខ្លួនគេនៅ
ខ្សោយទេ»។
៤២ព្រះអង្គយាងចេញទៅម្ដងទៀត ជាលើកទី
ពីរ ហើយទូលអង្វរថា៖ «ឱព្រះបិតាអើយ ប្រសិនបើ
ទូលបង្គំត្រូវតែទទួលពែងនៃទុក្ខលំបាកនេះ ចៀសពុំ
បានទេនោះ សូមឲ្យបានសម្រេចតាមព្រះហឫទ័យ
របស់ព្រះអង្គចុះ!»។
៤៣ព្រះយេស៊ូវិលត្រឡប់ ទៅរកពួកសាវ័កម្ដង
ទៀត ឃើញគេដេកលក់ ដ្បិតគេងងុយពេក បើក
ភ្នែកពុំរួចសោះ។ ៤៤ព្រះអង្គក៏យាងចាកចេញពីគេ
ទៅអធិស្ឋាន*ជាលើកទីបី ហើយទូលអង្វរដោយ
ពាក្យដដែល។ ៤៥បន្ទាប់មកព្រះអង្គវិលមករកសាវ័ក
វិញមានព្រះបន្ទូលទៅគេថា៖ «អ្នករាល់គ្នានៅតែ
ដេកលក់ អ្នករាល់គ្នាសម្រាកដល់អង្កាល់ទៀត?
ឥឡូវនេះ ជិតដល់ពេលកំណត់ដែលបុត្រមនុស្សត្រូវ
គេបញ្ជូន ទៅក្នុងកណ្ដាប់ដៃរបស់មនុស្សបាបហើ
យ។ ៤៦ចូរក្រោកឡើង! យើងនាំគ្នាទៅ ដ្បិតអ្នកដែល
នាំគេមកចាប់ខ្ញុំមកជិតដល់ហើយ!»។

## គេចាប់ព្រះយេស៊ូ

(មក.១៤.៤៣-៥០ លក.២២.៤៧-៥៣ យហ.១៨.៣-១១)

៤៧ព្រះអង្គកំពុងតែ មានព្រះបន្ទូលនៅឡើយ
ស្រាប់តែយូដាសជាសាវ័ក*ម្នាក់ ក្នុងចំណោមសាវ័ក
ទាំងដប់ពីរមកដល់ ទាំងមានបណ្ដាជនជាច្រើនកាន់
ដាវ កាន់ដំបងមកជាមួយផង។ ពួកនាយកបូជាចារ្យ*
និងពួកព្រឹទ្ធាចារ្យ*របស់ប្រជាជនបានចាត់អ្នកទាំង
នោះឲ្យមក។ ៤៨យូដាសដែលនាំគេមកចាប់ព្រះ
យេស៊ូ បានសន្មតជាមួយគេនូវសញ្ញាមួយថា៖ «ខ្ញុំ
ថើបអ្នកណា គឺអ្នកនោះហើយ សុំចាប់គាត់ទៅ!»។
៤៩កាលយូដាសមកដល់ភ្លាមគាត់ដើរតម្រង់មករក
ព្រះយេស៊ូទូលថា៖ «ជម្រាបសួរព្រះគ្រូ!» រួចថើប
ព្រះអង្គ។ ៥០ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖
«សំឡាញ់អើយ អ្នកមកនេះចង់ធ្វើអ្វី ធ្វើទៅចុះ!»។
ពេលនោះ បណ្ដាជនក៏នាំគ្នាចូលមកចាប់ព្រះអង្គ។
៥១មានម្នាក់ក្នុងចំណោមពួកអ្នកដែលនៅជាមួយព្រះ
យេស៊ូ បានហូតដាវកាប់អ្នកបម្រើរបស់លោកមហា
បូជាចារ្យ* ដាច់ស្លឹកត្រចៀក។ ៥២ព្រះយេស៊ូមានព្រះ
បន្ទូលទៅអ្នកនោះថា៖ «ស៊កដាវអ្នកទៅក្នុងស្រោម
វិញទៅ ដ្បិតអស់អ្នកដែលប្រើដាវនឹងត្រូវស្លាប់
ដោយមុខដាវជាមិនខាន។ ៥៣អ្នកស្មានថា ខ្ញុំមិនអាច
អង្វរករព្រះបិតាខ្ញុំឲ្យចាត់ទេវទូតជាងដប់ពីរកងពល
មកជួយខ្ញុំបានភ្លាមៗទេឬ? ៥៤តែបើធ្វើដូច្នោះធ្វើម្ដេច
នឹងបានស្របតាមសេចក្ដីដែលមានចែងទុកក្នុងគម្ពីរ
អំពីហេតុការណ៍ដែលត្រូវតែកើតឡើងយ៉ាងនេះ!»។

៥៥ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់
មហាជនថា៖ «ខ្ញុំជាចោរព្រៃឬ បានជាអស់លោក
កាន់ដាវ កាន់ដំបងមកចាប់ខ្ញុំដូច្នេះ? ខ្ញុំតែងអង្គុយ
បង្រៀននៅក្នុងព្រះវិហារ* ជារៀងរាល់ថ្ងៃ តែអស់
លោកពុំបានចាប់ខ្ញុំទេ»។ ៥៦ហេតុការណ៍ទាំងនេះ
កើតឡើង ដើម្បីឲ្យបានស្របតាមសេចក្ដីដែលមាន
ចែងទុកក្នុងគម្ពីរព្យាការី*។ ពេលនោះ ពួកសាវ័កនាំ
គ្នាបោះបង់ចោលព្រះអង្គ ហើយរត់បាត់អស់ទៅ។

## ព្រះយេស៊ូនៅមុខក្រុមប្រឹក្សាជាន់ខ្ពស់

(ម៉ាកុស១៤.៥៣-៦៥ លូកា២២.៥៤-៥៥, ៦៣-៧១ យ៉ូហាន ១៨.១៣-១៤, ១៩.២៤)

៥៧លុះចាប់ព្រះយេស៊ូបានហើយ គេបណ្ដើរព្រះ
អង្គទៅដល់ដំណាក់របស់លោកកៃផាស ជាមហា
បូជាចារ្យ*។ ពួកធម្មាចារ្យ*និងពួកព្រឹទ្ធាចារ្យ*ជួបជុំគ្នា
នៅទីនោះ។ ៥៨លោកសិលាដើរតាមព្រះអង្គពី
ចម្ងាយ គាត់តាមរហូតដល់ទីធ្លាខាងក្នុងដំណាក់
របស់មហាបូជាចារ្យ ហើយអង្គុយជាមួយកងរក្សាព្រះ
វិហារ ចង់ដឹងថាហេតុការណ៍នឹងទៅជាយ៉ាងណា។
៥៩ពួកនាយកបូជាចារ្យនិងក្រុមប្រឹក្សាជាន់ខ្ពស់*
ទាំងមូលនាំគ្នារកពាក្យចោទប្រកាន់ មួលបង្កាច់ព្រះ
យេស៊ូដើម្បីកាត់ទោសប្រហារជីវិតព្រះអង្គ ៦០ទោះបី
មានមនុស្សជាច្រើនធ្វើសាក្សីក្លែងក្លាយក៏ដោយក៏គេ
រកមិនបានដែរ។ នៅទីបំផុតមានបុរសពីរនាក់នាំគ្នា
ចូលមក ៦១ពោលថា៖ «អ្នកនេះបានអះអាងថា"ខ្ញុំ
អាចរុះព្រះវិហាររបស់ព្រះជាម្ចាស់ចោល ហើយសង់
ឡើងវិញបានក្នុងរវាងបីថ្ងៃ"»។ ៦២ពេលនោះលោក
មហាបូជាចារ្យក្រោកឈរឡើង សួរព្រះអង្គថា៖ «
ម្ដេចក៏អ្នកមិនឆ្លើយនឹងពាក្យចោទប្រកាន់របស់អ្នក
ទាំងនេះ?»។ ៦៣ព្រះយេស៊ូនៅស្ងៀម។ លោកមហា
បូជាចារ្យសួរព្រះអង្គទៀតថា៖«ចូរស្បថដោយយក
ព្រះដ៏មានព្រះជន្មគង់នៅ ធ្វើជាប្រធាន តើអ្នកពិតជា
ព្រះគ្រីស្ត* ជាព្រះបុត្រារបស់ព្រះជាម្ចាស់មែនឬ?»។
៦៤ព្រះយេស៊ូមានព្រះបន្ទូលទៅលោកថា៖ «ត្រូវដូច
លោកមានប្រសាសន៍មែន ប៉ុន្តែខ្ញុំសុំបញ្ជាក់ប្រាប់
អស់លោកថា អំណើះតទៅអស់លោកនឹងឃើញបុត្រ
មនុស្ស* គង់នៅខាងស្ដាំព្រះដ៏មានឫទ្ធានុភាព ហើយ
នឹងយាងមកលើពពក* ក្នុងផ្ទៃមេឃ[ឈ]»។ ៦៥ពេល
នោះ លោកមហាបូជាចារ្យហែកអាវរបស់លោក[ញ]
ហើយមានប្រសាសន៍ថា៖ «ជននេះបានពោលពាក្យ
ប្រមាថព្រះជាម្ចាស់ហើយ! យើងមិនបាច់រកសាក្សី
ឯណាទៀតទេ អស់លោកឮអ្នកនេះពោលពាក្យ
ប្រមាថ ព្រះជាម្ចាស់អំបាញ់មិញស្រាប់! ៦៦តើអស់
លោកមានយល់យ៉ាងណា?»។ ពួកគេឆ្លើយឡើងថា
៖ «អ្នកនេះត្រូវមានទោសដល់ជីវិត!»។ ៦៧គេក៏នាំ
គ្នាស្ដោះទឹកមាត់ដាក់ព្រះភក្ត្រព្រះអង្គ គេវាយតប់ព្រះ
អង្គ ហើយអ្នកខ្លះទះកំផ្លៀងព្រះអង្គ ៦៨ទាំងពោលថា
៖ «ទាយមើល៍ព្រះគ្រីស្ដអើយអ្នកណាវាយឯង! »។

## លោកសិលាបដិសេធមិនស្គាល់ព្រះយេស៊ូ

(ម៉ាកុស១៤.៦៦-៧២ លូកា២២.៥៦-៦២ យ៉ូហាន១៨.១២-១៨,២៥-២៧)

៦៩ពេលនោះ លោកសិលាអង្គុយនៅខាងក្រៅ
ក្នុងទីធ្លា។ មានស្ត្រីបម្រើរបស់មហាបូជាចារ្យ*ម្នាក់
ចូលមកជិតគាត់ ពោលថា៖ «អ្នកឯងជាបក្សពួក
របស់យេស៊ូ ជាអ្នកស្រុកកាលីឡេដែរ!»។ ៧០ប៉ុន្តែ
គាត់ប្រកែកថា៖ «ខ្ញុំមិនដឹងថានាងចង់និយាយអំពី
រឿងអ្វីឡើយ!»។ ៧១ពេលលោកសិលាដើរចេញពីទី
នោះឆ្ពោះទៅរកខ្លោងទ្វារ មានស្ត្រីបម្រើម្នាក់ទៀត
ឃើញគាត់ ហើយពោលថា៖ «អ្នកនេះជាបក្សពួក
របស់យេស៊ូ ជាអ្នកភូមិណាសារ៉ែតដែរ!»។ ៧២លោក
សិលាក៏ប្រកែកសាជាថ្មីទាំងស្បថថា៖ «ខ្ញុំមិនស្គាល់
អ្នកនោះទេ!»។ ៧៣បន្តិចក្រោយមក អស់អ្នកដែល
នៅទីនោះ នាំគ្នាចូលទៅជិតលោកសិលា ហើយ

ពោលថា៖ «អ្នកឯងពិតជាបក្សពួករបស់អ្នកទាំង
នោះ ព្រោះសំដីអ្នកឯងបញ្ជាក់ច្បាស់ថា អ្នកឯងមកពី
ស្រុកកាលីឡេមែន!»។ ៧៤លោកសិលាក៏ពោល
ឡើងថា៖ «បើខ្ញុំកុហក សូមព្រះជាម្ចាស់ដាក់ទោស
ខ្ញុំចុះ!។ ខ្ញុំសុំស្បថថា ខ្ញុំមិនដែលស្គាល់អ្នកនោះទាល់
តែសោះ!»។ រំពេចនោះ ស្រាប់តែមាន់រងាវឡើង ៧៥
លោកសិលាក៏នឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូ
ដែលថា៖ «មុនមាន់រងាវ អ្នកនឹងបដិសេធបីដងថា
មិនស្គាល់ខ្ញុំ»[ដ]។ លោកសិលាចាកចេញពីទីនោះ
ហើយយំសោកយ៉ាងខ្លោចផ្សា។

## ក្រុមជំនុំជាន់ខ្ពស់កាត់ទោសព្រះយេស៊ូ

(ម៉ាកុស ១៥.១ លូកា ២៣.១-២ យ៉ូហាន ១៨.២៨-៣២

២៧ ១លុះព្រឹកឡើង ពួកនាយកបូជាចារ្យនិង
ព្រឹទ្ធាចារ្យ*ទាំងអស់របស់ប្រជាជនប្រជុំគ្នា ហើយ
សម្រេចចិត្តធ្វើគុតព្រះយេស៊ូ។ ២គេក៏ចងព្រះអង្គ
បញ្ជូនទៅលោកពីឡាតជាទេសាភិបាល។

## ប្រាក់បង់ថ្លៃឈាម

(កិច្ចការ ១.១៨-១៩)

៣កាលយូដាសជាអ្នក ដែលនាំគេមកចាប់ព្រះ
យេស៊ូ ឃើញគេកាត់ទោសព្រះអង្គដូច្នេះ គាត់សោក
ស្ដាយជាខ្លាំង ក៏យកប្រាក់សាមសិបស្លឹងទៅប្រគល់
ឲ្យពួកនាយកបូជាចារ្យ* និងពួកព្រឹទ្ធាចារ្យ*វិញ
៤ ទាំងពោលថា៖ «ខ្ញុំបានប្រព្រឹត្តអំពើបាប ព្រោះខ្ញុំ
បានបញ្ជូនមនុស្សឥតទោស ទៅឲ្យគេបង្ហូរឈាម»។
ពួកគេឆ្លើយថា៖ «រឿងនេះគ្មានទាក់ទងអ្វីនឹងយើង
ទេ ជារឿងរបស់អ្នកទេតើ!»។ ៥យូដាសបាចប្រាក់
នោះ នៅក្នុងព្រះវិហារ* ហើយចេញទៅចងកសម្លាប់
ខ្លួន។

៦ពួកនាយកបូជាចារ្យរើសប្រាក់នោះ ទាំង
ពោលថា៖ «យើងគ្មានច្បាប់នឹងបញ្ចូលប្រាក់នេះទៅ
ក្នុងហិបតង្វាយឡើយ ព្រោះជាប្រាក់បង់ថ្លៃឈាម[ដ]»
។ ៧ក្រោយពីបានពិភាក្សាគ្នាហើយ គេក៏យកប្រាក់
នោះទៅទិញដីចម្ការរបស់ជាងស្មូន ទុកធ្វើជាកន្លែង
បញ្ចុះសពជនបរទេស។ ៨ហេតុនេះហើយបានជាគេ
ហៅចម្ការនោះថា «ចម្ការឈាម»រហូតមកទល់សព្វ
ថ្ងៃ។ ៩ហេតុការណ៍នេះកើតឡើងស្របនឹងសេចក្ដី
ដែលមានចែងទុក តាមរយៈព្យាការី*យេរេមីថា៖ «
គេបានយកប្រាក់សាមសិបស្លឹង ជាប្រាក់ដែលជន
ជាតិអ៊ីស្រាអែលសន្មតថា ជាថ្លៃទិញលោកនោះ ១០
ហើយគេបានយកប្រាក់នោះទៅទិញចម្ការរបស់ជាង
ស្មូន ដូចព្រះអម្ចាស់បង្គាប់មកខ្ញុំ»[ឋ]។

## លោកពីឡាតកាត់ទោសប្រហារជីវិតព្រះយេស៊ូ

(ម៉ាកុស ១៥.២-១៥ លូកា ២៣.៣-៥;១៣-២៥
យ៉ូហាន ១៨.៣៣-១៩.១៦)

១១ព្រះយេស៊ូឈរ នៅចំពោះមុខលោកទេសាភិ
បាល លោកសួរព្រះអង្គថា៖ «តើអ្នកជាស្ដេចយូដា
មែនឬ?»។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «លោក
ទេតើ ដែលមានប្រសាសន៍ដូច្នេះ»។

១២ពួកនាយកបូជាចារ្យ* និងពួកព្រឹទ្ធាចារ្យ*នាំ
គ្នាចោទប្រកាន់ព្រះអង្គ តែព្រះអង្គពុំឆ្លើយអ្វីទាល់តែ
សោះ។ ១៣លោកពីឡាតសួរព្រះអង្គថា៖«អ្នកមិនឮ
សេចក្ដីទាំងប៉ុន្មាន ដែលគេចោទប្រកាន់អ្នកទេឬ?»
។ ១៤ព្រះយេស៊ូពុំបានឆ្លើយតបមួយម៉ាត់សោះឡើយ
ជាហេតុនាំឲ្យលោកទេសាភិបាលងឿងឆ្ងល់ជាខ្លាំង។

១៥ជារៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យចម្លង*
លោកទេសាភិបាល តែងតែលែងអ្នកទោសម្នាក់
តាមសំណូមពររបស់បណ្ដាជន។ ១៦នៅពេលនោះ
មានអ្នកទោសដ៏ល្បីម្នាក់ ឈ្មោះយេស៊ូបារ៉ាបាស។
១៧កាលបណ្ដាជនមកជុំគ្នាហើយ លោកពីឡាតសួរ
គេថា៖ «តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងអ្នកណា

ដោះលែងយេស៊ូបារ៉ាបាស ឬយេស៊ូហៅព្រះគ្រីស្ត?»។ ១៨លោកពីឡាតមានប្រសាសន៍ដូច្នេះ មកពីលោកជ្រាបថា ពួកគេបញ្ជូនព្រះយេស៊ូមកលោក ព្រោះគេមានចិត្តច្រណែន។

១៩នៅពេល ដែលលោកពីឡាតអង្គុយនៅលើវេទិកាកាត់ក្ដី ភរិយារបស់លោកបានចាត់គេ ឲ្យមកជម្រាបថា៖ «កុំឡូកឡំនឹងរឿងមនុស្សឥតទោសនេះធ្វើអ្វី។ យប់មិញ ព្រោះតែរឿងបុរសនេះ ខ្ញុំយល់សប្តិអាក្រក់ណាស់»។

២០ពួកនាយកបូជាចារ្យ* និងពួកព្រឹទ្ធាចារ្យ*នាំគ្នាញុះញង់បណ្ដាជន ឲ្យសុំដោះលែងបារ៉ាបាស និងសុំប្រហារជីវិតព្រះយេស៊ូ។ ២១លោកទេសាភិបាលមានប្រសាសន៍ទៅគេថា៖ «ក្នុងចំណោមអ្នកទាំងពីរនេះ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងអ្នកណា?»។ ពួកគេឆ្លើយថា៖ «បារ៉ាបាស!»។ ២២ លោកពីឡាតសួរទៅគេថា៖ «បើដូច្នេះ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំធ្វើអ្វីដល់ឈ្មោះយេស៊ូ ហៅព្រះគ្រីស្តនេះ?»។គេស្រែកឡើងទាំងអស់គ្នាថា៖ «យកទៅ ឆ្កាងទៅ!»។ ២៣ លោកមានប្រសាសន៍ថា៖ «តើអ្នកនេះបានប្រព្រឹត្តអំពើអាក្រក់អ្វី?» គេនាំគ្នាស្រែកកាន់តែខ្លាំងឡើងថា៖ «យកទៅ ឆ្កាងទៅ!»។ ២៤ ដោយលោកពីឡាតឃើញថា និយាយទៅឥតបានការ ហើយផ្ទុយទៅវិញ ឃើញគេកើតចលាចលកាន់តែខ្លាំងឡើងៗ ដូច្នេះ លោកក៏យកទឹកមកលាងដៃ នៅមុខបណ្ដាជនទាំងពោលថា៖ «នេះជាបញ្ហារបស់អ្នករាល់គ្នាទេ ខ្ញុំឥតទទួលខុសត្រូវក្នុងការបង្ហូរឈាមបុរសនេះឡើយ»។ ២៥ប្រជាជនឆ្លើយឡើងទាំងអស់គ្នាថា៖ «យើងខ្ញុំនិងកូនចៅរបស់យើងខ្ញុំទទួលខុសត្រូវ ក្នុងការប្រហារជីវិតជននេះ!»។ ២៦ លោកពីឡាតក៏ដោះលែងបារ៉ាបាស រីឯព្រះយេស៊ូវិញ លោកឲ្យគេវាយនឹងរំពាត់ រួចបញ្ជូនព្រះអង្គទៅឲ្យគេឆ្កាង។

## ទាហានមើលងាយនិងធ្វើបាបព្រះយេស៊ូ

(ម៉ាកុស ១៥.១៦-២០ យ៉ូហាន ១៩.២-៣)

២៧ពួកទាហានរបស់លោកទេសាភិបាល នាំព្រះយេស៊ូទៅក្នុងទីធ្លាបន្ទាយ ហើយប្រមូលគ្នីគ្នាក្នុងកងនោះមកចោមរោមព្រះអង្គ។ ២៨គេដោះព្រះពស្ត្ររបស់ព្រះអង្គចេញ ហើយយកអាវធំដែលមានពណ៌ក្រហមទុំមកបំពាក់ថ្វាយព្រះអង្គ។ ២៩គេយកបន្លាមកក្រងធ្វើជាភួង បំពាក់លើព្រះសិរសាព្រះអង្គ និងយកដើមត្រែង មកដាក់ក្នុងព្រះហស្ដស្ដាំ ឲ្យព្រះអង្គកាន់ រួចគេនាំគ្នាលុតជង្គង់នៅមុខព្រះអង្គទាំងពោលចំអកថា៖ «សូមគោរពថ្វាយបង្គំស្ដេចយូដា!»។ ៣០គេស្ដោះទឹកមាត់ដាក់ព្រះអង្គ និងយកដើមត្រែងនោះវាយ ព្រះសិរសាព្រះអង្គទៀតផង។ ៣១ក្រោយពីបានប្រមាថមើលងាយព្រះអង្គរួចហើយ ពួកគេដោះអាវធំចេញ យកព្រះពស្ត្ររបស់ព្រះអង្គមកបំពាក់ថ្វាយព្រះអង្គវិញ រួចបណ្ដើរនាំយកទៅឆ្កាង។

## គេឆ្កាងព្រះយេស៊ូ

(មក ១៥.២១-៣២ លក ២៣.២៦-៤៣
យហ ១៩.១៧-២៧)

៣២ពេលចេញពីទីក្រុងទៅ គេជួបបុរសម្នាក់ឈ្មោះស៊ីម៉ូនជាអ្នកស្រុកគីរេន គេបង្ខំគាត់ឲ្យលីឈើឆ្កាងរបស់ព្រះយេស៊ូ។ ៣៣លុះមកដល់កន្លែងមួយឈ្មោះ «កុលកូថា» ដែលប្រែថា «ភ្នំលលាដ៍ក្បាល» ៣៤គេយកស្រាទំពាំងបាយជូរលាយជាមួយប្រមាត់ មកថ្វាយព្រះអង្គសោយ។ ព្រះយេស៊ូក្រេបបន្តិច ព្រះអង្គពុំព្រមសោយទេ។

៣៥ក្រោយពីឆ្កាងព្រះអង្គរួចហើយ ពួកទាហានយកសម្លៀកបំពាក់របស់ព្រះអង្គ មកចាប់ឆ្នោតចែកគ្នា ៣៦រួចអង្គុយយាមព្រះអង្គនៅទីនោះ។ ៣៧គេបានសរសេរប្រកាស អំពីហេតុដែលគេធ្វើទោសព្រះអង្គថា «អ្នកនេះឈ្មោះយេស៊ូជាស្ដេចជនជាតិយូដា»

ហើយគេបោះប្រកាសនោះនៅពីខាងលើព្រះសិរសា
ព្រះអង្គ។ ៣៨ពេលនោះ គេបានឆ្កាងចោរព្រៃពីរនាក់
ជាមួយព្រះយេស៊ូដែរ ម្នាក់នៅខាងស្ដាំម្នាក់ទៀតនៅ
ខាងឆ្វេង។

៣៩មនុស្សម្នាដើរកាត់តាមនោះ ប្រមាថមើល
ងាយព្រះអង្គ គ្រវីក្បាលដាក់ព្រះអង្គ ៤០ទាំង
ពោលថា៖ «អ្នករុះព្រះវិហារ* ហើយសង់ឡើងវិញតែ
បីថ្ងៃអើយ! ចូរសង្គ្រោះខ្លួនឯងទៅ! បើអ្នកពិតជាព្រះ
បុត្រារបស់ព្រះជាម្ចាស់មែន អញ្ជើញចុះពីឈើឆ្កាង
មក!»។ ៤១រីឯពួកនាយកបូជាចារ្យ ពួកធម្មាចារ្យ*
និងពួកព្រឹទ្ធាចារ្យ*ក៏នាំគ្នាចំអកដាក់ព្រះអង្គ ដូចគេ
ដែរ ដោយពោលថា៖ ៤២«គាត់បានសង្គ្រោះអ្នក
ឯទៀតៗ តែមិនអាចសង្គ្រោះខ្លួនឯងបានទេ! គាត់ជា
ស្ដេចអ៊ីស្រាអែល ឲ្យគាត់ចុះពីឈើឆ្កាងឥឡូវនេះ មក
ដើម្បីយើងជឿផង! ៤៣គាត់បានទុកចិត្តលើព្រះជា
ម្ចាស់ បើព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងគាត់មែន
សូមឲ្យព្រះអង្គដោះលែងគាត់ឥឡូវនេះទៅ![ឆ] ដ្បិត
គាត់ពោលថា "ខ្ញុំជាព្រះបុត្រារបស់ព្រះជាម្ចាស់"»។
៤៤សូម្បីតែចោរព្រៃដែលជាប់ឆ្កាងជាមួយព្រះយេស៊ូក៏
ជេរប្រមាថព្រះអង្គដូច្នោះដែរ។

## ព្រះយេស៊ូសោយទិវង្គត

(មក ១៥.៣៣-៤១ លក ២៣.៤៤-៤៩
យហ ១៩.២៨-៣០)

៤៥ផែនដីទាំងមូលងងឹតសូន្យ ចាប់ពីពេលថ្ងៃ
ត្រង់រហូតដល់ម៉ោងបីរសៀល។ ៤៦ប្រមាណជាម៉ោង
បីរសៀល ព្រះយេស៊ូស្រែកអង្វរខ្លាំងៗថា៖ «អេលី
អេលីឡេម៉ាសាបាច់ថានី!» ដែលមានន័យថា «ឱ
ព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជា
ព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?»[ឈ]។ ៤៧អ្នក
ខ្លះឈរនៅទីនោះ បានឮព្រះបន្ទូលរបស់ព្រះអង្គ ក៏
ពោលថា៖ «គាត់ហៅលោកអេលី!»។ ៤៨រំពេចនោះ
មានគ្នាគេម្នាក់រត់ទៅយកសារាយស្ងួតជ្រលក់នឹងទឹក
ខ្មេះ រុំជាប់នៅចុងត្រែងមួយដើមហុចថ្វាយព្រះអង្គ
សោយ។ ៤៩ប៉ុន្តែ អ្នកឯទៀតៗពោលថា៖ «ចាំមើល
មើល៍! តើលោកអេលីមកសង្គ្រោះគាត់ឬទេ?»។

៥០ព្រះយេស៊ូស្រែកយ៉ាងខ្លាំងម្ដងទៀត រួចផុត
វិញ្ញាណទៅ។ ៥១ពេលនោះ វាំងននៅក្នុងព្រះ
វិហារ* រហែកជាពីរ តាំងពីលើចុះដល់ក្រោមផែនដីក៏
រញ្ជួយថ្មាំងថ្មក៏ប្រេះចេញពីគ្នា ៥២ផ្នូរក៏របើកចំហឡើង
ហើយសាកសពប្រជាជនដ៏វិសុទ្ធ*ជាច្រើនបានរស់
ឡើងវិញ ៥៣និងនាំគ្នាចេញពីផ្នូរ។ ក្រោយពេលព្រះ
យេស៊ូមានព្រះជន្មរស់ឡើងវិញ គេបានចូលទៅក្នុង
ក្រុងដ៏វិសុទ្ធ ព្រមទាំងបង្ហាញខ្លួនឲ្យមនុស្សជាច្រើន
បានឃើញផង។

៥៤កាលនាយទាហានរ៉ូម៉ាំង និងពួកទាហាន
ដែលនៅយាមព្រះយេស៊ូ បានឃើញផែនដីរញ្ជួយ
និងបានឃើញហេតុការណ៍ទាំងឡាយ កើតឡើង
ដូច្នេះគេកោតស្ញប់ស្ញែងជាខ្លាំង ហើយពោលថា៖ «
លោកនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន!»។

៥៥នៅទីនោះ មានស្ត្រីជាច្រើនមើលពីចម្ងាយគឺ
ស្ត្រីៗដែលតាមបម្រើព្រះយេស៊ូ តាំងពីស្រុកកាលីឡេ
មក។ ៥៦ក្នុងចំណោមស្ត្រីៗទាំងនោះ មាននាងម៉ារីជា
អ្នកស្រុកម៉ាដាឡា នាងម៉ារី ជាម្ដាយរបស់យ៉ាកុប
និងយ៉ូសែប ព្រមទាំងភរិយារបស់លោកសេបេដេជា
ដើម។

## ការបញ្ចុះសពព្រះយេស៊ូ

(មក ១៥.៤២-៤៧ លក ២៣.៥០-៥៦ យហ ១៩.៣៨-៤២)

៥៧លុះដល់ល្ងាច មានសេដ្ឋីម្នាក់ឈ្មោះយ៉ូសែប
ជាអ្នកក្រុងអារីម៉ាថេ មកដល់គាត់ក៏ជាសាវ័ករបស់
ព្រះយេស៊ូដែរ។ ៥៨គាត់បានអញ្ជើញទៅជួបលោកពី
ឡាត សុំយកព្រះសពព្រះយេស៊ូ។ លោកពីឡាតក៏
បញ្ជាឲ្យគេប្រគល់ព្រះសពមកគាត់។ ៥៩លោកយ៉ូសែ
បយកព្រះសព មករុំនឹងក្រណាត់ផាឱបថ្មី ៦០រួចដាក់

ក្នុងផ្នូរថ្មីរបស់គាត់ជារូងថ្មដែលគេដាប់ធ្វើផ្នូរ។ បន្ទាប់
មក គាត់ប្រមៀលថ្មមួយដុំធំបិទមាត់ផ្នូរ ហើយចាក
ចេញទៅ។ ៦១នាងម៉ារីជាអ្នកស្រុកម៉ាដាឡា និងនាង
ម៉ារីម្នាក់ទៀត ក៏នៅទីនោះដែរ នាងអង្គុយនៅមុខផ្នូ
រ។

៦២នៅថ្ងៃបន្ទាប់ ជាថ្ងៃរៀបចំថ្ងៃឈប់សម្រាក*
ពួកនាយកបូជាចារ្យ* និងពួកខាងគណៈផារីស៊ី*នាំគ្នា
ទៅជួបលោកពីឡាត ៦៣ជម្រាបថា៖ «លោកម្ចាស់!
យើងខ្ញុំនៅចាំពាក្យរបស់ជនបោកប្រាស់នោះកាលពី
គាត់នៅរស់ថា៖ "បីថ្ងៃក្រោយខ្ញុំស្លាប់ ខ្ញុំនឹងមានជីវិត
រស់ឡើងវិញ"។ ៦៤ហេតុនេះ សូមលោកបញ្ជាឲ្យគេ
យាមផ្នូរនោះ រហូតដល់ថ្ងៃទីបីទៅក្រែងលោសិស្ស
របស់គាត់មកលួចយកសព ហើយប្រាប់ប្រជាជនថា
គាត់រស់ឡើងវិញ។ ការបោកប្រាស់លើកនេះ មុខជា
អាក្រក់ជាងមុនទៅទៀត»។ ៦៥លោកពីឡាតមាន
ប្រសាសន៍ទៅគេថា៖ «អស់លោកមានទាហាន
ស្រាប់ហើយ សុំអញ្ជើញទៅចាត់ចែងឲ្យគេយាមផ្នូរ
តាមអស់លោកយល់ឃើញទៅចុះ!»។ ៦៦ ពួកគេក៏
នាំគ្នាចេញទៅចាត់ចែងឲ្យយាមផ្នូរ គឺភ្ជិតផ្នូរបោះត្រា
ពីលើ និង ដាក់ទាហានឲ្យនៅយាមផង។

## ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

(ម៉ាកុស១៦.១-៨ លូកា២៤.១-១២ យ៉ូហាន២០.១-២០)

២៨ ១ក្រោយថ្ងៃសប្ប័ទ* គឺនៅព្រឹកថ្ងៃអាទិត្យ[ណ] នាង
ម៉ារីជាអ្នកស្រុកម៉ាដាឡា និងនាងម៉ារីម្នាក់ទៀតនាំគ្នា
ទៅមើលផ្នូរ។ ២ ពេលនោះស្រាប់តែផែនដីរញ្ជួយ
យ៉ាងខ្លាំង ដ្បិតមានទេវទូត*របស់ព្រះអម្ចាស់ ចុះពី
ស្ថានបរមសុខ* មកប្រមៀលថ្មចេញពីមាត់ផ្នូរ ហើយ
អង្គុយលើថ្មនោះថែមទៀតផង។ ៣ទេវទូតនោះមាន
ទ្រង់ទ្រាយភ្លឺដូចផ្លេកបន្ទោរ និងមានសម្លៀកបំពាក់
សដូចសំឡី។ ៤ ទាហានភ័យញ័រជាខ្លាំង ភាំងស្មារតី
ដូចមនុស្សស្លាប់។ ៥ទេវទូតនិយាយទៅកាន់ស្ត្រីៗថា
៖ «កុំភ័យខ្លាចអ្វី! ខ្ញុំដឹងថានាងៗមករកព្រះយេស៊ូ
ជាអ្នកភូមិណាសារ៉ែតដែលគេបានឆ្កាង។ ៦ព្រះអង្គ
មិននៅទីនេះទេ ព្រះជាម្ចាស់បានប្រោសព្រះអង្គ ឲ្យ
មានព្រះជន្មរស់ឡើងវិញ ដូចទ្រង់មានព្រះបន្ទូលរួច
មកហើយ សុំមកមើលកន្លែង ដែលគេដាក់ព្រះសព
ព្រះអង្គឯណេះសិន ៧ហើយសឹមអញ្ជើញទៅប្រាប់
ពួកសាវ័ករបស់ព្រះអង្គជាប្រញាប់ថា ព្រះអង្គមាន
ព្រះជន្មរស់ឡើងវិញហើយ ឥឡូវនេះព្រះអង្គយាង
ទៅស្រុកកាលីឡេមុនអ្នករាល់គ្នា។ នៅទីនោះអ្នក
រាល់គ្នានឹងឃើញព្រះអង្គ សុំនាងជ្រាប!»។

៨ស្ត្រីទាំងនោះប្រញាប់ប្រញាល់ ចេញពីផ្នូរទាំង
ភ័យទាំងអរយ៉ាងខ្លាំង នាំដំណឹងនេះរត់ទៅជម្រាប
ពួកសាវ័ក។ ៩ពេលនោះ ស្រាប់តែព្រះយេស៊ូយាង
មកជួបពួកនាង ទ្រង់មានព្រះបន្ទូលថា៖ «ជម្រាប
សួរនាង!»។ នាងទាំងនោះក៏ចូលមកអោបព្រះបាទា
ហើយក្រាបថ្វាយបង្គំព្រះអង្គ។ ១០ព្រះយេស៊ូមានព្រះ
បន្ទូលថា៖ «កុំភ័យខ្លាចអ្វីឡើយ! សុំទៅប្រាប់បងប្អូន
ខ្ញុំឲ្យទៅស្រុកកាលីឡេទៅ គេនឹងឃើញខ្ញុំនៅទី
នោះ»។

១១កាលស្ត្រីទាំងនោះ កំពុងតែធ្វើដំណើរទៅ
ទាហានខ្លះនាំគ្នាចូលទៅទីក្រុង ជម្រាបពួកនាយក
បូជាចារ្យ អំពីហេតុការណ៍ទាំងប៉ុន្មាន ដែលកើតឡើ
ង។ ១២ពួកនាយកបូជាចារ្យក៏ប្រជុំពិភាក្សាគ្នាជាមួយ
ពួកព្រឹទ្ធាចារ្យ ហើយសម្រេចចិត្តឲ្យប្រាក់យ៉ាងច្រើន
ដល់ពួកទាហាន ១៣ទាំងប្រាប់ថា៖«ត្រូវនិយាយថា
"ពេលយើងខ្ញុំកំពុងដេកលក់មានសិស្សរបស់អ្នកនោះ
មកលួចយកសពទៅ ទាំងយប់"។ ១៤ ប្រសិនបើ រឿង
នេះលេចឮដល់លោកទេសាភិបាល ចាំយើងជួយ
ដោះស្រាយ ដើម្បីកុំឲ្យអ្នករាល់គ្នាមានទោស»។

១៥ពួកទាហានទទួលយកប្រាក់ ហើយធ្វើតាម
សេចក្ដីដែលគេបង្គាប់។ រឿងនេះក៏លេចឮសុស
សាយក្នុងចំណោមជនជាតិយូដា រហូតមកទល់សព្វ

ថ្ងៃ។

## ព្រះយេស៊ូបង្ហាញខ្លួនឲ្យពួកសាវ័កឃើញ

(ម៉ាកុស ១៦.១៤-១៨ លូកា ២៤.៣៦-៤៩
យ៉ូហាន ២០.១៩-២៣ កិច្ចការ ១.៦-៨)

១៦សាវ័ក*ទាំងដប់មួយរូប នាំគ្នាធ្វើដំណើរទៅ
ស្រុកកាលីឡេ ហើយឡើងទៅលើភ្នំដែលព្រះយេស៊ូ
បានប្រាប់ឲ្យគេទៅ។ ១៧កាលគេបានឃើញព្រះអង្គ
គេក្រាបថ្វាយបង្គំ ប៉ុន្តែមានអ្នកខ្លះនៅសង្ស័យ។១៨
ព្រះយេស៊ូយាងចូលមកជិតគេ ហើយមានព្រះបន្ទូល
ថា៖ «ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរម
សុខ* ទាំងនៅលើផែនដី។ ១៩ដូច្នេះចូរចេញទៅនាំ
មនុស្សគ្រប់ជាតិសាសន៍ ឲ្យធ្វើជាសាវ័ក ហើយធ្វើ
ពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតាព្រះបុត្រា
និងព្រះវិញ្ញាណដ៏វិសុទ្ធ*។ ២០ត្រូវបង្រៀនគេឲ្យប្រតិ
បត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នក
រាល់គ្នា។ ចូរដឹងថាខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀង
រាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក»។

ផ. ពាក្យដើម៖ «សាច់និងឈាម» ដែលសំដៅទៅលើនិស្ស័យជាមនុស្សធម្មតា។•ព. ពាក្យដើម៖ «ទ្វារនៃស្ថានមនុស្សស្លាប់»ឬ« អំណាចមច្ចុរាជ»។•ភ. ក្នុងគំនិតរបស់ជនជាតិយូដាពាក្យ«ចង» មានន័យថា«ហាម»ឬ«ដេញឲ្យចេញពីក្រុមអ្នកជឿ»។រីឯពាក្យ« ស្រាយ»មានន័យថា«អនុញ្ញាតឲ្យ»ឬ«នាំឲ្យចូលក្នុងក្រុមឡើងវិញ»។ •ម. ឯកសារដើមខ្លះមានសរសេរថា«ព្រះគ្រីស្ត»។

យ. ពាក្យដើម «ប្រាក់ពីរដួង៎។រៀងរាល់ឆ្នាំ ជនជាតិអ៊ីស្រាអែលត្រូវបង់ពន្ធព្រះវិហារ ២ ដួង។

រ. «មិនបាត់»ពាក្យដើម«បានចំណេញ»មានន័យថាអ្នកនោះមិនចាកចេញពីក្រុមអ្នកជឿ។• ល. ចោទិយកថា ១៩.១៥។•វ. សូមអានសេចក្ដីពន្យល់អំពីពាក្យ«ចង»និង «ស្រាយ»នេះនៅម៉ាថាយ ១៦.១៩។

ស. «អត់ទោសឲ្យចិតសិបដង ប្រាំពីរដង» មានន័យថា«អត់ទោសឲ្យរហូត»។•ហ. «ប្រាក់ណែន»ជាប្រាក់ខ្មែរបុរាណមួយណែនទិញបានគោមួយនឹម។ប្រាក់មួយលានណែនក្នុងអត្ថបទនេះមានន័យថាច្រើនហួសប្រមាណគឺដូចនិស្ស័យបាបរបស់មនុស្សយើងនៅចំពោះព្រះជាម្ចាស់ដែលមិនអាចយកអ្វីមកសងបាន។ដើម្បីឲ្យរួចបាបនេះ យើងពឹងផ្អែកទៅលើព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គទាំងស្រុង។

ឡ. កំណើតពិភពលោក (លោកុប្បត្តិ) ១.២៧,២.២១-២២។•អ. កំណើតពិភពលោក (លោកុប្បត្តិ) ២.២៤។• ក. យើងអាចបកប្រែម៉្យាងទៀតថា:«មកពីអ្នករាល់គ្នាគ្មានចិត្តប្រណីសន្ដោស»។•ខ. សូមអានពាក្យពន្យល់នៅម៉ាថាយ ៥.៣២។•គ. «មិនអាចរៀបការបាន»ពាក្យដើម:«អ្នកដែលត្រូវគេក្រៀវ»។ • ឃ. «មិនអាចរៀបការបានពីកំណើត» ឬ «ខ្ទើយ»។

ង. សូមអាន សេរីភាព (និក្ខមនំ) ២០. ១២-១៦។ • ច. លេវីវិន័យ ១៩. ១៨។ • ឆ. ឯកសារជាភាសាក្រិកមួយចំនួនមានសរសេរថា «ទទួលវិញដ៏ច្រើនលើសលប់»។

ជ. ក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ «ពែង» ជានិមិត្តរូបនៃទុក្ខលំបាក (ទំនុកតម្កើង ៧៥.៨ ;អេសាយ ៥១.១៧-២២;យេរេមី ២៥.១៥ ។ល។) ព្រះយេស៊ូប្រើពាក្យពែងនេះ សំដៅទៅលើទុក្ខលំបាករបស់ព្រះអង្គនៅលើឈើឆ្កាង (សូមអាន ម៉ាថាយ ២៦.៣៩)។

ឈ. សាការី ៩. ៩។• ញ. «ជយោ»:ភាសាដើម«ហូសាណា» ជាពាក្យជយឃោសន៍ដែលប្រែឲ្យចំៗមានន័យថា«សូមមេត្តាជួយផង»។• ដ. ទំនុកតម្កើង ១១៨.២៥-២៦។• ឋ. អេសាយ ៥៦.៧។• ឌ. យេរេមី ៧.១១។

ឍ. ទំនុកតម្កើង ៨.៣។

ណ. ទំនុកតម្កើង ១១៨.២២។

ត.សូមអានទក.២៥.៥-៦។• ថ.សូមអានសរ.៣.៦។

ទ.សូមអានទក.៦.៥។• ធ.សូមអានលវ.១៩.១៨។• ន.សូមអានទំន.១១០.១។• ប.ភ្លាក់:បំពង់តូចៗសម្រាប់ដាក់បទគម្ពីរសំខាន់ៗចងភ្ជាប់នៅដៃឬភ្ជាប់នឹងថ្ងាស។•ផ.ខ្សែរំយោល:ជនជាតិអ៊ីស្រាអែលធ្វើរំយោលពណ៌ស្វាយភ្ជាប់នៅជាយអាវជានិមិត្តរូបនៃមេឃដែលធ្វើឲ្យគេរំលឹកអំពីវិន័យរបស់ព្រះជាម្ចាស់។

ព.ពាក្យដើម«កូនរបស់នរក»។

ភ.ទំនុកតម្កើង១១៨.២៦។• ម.អេសាយ១៩.២។

យ.ពាក្យនេះសំដៅទៅលើរូបសំណាករបស់ព្រះនានាដែលស្ដេចអន់ទីគូស-អេពីផានបានយកមកតម្កល់ក្នុងព្រះវិហារនៅក្រុងយេរូសាឡឹមនៅឆ្នាំ១៦៥មុនគ.ស.។ព្រះយេស៊ូមានព្រះបន្ទូលទុកអំពីរូបសំណាកដែលជនជាតិរ៉ូមុ ា ំងយកមកដាក់ក្នុងព្រះវិហារនៅគ.ស.៧០។ • រ.ដានីអែល៩.២៧,១២.១១។• ល.ដានីអែល១២.១។• វ.យ៉ូប៣៩.៣០។• ស.អេសាយ១៣.១០។•ហ.អេសាយ៣៤.៤។•ឡ.សាការី១២.១០។•អ.ដានីអែល៧.១៣។

ក.ពាក្យដើម«រដូវក្ដៅ»។

ខ.ពាក្យក្រិក «តាឡិនតូន»(ថាលនេតឹន)មានតម្លៃស្មើនឹងប្រាក់ឈ្នួលកម្មករធ្វើការប្រាំមួយពាន់ថ្ងៃ។យើងសន្មតប្រើពាក្យប្រាក់«ណែន»ជាប្រាក់ខ្មែរបុរាណ:មួយណែនទិញបានគោមួយនឹម។

គ.«ស្លឹង»:ជាប្រាក់ខ្មែរនៅសម័យបុរាណ។យើងសន្មតប្រើពាក្យ«ស្លឹង» នេះដើម្បីប្រែពាក្យ«អារគួរីយ៉ា»(� រង្សា)ជាប្រាក់ចោកៗ។ នៅជំនាន់ព្រះយេស៊ូ គេតែងលក់ទាសករម្នាក់ថ្លៃសាមសិបស្លឹង។ • ឃ.ពាក្យដើម«បញ្ជូន»។

ង.ធម្មតាយើងប្រែពាក្យនេះថា«ប្រព្រឹត្តអំពើបាប» ឬ«ឃ្លាតចាកជំនឿ»ដោយមិនយល់គម្រោងការរបស់ព្រះជាម្ចាស់។•ច.សាការី១៣.៧។

ឆ.ប្រុងស្មារតីមានន័យពីរយ៉ាង។ន័យទីមួយគឺមិនដេកលក់(នៅភ្ញាក់)ន័យទីពីរគឺនៅប្រុងប្រៀបខ្លួនរង់ចាំព្រះជាម្ចាស់។• ជ.ពាក្យដើម«ពែង» សូមអានសេចក្ដីពន្យល់នៅម៉ាថាយ២០.២២។

ឈ.ទំនុកតម្កើង១១០.១; ដានីអែល៧.១៣។• ញ.ជាសញ្ញាកាន់ទុក្ខ។

ដ.សូមអានមថ.២៦.៣៤។• ដដ.ឬជាប្រាក់ទិញជីវិតមនុស្ស។• ឋ.សូមអានសាការី១១.១២-១៣និងយេរេមី១៨.២-៣,១៩.១-២,៣២.៦-១៥)។

ឌ.ទំនុកតម្កើង២២.៩។• ឍ.ទំនុកតម្កើង២២.២។

ណ.ឃ្លាដើម:«កាលថ្ងៃទីមួយនៃសប្ដាហ៍ចាប់ផ្ដើមរះ»។

គំរោងរបស់គម្ពីរម៉ាថាយ

- បញ្ជីរាយនាមអយ្យកោរបស់ព្រះយេស៊ូនិងការប្រសូតរបស់ព្រះអង្គ(១.១-២.២៣)
- បេសកកម្មរបស់លោកយ៉ូហានបាទីស្ដ(៣.១-១២)
- ព្រះយេស៊ូទទួលពិធីជ្រមុជទឹកនិងឈ្នះការល្បួង(៣.១៣-៤.១១)
- ព្រះយេស៊ូប្រកាសដំណឹងល្អនៅស្រុកកាលីឡេ(៤.១២-១៨.៣៥)
- ព្រះយេស៊ូយាងពីស្រុកកាលីឡេឆ្ពោះទៅក្រុងយេរូសាឡឹម(១៩.១-២៥.៣៤)
- សប្ដាហ៍ចុងក្រោយនៅក្រុងយេរូសាឡឹមនិងភូមិដែលនៅជុំវិញ(២១.១-២៧.៦៦)
- ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនិងបង្ហាញខ្លួនឲ្យអ្នកជឿឃើញ(២៨.១-២០)

# ដំណឹងល្អរៀបរៀងដោយលោកម៉ាថាយ

លោកម៉ាថាយជាអ្នកទារពន្ធជាតិយូដាម្នាក់ដែលពីដើមមានឈ្មោះថាលេវី។ព្រះយេស៊ូបានត្រាស់ហៅលោកមកធ្វើជាសាវ័ក ព្រមទាំងបានតែងតាំងលោកជាគ្រីស្តទូតផង។

គោលបំណងរបស់លោកម៉ាថាយ

លោកបានតែងកណ្ឌគម្ពីរដំណឹងល្អនេះក្រោមការបំភ្លឺរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីណែនាំជនជាតិយូដាឲ្យជឿថាព្រះយេស៊ូពិតជាព្រះគ្រីស្តដែលបានយាងមកតាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។លោកចង់បង្ហាញថាព្រះយេស៊ូយាងមកក្នុងលោកនេះដើម្បីបំពេញកិច្ចការទាំងអស់ស្របតាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់កាលពីដើម និងស្របតាមពាក្យដែលពួកព្យាការីថ្លែងទុកមកផងដែរ។

លោកម៉ាថាយចង់ពន្យល់ទៀតថាព្រះយេស៊ូក៏ដូចជាលោកម៉ូសេដែរព្រះអង្គយាងមកប្រទានវិន័យតែវិន័យថ្មីនេះធ្វើឲ្យវិន័យពីដើមមានអត្ថន័យនិងមានតម្លៃពេញលក្ខណៈថែមទៀត។ហេតុនេះហើយបានជាលោកចូលចិត្តដកស្រង់ឃ្លាជាច្រើនពីព្រះគម្ពីរសម្ពន្ធមេត្រីចាស់ដែលជនជាតិយូដាចាំច្បាស់មកចំលងដាក់ក្នុងគម្ពីររបស់លោកដើម្បីធ្វើជាភស្តុតាងបញ្ជាក់ថាព្រះយេស៊ូពិតជាយាងមកផ្តល់អត្ថន័យឲ្យព្រះគម្ពីរសម្ពន្ធមេត្រីចាស់បានពេញលេញ។

លោកម៉ាថាយក៏ចង់ពន្យល់ជនជាតិយូដាថាក្រុមគ្រីស្តបរិស័ទគ្រប់ជាតិគ្រប់សាសន៍ពិតជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់។រីឯជនជាតិអ៊ីស្រាអែលដែលមិនព្រមជឿព្រះយេស៊ូលែងមានសិទ្ធិជាប្រជារាស្ត្ររបស់ព្រះអង្គទៀតហើយ។

លោកម៉ាថាយយកចិត្តទុកដាក់ដាស់តឿនក្រុមគ្រីស្តបរិស័ទដែលហៅថា"ព្រះសហគមន៍"ដ្បិតព្រះសហគមន៍នេះហើយដែលបានទទួលអំណាចពីព្រះគ្រីស្តនិងបន្តបេសកកម្មរបស់ព្រះអង្គក្នុងពិភពលោកសព្វថ្ងៃ។

លោកម៉ាថាយសរសេរកណ្ឌគម្ពីរដំណឹងល្អនេះតាមគំនិតរបស់ជនជាតិយូដាគឺលោកមិនហ៊ានសរសេរព្រះនាមព្រះជាម្ចាស់ទេតែលោកប្រើពាក្យ«ស្ថានបរមសុខ»ជំនួសវិញឧទាហរណ៍លោកប្រើពាក្យ«ព្រះរាជ្យនៃស្ថានបរមសុខ»ជំនួសពាក្យ«ព្រះរាជ្យរបស់ព្រះជាម្ចាស់»។

អ្នកអានមុខជាឃើញក្នុងកណ្ឌគម្ពីរដំណឹងល្អម៉ាថាយថាព្រះយេស៊ូយាងមកផែនដីនេះដើម្បីកសាងពិភពលោកមួយថ្មីគឺ«ព្រះរាជ្យរបស់ព្រះជាម្ចាស់»ហើយព្រះអង្គប្រៀនប្រដៅអស់អ្នកដែលមកតាមព្រះអង្គអំពីរបៀបរស់នៅសមស្របនឹងព្រះរាជ្យនេះដើម្បីឲ្យគេអាចធ្វើជាបន្ទាល់នាំដំណឹងល្អអំពីព្រះរាជ្យទៅប្រកាសប្រាប់មនុស្សទាំងអស់នៅសព្វទីកន្លែងរហូតដល់អវសានកាលនៃពិភពលោក។